# សង្កេតការណ៍

១៣

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទី របស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ខែកក្កដា ឆ្នាំ២០១២

## មាតិកា


បញ្ហាសុខភាព អៀង សារី ២

សក្ខីកម្មរបស់សាក្សី នី កន ៦

សក្ខីកម្មរបស់សាក្សី សតឹម ល្មុត ១៧

សក្ខីកម្មរបស់សាក្សី សៅ សារុន ២៥

សក្ខីកម្មរបស់សាក្សី ឌឹម ងន ៣៦

សក្ខីកម្មរបស់សាក្សី អឿន តាន ៣៨

សក្ខីកម្មរបស់សាក្សី យុន គីម ៤៥

សក្ខីកម្មរបស់សាក្សី ខៀវ នៅ ៥៣



ក្រុមសង្កេតការណ៍ ៈ

ឆាយ ឈុនលី, ឌី សុជាតា,

លឹម ជ័យទត្ត និង ចាន ប្រាថ្នា


ស្ថានភាពក្នុងសហករណ៍នៅរបបកម្ពុជាប្រជាធិបតេយ

(ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជ




ក្រុមមេដឹកនាំខ្មែរក្រហមនៅក្នុងរថភ្លើង (ប្រភពឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២ ៖ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២

*ឆាយ ឈុនលី, ឌី សុជាតា, ចាន ប្រាថ្នា និង លឹម ជ័យទត្ត*

## សេចក្តីផ្តើម

បន្ទាប់ពីការស្តាប់សក្ខីកម្មរបស់សាក្សី ពាន ឃៀន បានបញ្ចប់នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្អាកសវនាការដោយសារបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ។ រហូតមកដល់ថ្ងៃទី២១ ទើបសវនាការចាប់ផ្តើមដំណើរការជាថ្មី ។ ប៉ុន្តែដោយសុខភាពជនជាប់ចោទ អៀង សារី នៅតែចោទជាបញ្ហាដូច្នេះនៅថ្ងៃដដែលនេះ អង្គជំនុំជម្រះបានប្រកាសផ្អាកសវនាការ និងបានកំណត់យកបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី មកធ្វើការសួរដេញដោលនៅក្នុងសវនាការដាច់ដោយឡែកមួយនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ។ សវនាការថ្ងៃទី២៣នេះ អង្គជំនុំជម្រះបានកោះអញ្ជើញលោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា មកសាកសួរអំពីបញ្ហាសុខភាពជនជាប់ចោទ អៀង សារី ។ បន្ទាប់ពីសវនាការនេះបានបញ្ចប់ អង្គជំនុំជម្រះបានប្រកាសផ្អាកសវនាការរហូតដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ ។ ការសម្រេចនេះគឺដោយសារជនជាប់ចោទ អៀង សារី មានបញ្ហាសុខភាពមិនអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មរបស់សាក្សីបាន ។ គួរបញ្ជាក់ថា ចាប់ពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា ស្តីអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី និងសាក្សីចំនួន៧រូបជាបន្តបន្ទាប់ទាក់ទងនឹងអង្គហេតុដែលត្រូវសម្រេចនៅក្នុងតំណាក់កាលទី១នៃសំណុំរឿង០០២ ។ សាក្សីទាំង៧ រួមមាន ៖ ទី១) លោក នី កន គឺជាប្អូនប្រុសបង្កើតរបស់ សុន សេន (រដ្ឋមន្ត្រីនៃក្រសួងការពារជាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ។ លោកមានតួនាទីជាអ្នកឃោសនាអប់រំប្រជាជនឲ្យចូលរួមក្នុងចលនាបដិវត្ត និងទទួលបន្ទុកជាប្រធានចាងហ្វាងផ្នែកពិធីការនៅក្រសួង ការបរទេស ។ ទី២) លោក សរគីម លុត ហៅ មី គឺជាបុគ្គលម្នាក់ ដែលបានឧបត្ថមប្រាក់ដល់ចលនាបដិវត្តរបស់ខ្មែរក្រហម ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យលោកមានតួនាទីជាអគ្គនាយករងធនាគាពាណិជ្ជកម្មកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីជួយ សម្រួលដល់ការធ្វើពាណិជ្ជកម្មក្រៅប្រទេស ។ ទី៣) លោក សៅ សារុន គឺជាអតីតលេខាស្រុក ពេជ្រចិន្តាក្នុងចន្លោះឆ្នាំ១៩៧១-១៩៧៨ ដែលក្រោយមកក្លាយជាប្រធានកងពលតំបន់១០៥ ។ ទី៤) លោក ខឹម ងន គឺជាអតីតអ្នកបំរើការងារនៅស្ថានទូតចិន ហើយបន្ទាប់មកត្រូវបានចាត់តាំងឲ្យបំពេញការងារជាអ្នកទទួលភ្ញៀវនៅក្រសួងការបរទេស ដោយទទួលបន្ទុករៀបចំម្ហូបអាហារ ។ ទី៥) លោក អឿន តាន គឺជា អតីតនិរសារ និងកងការពាររបស់ ប៉ុល ពត ចាប់ពីឆ្នាំ ១៩៧០-១៩៧៩ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបម្រើការងារនៅក្នុងមន្ទីរក១ (ជាកន្លែងស្នាក់នៅ និងជាកន្លែងធ្វើការផ្ទាល់របស់ ប៉ុល ពត) ដោយទទួលបន្ទុកជាអ្នកការពារសន្តិសុខសម្រាប់កិច្ចប្រជុំធំៗនៅមន្ទីរក-១ និងរត់សំបុត្រឬសារទូរលេខពីមន្ទីរក-៧ ទៅប៉ុល ពត និងបញ្ជូនបន្តទៅ នួន ជា ។ទី ៦ លោក យន់ គីម គឺជាអតីតប្រធានសហករណ៍ស្រែខ្ទឿនក្រោយមកជាក្លាយជាប្រធានមន្ទីរសន្តិសុខប-៣ ។ លោកបានផ្តល់សក្ខីកម្មយ៉ាងច្រើនពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាលក្នុងខេត្តក្រចេះ និងទី៧) លោក ខៀវ នៅ ជាអតីតអ្នកគ្រប់គ្រងការដឹកជញ្ជូនសម្ភារៈរបស់រដ្ឋទៅតាមភូមិភាគផ្សេងៗនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងអំឡុងពេលនៃសវនាការទាំងនេះ មានប្រជាជនកម្ពុជា

ចូលរួមស្តាប់ដោយផ្ទាល់ប្រមាណ៤៣០០នាក់ ដែលមកពីបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជាតាមការអញ្ជើញរបស់មន្ត្រីតុលាការទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ ។ ក្នុងការសួរដេញដោលសាក្សី អង្គជំនុំជម្រះបានណែនាំគ្រប់ភាគីឲ្យចោទសំណួរដោយផ្តោតសំខាន់លើអង្គហេតុទាក់ទងនឹង រចនាសម្ព័ន្ធគ្រប់គ្រង រដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

គួរបញ្ជាក់ថា មុននឹងផ្តល់វេទិកាជូនភាគីក្នុងការចោទសួរសាក្សី ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជូនសាក្សីទាំងអស់អំពីសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែលនាំឲ្យមានពិរុទ្ធភាព និងករណីកិច្ចរបស់សាក្សីក្នុងការឆ្លើយតបសំណួររបស់ភាគីផ្សេងៗនូវអ្វីដែលខ្លួនបានដឹង បានឮ បានឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លើកលែងតែការឆ្លើយសំណួរនោះអាចបណ្តាលឲ្យដាក់ពិរុទ្ធភាពមកលើខ្លួនឯង ។ តាមរយៈសិទ្ធិនេះ អង្គជំនុំជម្រះបានផ្តល់មេធាវីប្រឹក្សាម្នាក់សម្រាប់សាក្សីធ្វើការប្រឹក្សាមុននឹងផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។

## I) សវនាការស្តីពីបញ្ហាសុខភាពជនជាប់ចោទ អៀង សារី

### ១) ការពិភាក្សាលើរបាយការណ៍សុខភាពជនជាប់ចោទ អៀង សារី

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការ ដោយសួរដេញដោលសាក្សីថ្មីមួយរូបទៀតដែលមានរហ័សនាមថា TCW-487 ។ មុននឹងឈានដល់ការសួរដេញដោលសាក្សី លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យលោកក្រឡាបញ្ជី ឌុច ដារី ឡើងរាយការណ៍អំពីវត្តមាន និងអវត្តមានរបស់ភាគីទាំងអស់នៅក្នុងបន្ទប់សវនាការ ។ បន្ទាប់ពីការរាយការណ៍របស់ក្រឡាបញ្ជី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ គឺលោក ពេជ អង្គ បានស្នើអង្គជំនុំជម្រះដើម្បីទទួលស្គាល់លោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិថ្មីជនជាតិបារាំង មានឈ្មោះ ឡូរ៍ ដេសហ្វកស៍ (Laure Desforges) ។ អង្គជំនុំជម្រះបានទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមសំណើរបស់លោកសហមេធាវីនាំមុខជាតិ ។ លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យក្រឡាបញ្ជីឡើងអានរបាយការណ៍ពិនិត្យសុខភាព ដែលចេញដោយវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា ដើម្បីជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធបានជ្រាបពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី និងដើម្បីធ្វើជាមូលដ្ឋានក្នុងការពិភាក្សា ។ ជនជាប់ចោទ អៀង សារី បានអវត្តមាន ដោយសារជំងឺ និងបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ កន្លងមកនៅក្នុងរបាយការណ៍ពិនិត្យសុខភាពនោះបានបញ្ជាក់ថា ជនជាប់ចោទ អៀង សារី មានរោគសញ្ញាក្អកជាប់ ពិបាកដកដង្ហើម និងវិលមុខ ។ បន្ថែមពីលើនេះ អៀង សារី ត្រូវបានរកឃើញថា មានជំងឺរលាកទងសួតស្រួចស្រាវ បន្ថែមលើរោគដែលលោកមានស្រាប់ពីពេលមុន គឺជំងឺបេះដូង និងសរសៃឈាម ។ ប៉ុន្តែ ស្ថានភាពជំងឺរបស់ជនជាប់ចោទមានសភាពធូរស្រាល ហើយនឹងអាចចេញពីមន្ទីរពេទ្យនៅព្រឹកថ្ងៃអង្គារ ទី២២ ខែឧសភា ឆ្នាំ២០១២ ខាងមុខ ។ នៅក្នុងរបាយការណ៍នោះដដែល បានបញ្ជាក់បន្ថែម ដោយផ្តល់ជាអនុសាសន៍ថា ក្រោយពេលចេញពីមន្ទីរពេទ្យ ជនជាប់ចោទត្រូវសម្រាកចំនួនពីរថ្ងៃ ដោយយោងលើស្ថានភាពជំងឺ ។ គួរកត់សម្គាល់ថានៅរសៀលថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ នៅពេលកំពុងដំណើរការនីតិវិធីសវនាការសួរដេញដោលសាក្សី ពាន យឿន ដោយក្រុមមេធាវីការពារក្តី នួន ជា ស្រាប់តែមានការជូនដំណឹងមួយដោយអង្គជំនុំជម្រះ បង្គាប់ឲ្យក្រុមមេធាវីការពារក្តី អៀង សារី ចុះទៅពិនិត្យមើលស្ថានភាពកូនក្តីរបស់ខ្លួននៅបន្ទប់ខាងក្រោមសវនាការ គឺនៅក្នុងបន្ទប់រង់ចាំដែល អៀង សារី តែងតែតាមដាននីតិវិធីសវនាការដោយប្រយោលពីទីនោះ ។ ការបង្គាប់ឲ្យក្រុមមេធាវីការពារ អៀង សារី ចុះទៅពិនិត្យស្ថានភាពសុខភាពកូនក្តីរបស់ខ្លួន គឺដោយសារអង្គជំនុំជម្រះបានទទួលដំណឹងពីមន្ត្រីតុលាការថា អៀង សារី មានបញ្ហាវិលមុខ និងពិបាកដកដង្ហើម ដែលតម្រូវឲ្យត្រូវតែបញ្ជូនទៅមន្ទីរពេទ្យដើម្បីព្យាបាលជាបន្ទាន់ ។ បន្ទាប់មកសវនាការបានបន្តធ្វើដោយអវត្តមានជនជាប់ចោទ អៀង សារី ។ បន្ទាប់ពីក្រឡាបញ្ជីបានអានរបាយការណ៍រួច លោកប្រធានអង្គជំនុំជម្រះបានសួរទៅកាន់ភាគីទាំងអស់ដែលមានបំណងលើកឡើងពីយោបល់ផ្សេងៗទាក់ទងនឹងបញ្ហាសុខភាពរបស់ អៀង សារី ។ ភ្លាមៗនោះ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ

អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស លើកឡើងថា ការពិតទៅ អៀង សារី មិនបានបោះបង់សិទ្ធិចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការទេ ។ លោកបាន បន្តថា បើតាមជំហររបស់លោកគឺសវនាការមិនគួរបន្តទៅមុខឡើយ គឺត្រូវរង់ចាំរហូតដល់ អៀង សារី ជាសះស្បើយពីជំងឺ ឬរហូតដល់ពេលជនជាប់ចោទលះបង់សិទ្ធចូលរួមក្នុងសវនាការតែម្តង ។ លោកថា បើយោងតាមគោលការណ៍អន្តរជាតិ ជនជាប់ចោទត្រូវណែនាំមេធាវីរបស់ខ្លួន ប៉ុន្តែពេលនេះក្រុមរបស់លោកនៅមិនទាន់ទទួលបានការណែនាំណាមួយពី អៀង សារី នៅឡើយទេ ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្តី អៀង សារី លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន បានលើកឡើងថា កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ លោក អៀង សារី បានចាកចេញពីសវនាការដោយសារបញ្ហាសុខភាព ហើយបានយល់ ព្រមឲ្យមានការបន្តនីតិវិធីសួរសំណួរសាក្សី ពាន យឿន ម្តងរួចហើយ ។ យោងតាមវិធាន៨១ នៃវិធានផ្ទៃក្នុង ចាំបាច់ត្រូវតែបញ្ជាក់ថា តើជនជាប់ចោទ អៀង សារី យល់ព្រមឲ្យធ្វើដូច្នេះទៀត ឬយ៉ាងណា ។ ប៉ុន្តែអ្វីដែលលំបាកគឺមេធាវីមិនអាចទាក់ទងជនជាប់ ចោទ អៀង សារី បាន ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តទៀតថា យើងមិនដឹងថា អៀង សារី ត្រឡប់ចូលមកសវនាការនៅពេលណាទេ ហើយបើថ្ងៃស្អែកជនជាប់ចោទវិលមកវិញនោះជនជាប់ចោទអាចមានលទ្ធភាព តាមដាននីតិវិធីសវនាការពីបន្ទប់ខាងក្រោមបាន ។ រីឯមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺលោក ពេជ អង្គ មិនមានការជំទាស់លើការលើកឡើងដោយមេធាវីការពារក្តីទេ និងគាំទ្រចំពោះការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ។ ចំណែកឯមេធាវីជាតិការពារក្តី នួន ជា គឺលោក សុន អរុណ បានគាំទ្រចំពោះសំណើរបស់មេធាវីការពារក្តី អៀង សារី និងបានលើកឡើងថាសវនាការគួរតែផ្អាកជាបណ្តោះអាសន្នសិន រង់ចាំការវិលត្រឡប់មកវិញរបស់ជនជាប់ចោទ អៀង សារី ដោយសារសាក្សីTCW-487 មានការពាក់ព័ន្ធច្រើនលើករណីរបស់ អៀង សារី ។ មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ក៏បានធ្វើការគាំទ្រចំពោះការលើកឡើងរបស់លោក មេធាវី កាណាវ៉ាស ដែរ ។

បន្ទាប់ពីបានស្តាប់ការលើកឡើងរបស់ភាគីនៅក្នុងសវនាការអង្គជំនុំជម្រះបានធ្វើការពិភាក្សា និងផ្តល់វេទិកាជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដើម្បីសួរសំណួរបញ្ជាក់ពីក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ។ លោកស្រីចៅក្រមបានស្នើឲ្យក្រុមមេធាវីការពារក្តី អៀង សារី ផ្តល់នូវព័ត៌មានស្តីពីស្ថានភាពសុខភាពរបស់ អៀង សារី និងស្នើឲ្យធ្វើការបញ្ជាក់ពីភាពលំបាកក្នុងការ ទាក់ទងរវាងក្រុមមេធាវីការពារក្តីជាមួយកូនក្តីរបស់ខ្លួននៅពេលដែលកូនក្តីស្ថិតនៅក្នុងមន្ទីរពេទ្យ ។ លោក មេធាវី កាណាវ៉ាស បានឆ្លើយតបចំពោះសំណើទាំងពីរនេះថា ចំពោះការផ្តល់ព័ត៌មានពីស្ថានភាពសុខភាពរបស់ជនជាប់ចោទទៅសាធារណៈជននោះ គឺជារឿងល្អមួយដែលអាចឲ្យគ្រប់គ្នាបានជ្រាបពីបញ្ហានេះ ហើយលោកគិតថា អៀង សារី មិនមានការជំទាស់ចំពោះការផ្តល់ព័ត៌មាននោះឡើយ និងធ្វើយ៉ាងណាដើម្បីឲ្យមានតម្លាភាព ។ ចំពោះសំណើទីពីរ លោកមេធាវីបានឆ្លើយតបថា លោកមិនអាចទាក់ទងកូនក្តីរបស់ខ្លួនបានទេ ព្រោះខាងមន្ទីរពេទ្យបានប្រាប់ថាលោកមិនអាចចូលទៅជួប អៀង សារី បានឡើយ នៅពេលនេះ ។ បន្ទាប់មកប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានបញ្ជាក់ថា ដោយគោរពតាមគោលការណ៍ច្បាប់អន្តរជាតិ ចំពោះការគោរពនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងផ្អែកតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសម្រេចផ្អាកសវនាការរយៈពេលពីរថ្ងៃគឺថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ។ លោកចៅក្រមបានបញ្ជាក់បន្ថែមថា នៅថ្ងៃទី២៣ អង្គជំនុំជម្រះនឹងធ្វើការពិភាក្សាដោយស្តាប់នូវមតិយោបល់ផ្ទាល់របស់លោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា ថាតើលទ្ធភាពរបស់ជនជាប់ចោទ អៀង សារី បន្ទាប់ពីចេញមន្ទីរពេទ្យនោះអាចចូលរួមនៅក្នុងដំណើរការសវនាការបានកម្រិតណា និងតាមរបៀបណា ។ បើការស្តាប់យោបល់របស់លោកវេជ្ជបណ្ឌិត ឃើញថាស្ថានភាពសុខភាពរបស់ជនជាប់ចោទមានសភាពវិជ្ជមាន អង្គជំនុំជម្រះនឹងបន្តសវនាការភ្លាម ប៉ុន្តែបើយោបល់នោះមានភាពអវិជ្ជមាន អង្គជំនុំជម្រះនឹងជម្រាបនៅពេលក្រោយថានឹងត្រូវបន្តដំណើរការសវនាការយ៉ាងដូចម្តេច ។ សូមបញ្ជាក់ថា សវនាការនាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ បានបញ្ចប់នៅវេលា ម៉ោង៩:៥២នាទីព្រឹក ។

## ២) ការដេញដោលពាក់ព័ន្ធនឹងស្ថានភាពសុខភាព

## ជនជាប់ចោទ អៀង សារី

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការ ដើម្បីសួរដេញ ដោលវេជ្ជបណ្ឌិត លីម ស៊ីវុត្ថា បន្ថែមលើរបាយការណ៍ដែលលោកវេជ្ជបណ្ឌិតបានចេញ ទាក់ទងនឹង ស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ។

មុនពេលចាប់ផ្តើមសវនាការ មេធាវីជាអន្តរជាតិការពារក្តី ជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បាន ក្រោកឈរ និងជូនដំណឹងអង្គជំនុំជម្រះអំពីស្ថានភាពរបស់កូនក្តី របស់ខ្លួន ។ លោកមេធាវី ការណាវ៉ាស បានបញ្ជាក់ថា លោកបានជួប ពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួនកាលពីពេលព្រឹក មុនពេលសវនាការ ចាប់ផ្តើម ហើយលោកបានធ្វើសេចក្តីថ្លែងការណ៍ជំនួស អៀង សារី ។ នៅក្នុង សេចក្តីថ្លែងនោះ លោកមេធាវីបានលើកឡើងនូវចំណុច៤គឺ៖

១) ជនជាប់ចោទ អៀង សារី សុំមិនចូលរួមនៅក្នុងកិច្ច ដំណើរការនីតិវិធីទេ ដោយសារស្ថានភាពសុខភាព ។

២) ជនជាប់ចោទ អៀង សារី នឹងមិនជំទាស់ចំពោះការយក បញ្ហាសុខភាពរបស់ខ្លួនមកពិភាក្សានៅក្នុងសវនាការសាធារណៈ ទេ ។

៣) អៀង សារី ពុំបានលះបង់សិទ្ធិរបស់ខ្លួនក្នុងការមាន វត្តមាននៅអំឡុងកិច្ចដំណើរការនីតិវិធី សួរដេញដោលសាក្សីពីររូប ដែលគ្រោងនឹងផ្តល់សក្ខីកម្មទេ នៅពេលដែលសាក្សីទាំងពីររូប មានការជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ចំពោះសកម្មភាព ឬការប្រព្រឹត្តិ ដែលចោទប្រកាន់ប្រឆាំងនឹងខ្លួន ។

៤) អៀង សារី នឹងរក្សាសិទ្ធិមិនចូលរួមនៅក្នុងសវនាការ សួរដេញដោលសាក្សីផ្សេង ដែលមិនមានការជាប់ពាក់ព័ន្ធនឹងការ ចោទប្រកាន់ប្រឆាំងនឹងខ្លួន ព្រោះជនជាប់ចោទមិនចង់ធ្វើឲ្យមាន ការពន្យារពេលដល់កិច្ចដំណើរការនីតិវិធីនៅពេលខាងមុខ ។

ទាក់ទងនឹងស្ថានភាពកូនក្តីរបស់ខ្លួន លោក ការណាវ៉ាស បានបញ្ជាក់ជូនអង្គជំនុំជម្រះថា អៀង សារី តែងតែវិលមុខនៅពេល ព្យាយាមផ្តង់អារម្មណ៍លើសពីរយៈពេល៥នាទី ។ ដូច្នេះ អៀង សារី បានស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីសម្រាប់សប្តាហ៍នេះ ដែល គ្រោងនឹងសួរដេញដោលសាក្សីពីររូបដែលលើកឡើងពីខាងដើម ។ លោកមេធាវីបានបន្តទៀតថា ជនជាប់ចោទ អៀង សារី ពិតជាចង់ ចូលរួមក្នុងសវនាការសួរដេញដោលសាក្សី ដោយនៅរង់ចាំឲ្យមានការ កោះពីសំណាក់អង្គជំនុំជម្រះ ប៉ុន្តែដោយសារតែកូនក្តីរបស់លោក មានអារម្មណ៍ថាមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបានទើប ខ្លួនស្នើសុំឲ្យមានការពន្យារពេល ។

### ២.១ ការសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ និល ណុន


អៀង សារី

ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានចាប់ ផ្តើមសវនាការ ដើម្បីធ្វើការសួរដេញដោលលោកវេជ្ជបណ្ឌិត ស៊ីវុត្ថា អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ហើយ បានកោះ ហៅលោកវេជ្ជបណ្ឌិត លីម ស៊ីវុត្ថា ចូលបន្ទប់សវនាការ ។ លោក ប្រធានបានជម្រាបលោកវេជ្ជបណ្ឌិតថា អង្គជំនុំជម្រះនឹងស្តាប់មតិ យោបល់របស់លោកវេជ្ជបណ្ឌិតអំពីស្ថានភាពសុខភាពរបស់ជនជាប់ ចោទ អៀង សារី ហើយមតិយោបល់នោះនឹងត្រូវអង្គជំនុំជម្រះយក មកពិចារណាថាតើជនជាប់ចោទ អៀង សារី អាចចូលរួមនៅក្នុង សវនាការបានដែរឬយ៉ាងណា ។ លោកប្រធានអង្គជំនុំជម្រះបានចាប់ ផ្តើមសួរសំណួរលោកវេជ្ជបណ្ឌិតអំពីប្រវត្តិសាវតារ និងប្រវត្តិនៃការ សិក្សា ។ លោកវេជ្ជបណ្ឌិត ស៊ីវុត្ថា បានបញ្ជាក់ថា លោកមិនមានជាប់ ពាក់ព័ន្ធ ឬជាសាច់ញាតិជាមួយនឹងភាគីណាមួយនៅក្នុងសវនាការទេ ហើយចំពោះប្រវត្តិសិក្សា និងការងារវិញ លោកបានបញ្ជាក់ថា លោកបានបញ្ចប់បរិញ្ញាបត្រជំនាញវេជ្ជសាស្ត្រនៃក្រសួងសុខា

ភិបាលនៅក្នុងឆ្នាំ២០០៣ បន្ទាប់មកលោកបាន បញ្ចប់ការសិក្សានៅមហាវិទ្យាល័យវែកសៃ(Versailles) ក្នុងទីក្រុងប៉ារីសប្រទេស បារាំង ជំនាញខាងជំងឺបេះដូង ។ ក្រោយពីវិលត្រឡប់ពីប្រទេសបារាំង លោកបានចូលបម្រើការនៅមន្ទីរពេទ្យ មិត្តភាព ខ្មែរ-សូវៀត ផ្នែកសង្គ្រោះបន្ទាន់ កន្លែងដែលលោកកំពុងធ្វើការនាពេលបច្ចុប្បន្ន ។

លោកប្រធានអង្គជំនុំជម្រះ បានបង្គាប់ឲ្យក្រឡាបញ្ជីយករបាយការណ៍ពិនិត្យសុខភាពជនជាប់ ចោទ អៀង សារី ជូនលោកវេជ្ជបណ្ឌិតដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ថាតើរបាយការណ៍នោះពិត ជារបាយការណ៍ដែលធ្វើឡើងដោយលោកវេជ្ជបណ្ឌិតមែនឬទេ ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា របាយការណ៍ពិនិត្យសុខភាពនោះ ពិតជារបាយការណ៍ដែលចេញដោយរូបលោកផ្ទាល់ ហើយរូបលោកក៏ជាអ្នកពិនិត្យ និងតាមដានអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី ដែរ ។ លោកបានបន្ថែមថា លោកបានទទួលបន្ទុកព្យាបាលជនជាប់ចោទ អៀង សារី ចាប់តាំងពីឆ្នាំ២០១១ និងបានរំឭកថា កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនមកមន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត ដោយមានអាការៈក្អកជាប់ៗគ្នា ដែលធ្វើឲ្យជនជាប់ចោទមានការពិបាកក្នុងការដកដង្ហើម និងធ្វើឲ្យវិលមុខ ។ បន្ទាប់ពីបញ្ជូនចូលក្នុងបន្ទប់សង្គ្រោះដើម្បីធ្វើការព្យាបាលរួចហើយ ក្រុម វេជ្ជបណ្ឌិតរកឃើញថា ជនជាប់ចោទ អៀង សារី មានបញ្ហាខាងផ្នែកផ្លូវដង្ហើម និងរលាកទងសួត ប៉ុន្តែពុំមានការប៉ះពាល់ចំពោះស្ថានភាពជំងឺបេះដូងរបស់ជនជាប់ចោទឡើយ ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា ស្ថានភាពជំងឺនេះបាន



វេជ្ជបណ្ឌិត សេង ស៊ីវុត្ថា

ធូរស្រាលចាប់តាំងពីថ្ងៃទី១ នៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យមកម្ល៉េះ ។

## ២.២ ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បានសាកសួរលោកវេជ្ជបណ្ឌិតនូវសំណួរមួយចំនួន ។ សំណួរដំបូង លោកមេធាវី ការណាវ៉ាស បានសួរថា តើជាការពិតដែលឬទេ ដែលថាលោកវេជ្ជបណ្ឌិតមិនមែនជាអ្នកចិត្តវិទូ ឬជាវេជ្ជបណ្ឌិតខាងផ្នែកចិត្តវិទ្យា? លោកវេជ្ជបណ្ឌិត ស៊ីវុត្ថា បានបញ្ជាក់ថា ជាការពិតលោកមិនមែនជាអ្នកចិត្តវិទូ ឬវេជ្ជបណ្ឌិតខាងផ្នែកចិត្តវិទ្យា ។ លោកមេធាវីបានបន្តសួរទៀតថា តើលោកវេជ្ជបណ្ឌិតមានបានធ្វើពិសោធន៍ ឬពិនិត្យតាមដានពីសម្ថភាពរបស់ អៀង សារី ក្នុងការចូលរួមនៅក្នុងសវនាការដែរឬទេ? លោកវេជ្ជបណ្ឌិតបានឆ្លើយតបនឹងសំណួរនេះថា មុនពេលសម្រេចថា ជនជាប់ចោទ អៀង សារី គួរសម្រាករយៈពេល២ថ្ងៃ និងតាមដានសវនាការពីបន្ទប់រង់ចាំ គឺមិនមែនជាការសម្រេចរបស់លោកតែម្នាក់ឯងនោះទេ គឺមានការចូលរួមសម្រេចពីវេជ្ជបណ្ឌិតផ្សេងទៀតដែលមានជំនាញច្បាស់លាស់ ។ លោកមេធាវី ការណាវ៉ាស បានសួរបន្តថា តើវេជ្ជបណ្ឌិតដែលបានចូលរួមសម្រេចនោះមានជំនាញផ្នែកអ្វីខ្លះ? លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា គ្រូពេទ្យទាំងនោះមានជំនាញខាងផ្នែកព្យាបាលជំងឺបេះដូង និងជាគ្រូពេទ្យដែលមានជំនាញខាងចិត្តសាស្ត្រ ។ លោកមេធាវីបន្តសំណួររបស់ខ្លួន ដោយសាកសួរអំពីស្ថានភាពជំងឺកូនក្តីរបស់ខ្លួន ដោយស្នើឲ្យលោក វេជ្ជបណ្ឌិតធ្វើការបញ្ជាក់ថា តើការដែល អៀង សារី មានអាការៈវិលមុខក្រោយពេលអង្គុយ ឬផ្ចង់អារម្មណ៍លើអ្វីមួយនៅប៉ុន្មាននាទីក្រោយ គឺជារឿងប្លែក ឬជារឿងធម្មតាសម្រាប់មនុស្សដែលមានវ័យចំណាស់ ហើយមានជំងឺបេះដូច និងរលាកទងសួតដូចជា អៀង សារី? លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា លោកមិនអាចធ្វើការសន្និដ្ឋានឲ្យបានសុក្រឹត្យចំពោះចំណុចនេះបានទេ ប៉ុន្តែលោកមិនបដិសេធទេថា ស្ថានភាពជំងឺរបស់ អៀង សារី អាចបណ្តាលមកពី ជំងឺផ្តាសសាយ និងរលាកទងសួត រួមទាំងបញ្ហាវ័យចាស់ជរារបស់ជនជាប់ចោទ អៀង សារី ផង ។ លោក

វេជ្ជបណ្ឌិតបានបន្តថា ទោះបីជាជំងឺបេះដូងរបស់ជនជាប់ចោទ អៀង សារី មានស្ថានភាពនឹងនរក្រោយពីការព្យាបាលក៏ដោយក្រុមគ្រូពេទ្យរបស់លោកជឿជាក់ថា បញ្ហាជំងឺនេះនឹងវិវត្តន៍ទៅមុខ ។ ដោយសារមើលឃើញពីស្ថានភាពមិនអាចឈរ និងផ្លូវអារម្មណ៍ និងបញ្ហាវិលមុខរបស់ជនជាប់ចោទ អៀង សារី ទើបលោកមិនទាន់អនុញ្ញាតឲ្យ អៀង សារី ចូលរួមដោយផ្ទាល់នៅក្នុងសវនាការរយៈពេលមួយសប្តាហ៍សិន ដោយរង់ចាំតាមដានស្ថានភាពជំងឺរបស់ជនជាប់ចោទបន្តទៀត ។

## ២.៣ ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិគឺលោក ខេល លីសាក់ បានសួរសំណួរលោកវេជ្ជបណ្ឌិត ស៊ីរ៉ុត្តា តែមួយសំណួរប៉ុណ្ណោះ ។ លោកបានសួរថា តើការដែលលោកវេជ្ជបណ្ឌិតស្នើឲ្យជនជាប់ ចោទ អៀង សារី ឈប់សម្រាកចំនួន២ថ្ងៃនោះ គឺមិនចូលរួមដំណើរការនីតិវិធីទាំងស្រុង ឬសម្រាកដោយចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ? លោកវេជ្ជបណ្ឌិតបានឆ្លើយតបនឹងសំណួរនេះថា រយៈពេល២ថ្ងៃដែលលោកស្នើឲ្យ គឺសុំឲ្យឈប់សម្រាកដោយមិនអនុញ្ញាតឲ្យចូលរួមនៅក្នុងសវនាការទាំងមូលតែម្តង ។

## ២.៤ ការសួរដេញដោលដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានសួរសំណួរលោក វេជ្ជបណ្ឌិត ស៊ីរ៉ុត្តា ទាក់ទងនឹងបញ្ហាវិលមុខរបស់ អៀង សារី ដោយចោទជាសំណួរថា តើនៅអំឡុងពេលដែល អៀង សារី សម្រាកព្យាបាលនៅមន្ទីរពេទ្យ ជនជាប់ចោទរូបនេះ មានដែលបាននិយាយពីបញ្ហាវិលមុខប្រាប់លោក ឬក្រុមការងាររបស់លោកវេជ្ជបណ្ឌិតដែរឬទេ? លោកវេជ្ជបណ្ឌិតបានឆ្លើយតបនឹងសំណួរនេះថា អៀង សារី បានត្អូញត្អែរពីបញ្ហាវិលមុខមុនពេលបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យទៅទៀត ។ លោកមេធាវី ពេជ អង្គ បានបន្តសួរទៀតថា តើការវិលមុខនោះអាចកើតមាននៅក្នុងរយៈពេលយូរ ឬអាចជាសះស្បើយក្នុងរយៈពេលខ្លី? លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា ស្ថានភាពជំងឺរបស់ អៀង សារី ងាយនឹងជាសះស្បើយ ឬនៅរ៉ាំរ៉ៃ គឺអាស្រ័យលើសភាពជាក់ស្តែង ថាតើអ្នកជំងឺអាចសម្រាកបានគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ និងបញ្ជាក់ថា ស្ថានភាពជំងឺនេះ គឺមានការជាប់ទាក់ទងនឹងជំងឺបេះដូង និងរលាកទងសួតរបស់ជនជាប់ចោទដែលធ្វើឲ្យជំងឺរបស់ជនជាប់ចោទនៅតែជាចោទជាបញ្ហា ។

គួរកត់សម្គាល់ថា មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការ លោកប្រធានអង្គជំនុំជម្រះបានស្នើឲ្យលោកមេធាវី កាណាវ៉ាស ធ្វើការបញ្ជាក់ថា តើសាក្សីណាមួយដែលកូនក្តីរបស់ខ្លួនមិនមានចេតនាលះបង់សិទ្ធិក្នុងការចូលរួមសវនាការ? លោកមេធាវីបានឆ្លើយតបថា សវនាការសួរដេញដោលសាក្សីដែល កូនក្តីរបស់លោកមិនមានចេតនាលះបង់សិទ្ធិក្នុងការចូលរួមនោះ គឺសាក្សី TCW-487 និងTCW-583 ។

## II) សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី នី កន

នៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបើកសវនាការឡើងវិញ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី នី កន ហៅ គិន ឬសាត ដែលត្រូវបានស្គាល់ថាជាប្អូនប្រុសបង្កើតរបស់ សុន សេន អតីតរដ្ឋមន្ត្រីនៃក្រសួងការពារជាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។

សវនាការនេះមានរយៈពេលបីថ្ងៃពេញ ដោយមានអ្នកភូមិ និងសិស្សនិស្សិតចូលរួមទស្សនា ប្រមាណជាង៩០០នាក់មកពីបណ្តាខេត្តមួយចំនួន អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោលសាក្សីអំពីអង្គហេតុទាក់ទងនឹង រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងការសួរដេញដោលនេះ ភាគីបានផ្តោតលើប្រវត្តិសាវតាររបស់សាក្សីក្នុងការចូលរួមចលនាបដិវត្ត តួនាទីរបស់សាក្សីក្នុងការឃោសនាអប់រំប្រជាជនដើម្បីឲ្យចូលរួមក្នុងចលនាបដិវត្ត តួនាទីរបស់សាក្សី និងបុគ្គលមួយចំនួននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស ការទទួល និងការជូនដំណើរគណៈប្រតិភូបរទេសមួយចំនួនដែលធ្វើទស្សនកិច្ចនៅតាមភូមិភាគផ្សេងៗ ជាពិសេសទាក់ទងនឹងការទទួលផែនការពីថ្នាក់លើដើម្បីអនុវត្ត និងរាយការណ៍អំពីបញ្ហាផ្សេងៗ ទៅថ្នាក់លើវិញ ។



សាក្សី នី កន

## ១) ប្រវត្តិសាវតាររបស់សាក្សី

លោក នី កន ហៅ“កន” អាយុ ៦៩ឆ្នាំ មានស្រុកកំណើតនៅកម្ពុជាក្រោម ស្រុកត្រាយឹង (ខ្មែរហៅថាស្រុកព្រះត្រពាំង) បច្ចុប្បន្នរស់នៅស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ សឹង នី ម្ដាយឈ្មោះ សឹង សឿង ។ នី កន មានប្រពន្ធឈ្មោះ លឹម គឹមសាត និងមានកូនបីនាក់ ។ លោក នី កន មានបងប្រុសបង្កើតពីរនាក់គឺ សុន សេន ដែលត្រូវបានគេស្គាល់ថាជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង សុន ឈុំ ជាមន្ត្រីទូតនៅប្រទេសកូរ៉េ ។ នៅអាយុ១៥ឆ្នាំ លោក នី កន បានចាកចេញពីស្រុកកំណើតមករស់នៅទីក្រុងភ្នំពេញ ហើយបន្តការសិក្សានៅវិទ្យាល័យ ព្រះស៊ីសុវត្ថិរហូតប្រឡងជាប់ថ្នាក់បឋមភូមិ ។ ក្នុងឆ្នាំ១៩៦៦ លោកបានចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាក្នុងខេត្តសៀមរាប ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ពី អំណាច ឆ្នាំ១៩៧០ លោក នី កន បានរត់ចូលព្រៃដើម្បីចូលរួមក្នុងចលនាបដិវត្តតស៊ូប្រឆាំងនឹងរបប លន់ នល់ និង ចក្រពត្តិអាមេរិក ។ អំឡុងឆ្នាំ១៩៧៤ លោក នី កន ត្រូវបានបញ្ចូលជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈការណែនាំរបស់ សេង ដែលជាប្រធានសាខាបក្សប្រចាំខេត្តសៀមរាប ហើយលោកត្រូវបានបញ្ជូនឲ្យទៅធ្វើសកម្មភាពឃោសនានៅតំបន់១៥ នៃភូមិភាគពិសេស ដែលក្រោយមកក្លាយជាតំបន់៣២ នៃភូមិភាគបស្ចិម ។ គួររំឭកថា មុនពេលបានក្លាយជាសមាជិកបក្ស លោក នី កន គឺជាសមាជិករបស់ “**មហាជនចម្រើន**” ដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការឃោសនាផ្សេងៗ ប្រឆាំង នឹងរបប លន់ នល់ ហើយក្នុងពេលនោះក៏មាន “***សម្ព័ន្ធយុវជនបដិវត្ត***” ធ្វើសកម្មភាពប្រឆាំងដូចគ្នាដែរ ។ នៅចុងឆ្នាំ១៩៧៧ បក្សបានចាត់តាំងលោកឲ្យមកបំពេញការងារផ្នែកពិធីការនៅក្រសួងការបរទេស ដោយទទួលបន្ទុកជូនភ្ញៀវបរទេសធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា ។

## ២) សក្ខីកម្មរបស់សាក្សីចំពោះមុខតំណាងសហព្រះរាជអាជ្ញា

ក្នុងការសួរដេញដោលសាក្សី លោក ចាន់ ដារាវស្សី តំណាងឲ្យសហព្រះរាជអាជ្ញាជាតិ បានសួរផ្ដោតសំខាន់អំពីប្រវត្តិតស៊ូធ្វើបដិវត្តរបស់សាក្សី មុនឆ្នាំ១៩៧៥ ។ ចំណែក លោក វីនសិន ដឺរ៉ាល់ តំណាងឲ្យសហព្រះរាជអាជ្ញាអន្តរជាតិបានសួរផ្ដោតសំខាន់អំពីតួនាទីរបស់សាក្សី និងបុគ្គលមួយចំនួនទៀតនៅភូមិភាគបស្ចិម និងនៅក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ទាក់ទងនឹងសំណួររបស់លោក ចាន់ ដារាវស្សី លោកបាន



ចាន់ ដារាវស្សី



វីនសិន ដឺរ៉ាល់

ស្នើសុំសាក្សីរៀបរាប់អំពីមូលហេតុដែលនាំឲ្យខ្លួនសម្រេចចូលរួមក្នុងចលនាបដិវត្ត តួនាទីនិងការទទួលខុសត្រូវរបស់សាក្សីក្នុងអំឡុងពេលនៃចលនាបដិវត្ត និងការឃោសនាអប់រំផ្សេងៗ ។ ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា បុព្វហេតុចម្បងដែលនាំឲ្យ

លោកសម្រេចចិត្តចូលរួមធ្វើបដិវត្ត គឺដើម្បីរំដោះប្រទេសជាតិចេញពីការត្រួតត្រារបស់ចក្រពត្តិអាមេរិក រួមទាំងរបប លន់ នល់ និងសំខាន់បំផុតគឺដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាមានភាពប្រសើរឡើង ។ ម្យ៉ាងវិញទៀត សុន សេន ដែលត្រូវជាបងប្រុសបង្កើត តែងតែប្រាប់លោកអំពីស្ថានការណ៍នៅស្រុកខ្មែរ និងរឿងល្អៗដែលត្រូវធ្វើ ។ បន្ថែមលើនេះទៀត បន្ទាប់ពីព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានធ្វើរដ្ឋប្រហារទម្លាក់ពីអំណាច នី កន បានសម្រេចរត់ចូលព្រៃតាមការអំពាវនាវរបស់សម្តេចសីហនុ ដើម្បីចូលរួមចលនាបដិវត្ត ។ អំឡុងពេលនោះ នី កន បំពេញការងារក្នុងក្របខ័ណ្ឌរបស់រណសិរ្សរួបរួមជាតិ ដោយបានទទួលបន្ទុកបំផុសបំផុលប្រជាជនដែលរស់នៅតំបន់របស់ខ្លួនឲ្យរួបរួមកម្លាំងដើម្បីតស៊ូប្រឆាំងនឹងរបប លន់ នល់ ។ ជាទូទៅលោកបានឃោសនាឲ្យប្រជាជនខិតខំបង្កបង្កើនផល និង ឧបត្ថមធនធាននិងកម្លាំងដល់កង កម្លាំងប្រយុទ្ធជួរមុខដើម្បីរំដោះប្រទេសចេញពីការគ្រប់គ្រងរបស់ លន់ នល់ ។ លោក នីកនបញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលនោះ គឺមានចលនារបស់ប្រជាជនចូលរួមចលនាតស៊ូធ្វើ បដិវត្តន៍ដោយសារតែមានការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់របស់ លន់ នល់ និងសហរដ្ឋអាមេរិក ។ ដូច្នេះតំបន់សំខាន់ៗដែលលោកត្រូវចុះទៅឃោសនាដើម្បីទាក់ទាញប្រជាជន គឺតំបន់ដែលទទួលរងការទម្លាក់គ្រាប់បែក និងតំបន់ដែលមិនទាន់ត្រូវបានរំដោះ ។ ខ្លឹមសារដែលលោកបានយកទៅឃោសនាអប់រំ ដើម្បីទាក់ទាញប្រជាជនឲ្យចូលរួមក្នុងចលនាបដិវត្ត គឺបានមកពីគោលនយោបាយរបស់បក្ស ដែលត្រូវបានដកស្រង់យកមកបង្រៀនដោយឈ្មោះ សេង ដែលជាប្រធានសាខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំខេត្តសៀមរាប ។ ខ្លឹមសារទាំងនោះភាគច្រើននិយាយពីការជំរុញការបង្កបង្កើនផល ការការពារបូរណភាពទឹកដី ភាពឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថមខ្លួន និងការបណ្តេញសត្រូវឈ្លានពានជាដើម ។

សាក្សីបានបន្តថា ក្នុងអំឡុងឆ្នាំ១៩៧៤ លោកត្រូវបានបក្សបញ្ជូនឲ្យមកធ្វើការនៅតំបន់១៥ ស្ថិតក្នុងភូមិភាគពិសេស ដែលមានទីតាំងនៅស្រុកឧត្តុង ។ ក្រោយមកតំបន់នេះត្រូវបានបញ្ចូលក្នុងតំបន់៣២ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគបស្ចិម ។ តំបន់១៥ គឺជាតំបន់ដែលមានការប្រយុទ្ធ ខ្លាំងក្លាជាមួយកងទ័ព លន់ នល់ ដូច្នេះតំបន់នេះត្រូវបានបែងចែកឲ្យមានអ្នកទទួលខុសត្រូវខាងផ្នែក យោធា (ទទួលបន្ទុកដោយ ចេង អន) ផ្នែកសេដ្ឋកិច្ច ដឹកជញ្ជូន ផ្គត់ផ្គង់ និងអប់រំជាដើម ។ លោក នី កន បញ្ជាក់បន្ថែមថា នៅតំបន់១៥ លោកត្រូវបានបក្សចាត់តាំងឲ្យបំពេញការងារនៅក្នុងគណៈអប់រំ ដោយទទួលបន្ទុកខាងឃោសនា និងអប់រំដល់ប្រជាជនដើម្បីទទួលបានកម្លាំងវាយយកទីក្រុងភ្នំពេញ ។ ខ្លឹមសារដែលត្រូវបានយកមកឃោសនាអប់រំនៅពេលនោះ គឺដូចគ្នានឹងខ្លឹមសារដែលខ្លួនធ្លាប់បានឃោសនានៅមុនឆ្នាំ១៩៧៤ ពោលគឺជំរុញឲ្យប្រជាជនខិតខំបង្កបង្កើនផលដើម្បីអនុវត្តនយោបាយខ្លួនឧបត្ថមខ្លួន កែប្រែជីវភាពប្រជាជនឲ្យមានភាពប្រសើរឡើង រួមកម្លាំងវាយរំដោះប្រទេសជាតិពីសត្រូវ ។ ក្រៅពីនេះ លោកទទួលបន្ទុកបណ្តុះបណ្តាលគោលនយោបាយរបស់បក្សដល់កម្មាភិបាលថ្នាក់ក្រោមដែលត្រូវបានជ្រើស រើសឲ្យមករៀនសូត្រ ។

លោក នី កន បញ្ជាក់បន្ថែមថា បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជារំដោះបានទីក្រុងភ្នំពេញ ពោលគឺ សង្គ្រាមរវាងខ្មែរក្រហម និងរបប លន់ នល់ ត្រូវបានបញ្ចប់ តំបន់១៥ ត្រូវបានដាក់បញ្ចូលក្នុងតំបន់៣២ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគបស្ចិម ។ សាក្សីបញ្ជាក់ថា ឈ្មោះ សារុន ជាលេខាតំបន់៣១ ឈ្មោះ ប៉ាល់ ជាលេខាតំបន់៣២ ដែលតំបន់ទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស៊ី ជាលេខា ភូមិភាគបស្ចិម ។ ដូច្នេះលោកត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់៣២ ដែលមាន តាប៉ាល់ ជាលេខា ។ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ លោកនៅតែទទួលតួនាទីជាអ្នកឃោសនាអប់រំដដែល តែផ្តោតទៅលើការបង្កបង្កើនផល និងលើកទំនប់ប្រឡាយ ដើម្បីធ្វើកសិកម្មតែប៉ុណ្ណោះ ។ ក្នុងឋានៈជាអ្នកឃោសនាអប់រំ លោកទទួលការណែនាំការងារ ឬបណ្តុះបណ្តាលពី តាប៉ាល់ បន្ទាប់ពី តាប៉ាល់ បាន ទទួលការណែនាំពីប្រធានភូមិភាគ ហើយលោកបានរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួនទៅ តាប៉ាល់ ដែល តាប៉ាល់ នឹងរាយការណ៍បន្តទៅប្រធានភូមិភាគ ។ សាក្សីបញ្ជាក់យ៉ាងច្បាស់ថា ជាទូទៅលេខាស្រុកគឺជាសមាជិករបស់គណៈតំបន់ ហើយលេខាតំបន់នីមួយៗ គឺជាសមាជិករបស់គណៈភូមិភាគរបស់ខ្លួន ។ ជាក់ស្តែង តាប៉ាល់ និង តាសារុន ដែលជាលេខាតំបន់គឺជាសមាជិករបស់គណៈភូមិភាគបស្ចិម ។

គួរបញ្ជាក់ថា នៅពេលលោក ចាន់ ដារាវស្មី ចោទសួរអំពីតួនាទី និងភារកិច្ចរបស់ សុន សេន ក្នុងអំឡុងពេលធ្វើបដិវត្ត លោក នី កន តែងតែឆ្លើយថា លោកមិនដឹងអំពីតួនាទី និងភារកិច្ចរបស់ សុន សេន ឡើយ គឺគ្រាន់តែដឹងថា សុន សេន គឺជាអ្នកកាន់កាប់កងទ័ពរួម ដែលបានធ្វើសកម្មភាពតស៊ូ ប្រឆាំងនឹងចក្រពត្តិអាមេរិក និង លន់ នល់ ។

បន្ទាប់ពីលោក ចាន់ ដារាវស្មី បានបញ្ចប់សំណួររបស់ខ្លួន លោក វីនសិន ដឺវ៉ាល់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តចោទសំណួរមួយចំនួនទាក់ទងនឹងចលនាតស៊ូបដិវត្តនៅតំបន់១៥ ការធ្វើមហាសន្និបាតរបស់ភូមិភាគបស្ចិម ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការប្រជុំទិទៀន និងស្ម័យ ទិទៀន តួនាទីរបស់សាក្សីនៅក្នុងក្រសួងការបរទេស ជាពិសេសភារកិច្ចក្នុងការជូនគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមបណ្តាខេត្តផ្សេងៗ និងការរាយការណ៍អំពីដំណើរទស្សនកិច្ចទាំងនេះមកឲ្យថ្នាក់លើវិញ ។

ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា ក្នុងអំឡុងពេលលោកនៅតំបន់១៥ គឺមានចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់ ជាខ្លាំង ព្រោះជារៀងរាល់ថ្ងៃតំបន់នេះទទួលរងនូវការទម្លាក់គ្រាប់បែក និងការបាញ់កាំភ្លើងធំរបស់កងទ័ព លន់ នល់ ។ ក្នុងអំឡុងពេលនោះ កងទ័ពខ្មែរក្រហមបានធ្វើលេណដ្ឋានទ័ពនៅក្បែរខុដុក្ក ព្រោះតំបន់នោះសំបូរទៅដោយដំបូកកណ្តៀរ ។ កងទ័ពខ្មែរក្រហមបានចោះរូងនៅក្រោមដំបូកកណ្តៀរទាំងនោះ ដើម្បីគេចពីការទម្លាក់គ្រាប់បែក ។ លោក នី កន បញ្ជាក់ថា ដំបូកកណ្តៀរដែល មានដើមឈើដុះពីលើ គឺជាទីតាំងរឹងមាំដែលអាចការពារពីការទម្លាក់គ្រាប់បែករបស់សត្រូវបាន ។ បន្ថែម លើនេះ លោកតំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយមានចំណងជើងថា «ប៉ុល ពត ក្នុងសុបិន្តអាក្រក់» សរសេរដោយអ្នកការសែតម្នាក់ឈ្មោះ ហ៊ីលីបស្សូត ដោយលោកបានដកស្រង់សម្តីរបស់ លោក នី កន ដែលបានផ្តល់បទសម្ភាសន៍ថា «យើងបានសង់មន្ទីរបញ្ជាការដ្ឋាននៅក្នុងដីជាមួយនឹងត្រង់សេ និងជម្រកនៅក្នុងដំបូកកណ្តៀរ និងមានប្រព័ន្ធរូង ដែលអាចឲ្យយើងចេញពីដំបូកកណ្តៀរមួយទៅដំបូក កណ្តៀរមួយទៀតបាន ។ ក្នុងករណីដែលមានការទម្លាក់គ្រាប់បែក យើងពួននៅក្នុងនោះដូចកណ្តៀរអ៊ីចឹង ។ ហើយនៅពេលដែលរួចផុតពីគ្រោះថ្នាក់ហើយ យើងចេញមកក្រៅវិញ ហើយយើងផ្តើមធ្វើការងាររបស់យើងបន្តទៅទៀត ។ ជាទូទៅ នៅពេលយើងជីកត្រង់សេ គឺថាយើងដាក់ក្រោមឈើពីលើ ហើយដាក់បាវអង្ករដើម្បីកាត់បន្ថយឥទ្ធិពលគ្រាប់បែក ហើយដីដំបូកកណ្តៀរនេះមាំអាចស៊ូនឹងគ្រាប់បែកបាន» ។ សាក្សីបញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលនោះ លោកគឺជាឃោសនិកជនម្នាក់ ដែលត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងរោងពុម្ព ដោយទទួលបន្ទុកអូសឯកសារពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្ស ដែលថ្នាក់លើបានផ្តល់ឲ្យ ដើម្បីចែកជូន និងឃោសនាអប់រំដល់ប្រជាជនដែលរស់នៅតំបន់របស់ខ្លួន ។

ចំពោះការធ្វើសន្និបាតរបស់ភូមិភាគបស្ចិមវិញ លោក នី កន បញ្ជាក់ថា លោកបានចូលរួមជាច្រើនដងជាមួយកម្មាភិបាលផ្សេងៗទៀតដែលមកពីថ្នាក់តំបន់ និងភូមិភាគ ។ ជាទូទៅប្រធានភូមិភាគជាអ្នកធ្វើអធិបតីនៃសន្និបាត ហើយពេលខ្លះមានថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សដូចជា នួន ជា ធ្វើជាធិបតី ។ ប្រធានបទដែលត្រូវបានលើកមកនិយាយគឺផ្តោតលើការបង្កបង្កើនផល ការអនុវត្តនយោបាយខ្លួន ខុបត្ថមខ្លួនដោយឯករាជ្យនិងម្ចាស់ការ និងការប្រយុទ្ធប្រឆាំងសត្រូវណាដែលរារាំងដល់ការអភិវឌ្ឍន៍ជាតិជាដើម ។ ពាក់ព័ន្ធនឹងការធ្វើសន្និបាតរបស់ភូមិភាគបស្ចិម លោក វីនសិន ដាក់បង្ហាញឯកសារទស្សនាវដ្តី ទង់បដិវត្តមួយច្បាប់ចុះខែសីហា ឆ្នាំ១៩៧៨ ដែលបានចុះផ្សាយសុន្ទរកថាស្តីពី «សេចក្តីណែនាំមួយចំនួនទាក់ទងនឹងការកសាង ការពង្រឹង និងការពង្រីកបក្សដឹកនាំ» ថ្លែងដោយអ្នកតំណាងបក្សក្នុងឱកាស សន្និបាតរបស់ភូមិភាគបស្ចិមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ ។ សាក្សីបញ្ជាក់ថា លោកមិនធ្លាប់បានឃើញខ្លឹមសារនៃសុន្ទរកថានេះឡើយ ព្រោះជាទូទៅលោកមិនដែលទទួលបានឯកសារជាក្រដាសនៅពេល ថ្នាក់លើមកធ្វើការ បណ្តុះបណ្តាលអំពីគោលនយោបាយរបស់បក្សឡើយ ។ ទោះបីជាយ៉ាងណាក្តី លោក វីនសិន ព្យាយាមចោទសំណួរពាក់ព័ន្ធនឹងឯកសារនេះ តែមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឡើយបន្ទាប់ពីក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងថា ក្នុងករណីសាក្សីមិនស្គាល់ឯកសារ ណាមួយ នោះភាគីមិនអាចយកខ្លឹមសារនៅក្នុងឯកសារនោះមកចោទសួរសាក្សីឡើយ ។ ក្រៅពី

ការចូល រួមសន្និបាតបក្ស លោក នី កន បានចូលរួមកិច្ចប្រជុំទិទៀន និងស្វ័យទិទៀនជាប្រចាំ ។ លោកបញ្ជាក់ថា កិច្ចប្រជុំនេះតម្រូវឲ្យធ្វើជាប្រចាំ ហើយអ្នកចូលរួមត្រូវលើកឡើងអំពីកំហុសរបស់ខ្លួន ឬរបស់បុគ្គលណាម្នាក់នៅចំពោះមុខប្រធានអង្គប្រជុំ ។ បន្ទាប់មកប្រធានអង្គប្រជុំនឹងធ្វើការបូកសរុបអំពីកំហុសគ្នងរួចធ្វើរបាយការណ៍ឲ្យថ្នាក់លើដើម្បីសម្រេច ។ អ្នកចូលរួមប្រជុំតែងមានការភ័យខ្លាចនៅពេលដែលខ្លួនមិនទាន់ធ្វើបានសម្រេចតាមផែនការដែលថ្នាក់លើដាក់ឲ្យអនុវត្ត ឬមានបុគ្គលណាម្នាក់ទិទៀនមកលើខ្លួន ។ ដាក់ស្តែងសម្រាប់រូបលោកផ្ទាល់ គឺមានការភ័យខ្លាចនៅពេលដែលផែនការឃោសនារបស់ខ្លួនមិនទាន់ធ្វើបានសម្រេច ។

ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោក នី កន បានបញ្ជាក់ថា បន្ទាប់ពី កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាម លោកត្រូវបានចាត់តាំងឲ្យមកឃោសនាដើម្បីឲ្យប្រជាជនចេញពីទីក្រុង ។ ក្នុងអំឡុងពេលនោះ លោកបានប្រកាសឲ្យប្រជាជនចេញពីទីក្រុងមួយរយៈដោយយកហេតុផលថា ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការពារសុវត្ថិភាពរបស់ប្រជាជនក្នុងករណីវៀតណាមវាយដណ្តើមយកទីក្រុងភ្នំពេញវិញ ។ នៅពេលតំណាងសហព្រះរាជអាជ្ញាសួរថា តើការជម្លៀសនេះមានការរៀបចំគម្រោងជាមុនដែរឬទេ? លោក នី កន បញ្ជាក់ថា លោកមិនបានដឹងច្បាស់ឡើយ តែមុនពេលជម្លៀសគឺសហករណ៍តាមមូលដ្ឋានបានរៀបចំកន្លែងសម្រាប់ទទួលប្រជាជនដែលនឹងត្រូវជម្លៀសមកពីទីក្រុងទុកជាស្រេច ។ សាក្សីបញ្ជាក់បន្ថែមថា ប្រជាជនដែលត្រូវបានជម្លៀសទៅ គឺមិនត្រូវបានបក្សយកចិត្តទុកដាក់អំពីមធ្យោបាយធ្វើដំណើរ ឬកន្លែងស្នាក់នៅឲ្យបានសមរម្យឡើយ ពោលគឺប្រជាជនត្រូវដេកតាមផ្លូវ និងខ្វះខាតអាហារគួរឲ្យអាណិត ។ ប្រជាជនមិនមានលទ្ធភាពណាមួយប្រឆាំងតវ៉ាមិនចេញឡើយ ហើយគាត់មានទឹកមុខមិនសប្បាយចិត្តនៅពេលដែលត្រូវបានបង្ខំឲ្យចាកចោលទ្រព្យសម្បត្តិរបស់ខ្លួន ។

ទោះបីទីក្រុងភ្នំពេញត្រូវបានកាន់កាប់ដោយបក្សកុម្មុយនីស្តក្នុងឆ្នាំ១៩៧៥ក៏ដោយ ក្នុងអំឡុងពេលនោះលោក នី កន នៅតែបំពេញការងារជាអ្នកឃោសនាអប់រំនៅភូមិភាគបស្ចិមដដែល ។ នៅចុងឆ្នាំ១៩៧៧ នី កន ត្រូវបានបក្សបញ្ជូនមកឲ្យធ្វើការនៅផ្នែកពិធីការក្នុងក្រសួងការបរទេស ដោយទទួលបន្ទុកជូនគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមបណ្តាខេត្តនានា ។ មានការសួរបញ្ជាក់ពីតំណាងសហព្រះរាជអាជ្ញាអំពីមូលហេតុដែលនាំឲ្យបក្សផ្លាស់ប្តូរសាក្សីពីភូមិភាគបស្ចិមឲ្យមកធ្វើការនៅក្រសួងការបរទេសវិញ ។ សាក្សីបានបញ្ជាក់ថា លោកមិនបានដឹងពីមូលហេតុដែលនាំឲ្យមានការផ្លាស់ប្តូរកន្លែងធ្វើការនេះទេ ព្រោះថ្នាក់លើមិនដែលបានប្រាប់ឡើយ ។ ជាងនេះទៅទៀតលោកក៏មិនដែលហ៊ានសួររកហេតុផលអ្វីនោះទេ គឺអ្វីៗទាំងអស់បក្សជាអ្នកចាត់ចែង ។ បន្ទាប់ពីសាក្សីបញ្ជាក់ដូច្នេះ តំណាងសហព្រះ រាជអាជ្ញាបានបង្ហាញឯកសារបទសម្ភាសន៍ដែលធ្វើឡើងជាមួយជនជាប់ចោទ អៀង សារី និងលោកស៊ីវ ហេងឌ័រ នៅខែធ្នូឆ្នាំ១៩៩៦ ។ក្នុងបទសម្ភាសន៍នេះ អៀង សារី បានលើកឡើងថា *«...នី កន ដែលជាបងប្អូន របស់ សុន សេន ត្រូវបានបញ្ជូនមកក្រសួងការបរទេសក្នុងខែកក្កដា ឆ្នាំ១៩៧៧ ដោយមូលហេតុគេចោទថាមានការជាប់ពាក់ព័ន្ធនឹងខ្សែ សេ.អ៊ី.អា ។ អ្នកដែលគេចោទថាមានជាប់ពាក់ព័ន្ធនឹងខ្សែ សេ.អ៊ី.អា តែមិនទាន់មានភស្តុតាងគ្រប់គ្រាន់ នោះគេយកមកទុកនៅក្រសួងការបរទេស ដូចជា ណាត និង ហុង ជាដើម...»* ។ បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារនេះ លោក នី កន បានបង្ហាញ នូវការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយលើកឡើងថា លោកទើបតែដឹងអំពីមូលហេតុដែលខ្លួនត្រូវបានបញ្ជូន មកក្រសួងការបរទេសតាមរយៈឯកសារដែលតំណាងសហព្រះរាជអាជ្ញាយកមកបង្ហាញតែប៉ុណ្ណោះ ។

គួររំឭកថា ពាក់ព័ន្ធនឹងការបង្ហាញឯកសារបទសម្ភាសន៍នេះ គឺមានការជំទាស់ពីលោក ម៉ៃឃើល ខណាវ៉ាស ជាមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដោយលោកបានលើកឡើងថា តំណាងសហព្រះរាជអាជ្ញាមិនអាចយកចម្លើយរបស់បុគ្គលផ្សេងមកចោទសួរសាក្សីឡើយ ព្រោះបញ្ហានេះអង្គជំនុំជម្រះបានសម្រេចរួចហើយ ។ ជាលទ្ធផល អង្គជំនុំជម្រះសម្រេចបដិសេធចោលចំពោះការលើកឡើងរបស់លោកមេធាវី ខណាវ៉ាស ។ ភ្លាមនោះលោកមេធាវីបានស្នើឲ្យអង្គជំនុំជម្រះសម្រេចឲ្យបានច្បាស់ពាក់ព័ន្ធនឹងការយកចម្លើយរបស់បុគ្គលផ្សេងៗមកចោទសួរសាក្សី ។ ជាការឆ្លើយតបប្រធានអង្គជំនុំ ជម្រះបញ្ជាក់ថា *«មូលហេតុ សំអាងហេតុនៅក្នុងករណីនេះ គឺខុសប្លែកពីករណីដទៃទៀតដែលអង្គជំនុំ ជម្រះបានសម្រេចរួច*

ហើយ ។ករណីនេះ គឺជាបទសម្ភាសន៍ជាមួយជនជាប់ចោទ អៀង សារី ហើយ នៅពេលនេះ អៀង សារី បាននិងកំពុងមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ ។ ប្រសិនបើគាត់ស្តាប់បានហើយមានបញ្ហា គាត់អាចតទល់ជាមួយនឹងសាក្សីរូបនេះបាន» ។

ពាក់ព័ន្ធនឹងការបញ្ជូនលោក នី កន ទៅក្រសួងការបរទេសដែរ តំណាងសហព្រះរាជអាជ្ញាបានចោទសួរថា ក្នុងអំឡុងពេលសាក្សីត្រូវបានបញ្ជូនពីតំបន់៣២ទៅក្រសួងការបរទេស តើមានការបោសសម្អាតនៅក្នុងចំណោមកម្មាភិបាលរបស់ភូមិភាគ តំបន់ និងស្រុកនៅក្នុងភូមិភាគបស្ចិមដែរឬទេ? សាក្សីបញ្ជាក់ថា លោកបានដឹងពីការបោសសម្អាតនេះតាមរយៈការនិយាយតៗគ្នា ព្រោះពេលនោះលោកបាន មកដល់ក្រសួងការបរទេសហើយ ។

ចំពោះតួនាទីរបស់សាក្សីនៅក្រសួងការបរទេសហាក់ដូចជាមានការខ្វែងគំនិតគ្នារវាងតំណាងសហព្រះរាជអាជ្ញា និងសាក្សី ។ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា សាក្សីគឺជាប្រធានចាងហ្វាងចាត់ចែងពិធីការរបស់ក្រសួង ហើយលោកបានដកស្រង់សម្តីរបស់ អៀង សារី ដែលថា លោក នី កន មានឋានៈខ្ពស់ជាង សូ សែ និងចាត់ចែងការងារពិធីការច្រើនជាង សូ ហុង ។ ប៉ុន្តែលោក នី កន បញ្ជាក់ជូនអង្គជំនុំជម្រះថា ទោះបីខ្លួនមិនយល់ពីវិសាលភាពនៃពាក្យប្រធានចាងហ្វាងពិធីការក៏ដោយខ្លួនមិនអាចមានឋានៈខ្ពស់ជាងគណៈកម្មាធិការមន្ទីរ និងគណៈកម្មាធិការក្រសួងឡើយ ។ ខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ចៀម ដែលជាប្រធានមន្ទីរនៃក្រសួងការបរទេស ។ ជាងនេះទៅទៀត ខ្លួនគ្រាន់តែស្ថិតនៅ ក្នុងផ្នែកតូចមួយនៃពិធីការក្រសួង ដែលទទួលបន្ទុកជូនភ្ញៀវបរទេសក៏រិតទាបទៅធ្វើទស្សនកិច្ចតាមបណ្តាខេត្តតែប៉ុណ្ណោះ ។ ពាក់ព័ន្ធនឹងការលើកឡើងនេះ តំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារដែលបានចុះ ផ្សាយដោយវិទ្យុកម្ពុជាប្រជាធិបតេយ្យ និយាយអំពីការមកដល់របស់លោក ឡេអ៊ុង ប៉ៀកស្តាំង តំណាង ឲ្យ«បក្សកុម្មុយនីស្ត-ឡេនីន» នៅសហរដ្ឋអាមេរិក ។ ឯកសារនេះបង្ហាញថា លោក ឡេអ៊ុង ប៉ៀកស្ទាំង ត្រូវបានទទួលស្វាគមន៍ដោយ លោក នី កន នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ ។ សាក្សីបញ្ជាក់ថា ខ្លួនមិន ចាំអំពីព្រឹត្តការណ៍នេះឡើយ ។ ជាទូទៅការទទួលភ្ញៀវបរទេសធំៗគឺឈ្មោះ អោក សុគន្ធ និង ជួន ប្រសិទ្ធិ ហើយជួនកាល អៀង សារី ជាអ្នកទៅទទួល ។ ទោះបីជាយ៉ាងណាក្តីលោកចាំបានថា លោកធ្លាប់បានជូនភ្ញៀវបរទេសបីនាក់មកពីប្រទេស បែលហ្ស៊ិក ទៅធ្វើទស្សនកិច្ចនៅខេត្តសៀមរាប និងគណៈប្រតិភូមកពីប្រទេស យូហ្គោស្លាវី និងមកពីប្រទេស ជប៉ុន ទៅធ្វើទស្សនកិច្ចនៅតាមភូមិភាគផ្សេងៗ ។ ទាក់ទងនឹងការជូនដំណើរភ្ញៀវមកពីប្រទេស បែលហ្ស៊ិក តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារដែលបានផ្សាយដោយវិទ្យុក្រុងភ្នំពេញក្នុងខែសីហា ឆ្នាំ ១៩៧៨ ស្តីពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃសមាគមន៍ប្រទេស បែលហ្ស៊ិក-កម្ពុជា ។ ឯកសារនេះបញ្ជាក់ថា« គណៈប្រតិភូប្រទេស បែលហ្ស៊ិក បានទៅធ្វើទស្សនកិច្ចនៅភូមិភាគកណ្តាល និងខេត្តរពិនិត្យមើលកន្លែងផលិតថ្នាំ រោងចក្រស្ករដែកនៅកំពង់ចាម រោងចក្រកៅស៊ូនៅចំការដូង និងទស្សនាទំនប់១មករា និងអង្គរវត្ត និងរណ្តៅគ្រាប់បែក ។ បន្ទាប់មកបន្តទៅទស្សនកិច្ចនៅភូមិភាគនិរតីនៅតាកែវ សហករណ៍នៅអង្គតាសោម និងទៅកំពង់សោមមុននឹងត្រឡប់មកភ្នំពេញវិញ» ។ ចំពោះដំណើរទស្សនកិច្ចរបស់អ្នកកាសែតមកពីប្រទេស យូហ្គោស្លាវី តំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារសារទូរលេខមួយចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៨ ស្តីពីដំណើរទស្សនកិច្ច របស់អ្នកកាសែត យូហ្គោស្លាវី នៅភូមិភាគពាយ័ព្យ ។ សារទូរលេខនេះគឺជាសេចក្តីរាយការណ៍ជូនទៅមន្ទីរ ៨៧០ អំពីសំណួរ-ចម្លើយ ដែលអ្នកកាសែតបានសម្ភាសន៍អ្នកធ្វើការនៅត្រពាំងថ្ម អំពីរបបអាហារ លក្ខខណ្ឌការងារ ការដឹកជញ្ជូនអ្នកធ្វើការ និងការរៀបអាពាហ៍ពិពាហ៍ជាដើម ។ បន្ថែមពីលើនេះទៀត លោក នី កន បានបញ្ជាក់ថា នៅពេលជូនដំណើរគណៈប្រតិភូទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋាន លោក បានឃើញប្រជាជនមានជីវភាពខ្វះខាត និងខ្វះជម្រកជាច្រើន ហើយលោកបានយកបញ្ហានេះមករាយការណ៍ជូនថ្នាក់លើរបស់ខ្លួននៅពេលមានការប្រជុំ ។ ចុងក្រោយតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ ដែលលោក នី កន និងលោក គាត ឈន់ ហៅ មុត បានរាយការណ៍ឲ្យ អៀង សារី អំពីសំណើមួយចំនួនរបស់សាស្ត្រាចារ្យ ខាតវែល ជនជាតិអង់គ្លេស និងអ្នកកាសែតជនជាតិ អាមេរិកពីររូប គឺលោកស្រី បែកយ័រ និងលោក ឌឹក ម៉ាន់ ។ សំណើទាំងនោះរួមមាន« សុំទៅជិតព្រំដែន ទៅមើលជនបទ ចង់ឃើញជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ចង់ជួបកម្មាភិបាលនៅគ្រប់ក្រុង

ចង់មើលសហករណ៍ ចង់មើលគុកនយោបាយ ចង់ជួបផ្ទាល់មនុស្សដែលឲ្យនៅដាច់ដោយឡែកពីគ្នា ចង់ដឹងអំពីប្រជាជនចាម ការសម្លាប់មនុស្ស និងចង់ជួបមេដឹកនាំដែលមានដូចជា នាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី អៀង សារី, សុន សេន, អៀង ធីរិទ្ធ, ខៀវ ប៉ុណ្ណារី, នួន ជា, សម្តេចសីហនុ, ហ៊ូយន់ និង ហ៊ូនីម” ។ បន្ទាប់ពីបានពិនិត្យមើលឯកសារ លោក នីកន បញ្ជាក់ថា លោកពិតជាបានរាយណ៍អំពីសំណើនេះមកថ្នាក់លើរបស់ខ្លួនមែន ក៏ប៉ុន្តែសំណើទាំងនេះមិនទទួលបានការអនុញ្ញាតឡើយ ។

### ៣) សក្ខីកម្មរបស់សាក្សីចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោក ឡោ ជុនធី ជាមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានសួរអំពីប្រវត្តិតស៊ូបដិវត្ត តួនាទី និងវិធីសាស្ត្ររបស់សាក្សីក្នុងការឃោសនាអប់រំដល់ប្រជាជន ។ ចំណែកលោក បាណាបេ ណេគ្វី ជាមេធាវីអន្តរជាតិ សួរផ្តោតសំខាន់អំពីការដូនដំណើរគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមបណ្តាភូមិភាគផ្សេងៗ ។

ទោះបីជាអង្គហេតុពាក់ព័ន្ធប្រវត្តិតស៊ូបដិវត្ត និងតួនាទីឃោសនាអប់រំរបស់លោក នីកន ត្រូវបាន តំណាងសហព្រះរាជអាជ្ញាទាំងពីររូបចោទសួរម្តងហើយក៏ដោយ លោកមេធាវី ឡោ ជុនធី នៅតែចោទសំណួរមួយចំនួនទៀតដើម្បីឲ្យសាក្សីបញ្ជាក់កាន់តែច្បាស់ ។ សំណួរមួយចំនួនដែលលោកមេធាវីបានចោទសួរនោះគឺ តើលោក នីកន យកគោលនយោបាយអ្វី និងប្រើវិធីសាស្ត្របែបណាក្នុងការឃោសនាអប់រំប្រជាជនឲ្យចូលរួមក្នុងចលនាបដិវត្ត ? ដូចគ្នានឹងអ្វីដែលសាក្សីបានឆ្លើយតបនឹងតំណាងសហព្រះរាជអាជ្ញាដែរគឺថា ធ្វើការបំផុសបំផុលប្រជាជនឲ្យចូលរួមចលនាបដិវត្តដើម្បីតស៊ូប្រឆាំងនឹងការឈ្លានពានទឹកដីពីសត្រូវរំដោះប្រទេសឲ្យរួចផុតពីការត្រួតត្រារបស់របប លន់ នល់ និងចក្រពត្តិអាមេរិក និងធ្វើឲ្យប្រជាជនមានជីវភាពកាន់តែប្រសើរឡើង ។ ប៉ុន្តែលោកបានបញ្ជាក់បន្ថែមថា បន្ទាប់ពីមានការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីអំណាចនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ គឺចលនាតស៊ូបដិវត្តកាន់តែមានសកាពខ្លាំងឡើងៗ ។ ក្នុងអំឡុងពេលនោះមានការអំពាវនាវពីព្រះមហាក្សត្រឲ្យចូលព្រៃម៉ាគី ដើម្បីតស៊ូប្រឆាំងនឹងរបប លន់នល់ ។ ដោយប្រជាជនគ្រប់ស្រទាប់វណ្ណៈគោរពស្រឡាញ់ព្រះមហាក្សត្រ ដូច្នេះក្នុងការឃោសនាទាក់ទាញប្រជាជនឲ្យចូលរួមចលនាបដិវត្ត គឺយកឈ្មោះរបស់ព្រះហាមក្សត្រមកធ្វើការផ្សព្វផ្សាយក្នុងបុព្វហេតុវាយចក្រពត្តិអាមេរិក ដោយរួមបញ្ចូលទាំងរបប លន់នល់ ដែរ ។ ខ្លឹមសារគាំទ្រសម្តេច សីហនុ ប្រឆាំងនឹងពួកចក្រពត្តិ គឺត្រូវបានលោកផ្ទាល់ (នីកន) និងឃោសនិកជនផ្សេងៗ ទៀតយកទៅផ្សព្វផ្សាយតាមស្រុក តំបន់ និង ភូមិភាគដែលខ្លួនរស់នៅរហូតដល់កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ លោក នីកន មិនបានដឹងថាខ្លឹមសារឃោសនានេះមានប្រភពចេញមកពីមេដឹកនាំ ជាន់ខ្ពស់ណាម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាឡើយ ព្រោះនេះជាការសម្ងាត់ខ្ពស់របស់បក្ស ។

ចំពោះសំណួររបស់លោកមេធាវី បាណាបេ ណេគ្វី គឺ


បាណាបេ ណេគ្វី


ឡោ ជុនធី

ផ្តោតលើដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជប៉ុន មកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៨ ។ លោកមេធាវីបានផ្តោតយ៉ាងសំខាន់ទៅលើសេចក្តីថ្លែងការណ៍ដែលធ្វើដោយប្រធានដឹកនាំគណៈប្រតិភូមកពីប្រទេសជប៉ុនគឺលោក កូហ្សូ ហ្សាសាគី (Kozo Sasaki) អំពីសភាពការណ៍ដែលកើតនៅប្រទេសកម្ពុជា ។ ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចនេះ លោកមេធាវីបានដាក់បង្ហាញឯកសារដែលផ្សាយដោយវិទ្យុក្រុងភ្នំពេញអំពីសេចក្តីថ្លែងការណ៍ដែលធ្វើដោយប្រធានគណៈប្រតិភូជប៉ុនឆ្លើយតបនឹងសំណួររបស់អ្នកកាសែតនៅពេលចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់ខ្លួន ។ លោកមេធាវីបានដកស្រង់ខ្លឹមសារនៃសំណួរដែលបានចោទសួរលោក កូហ្សូ ហ្សាសាគី ក្នុង អំឡុងពេលនោះថា« វៀតណាមដែលជាអ្នកឈ្លានពានវាទទីនិយម និងចក្រពត្តិនិយមអន្តរជាតិកំពុងផ្សព្វផ្សាយឃោសនាបង្កាច់បង្ខូចដោយនិយាយថារដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យកំពុងនៅឯកោ ព្រោះប្រជាជនប្រឆាំងនឹងខ្លួន ហើយមានការរំដើបរំដួលពាសពេញប្រទេសកម្ពុជាគ្មានការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេស ព្រមទាំងថាប្រជាជនក្នុងប្រទេសកម្ពុជាកំពុងត្រូវបានគេសម្លាប់រង្គាល ។ ដោយឥឡូវនេះ អ្នកបានមកដល់ប្រទេសកម្ពុជាអស់រយៈពេលពីរសប្តាហ៍មកហើយ តើលោកគិតយ៉ាងណាចំពោះការឃោសនានេះ?» ។ ជាការឆ្លើយតប លោក កូហ្សូ ហ្សាសាគី បានលើកឡើងថា« យើងមិនឃើញមានការសម្លាប់រង្គាលណាទេ ប្រជាជនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគនៅជនបទ ។ យើងបានឃើញសត្វពាហនៈរាប់ពាន់ក្នុងសហករណ៍ជាច្រើន ។ ប្រសិនបើប្រជាជនកម្ពុជាខ្វះស្បៀង ពួកគេនឹងសម្លាប់សត្វពាហនៈទាំងនោះដើម្បីយកសាច់ ។ ដូច្នេះព័ត៌មានអំពីប្រជាជនកម្ពុជាដែលឆ្លងកាត់ការខ្វះខាតស្បៀងនោះ គឺជាការបោកប្រាស់ថ្មីមួយរបស់ជនជាតិវៀតណាម ។ យើងត្រូវតែកម្ទេចការឃោសនា បោកប្រាស់នេះ ។ កម្ពុជាប្រជាធិបតេយ្យមិនបានលាក់បាំងអ្វីឡើយ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់យើង យើងបានឃើញស្ថានភាពពិតក្នុងប្រទេសកម្ពុជា» ។ បន្ទាប់ពីបានអានខ្លឹមសារនេះជូនសាក្សី លោកមេធាវីបានចោទសួរថា តើអ្វីដែលប្រធានគណៈប្រតិភូជប៉ុនបានថ្លែងប្រាប់អ្នកសារព័ត៌មានដូចទៅនឹងអ្វីដែលសាក្សីបានឃើញក្នុងអំឡុងពេលជូនដំណើរគណៈប្រតិភូនោះដែរឬទេ? ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា អ្វីដែលលោកបានឃើញ គឺមិនដូចអ្វីដែលលោក កូហ្សូ ហ្សាសាគី បានថ្លែង ឡើយ ព្រោះក្នុងអំឡុងពេលនោះ លោកបានឃើញប្រជាជនមានការអត់ឃ្លាន និងខ្វះជម្រកជាច្រើន ។ មានសំណួរមួយចំនួនទៀតដែលលោកមេធាវីបានសួរ គឺពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី លោក នី កន នៅតែបញ្ជាក់ដូចអ្វីដែលលោកបានឆ្លើយជូនតំណាង សហព្រះរាជអាជ្ញាដដែល ។

## ៤) សក្ខីកម្មរបស់សាក្សីចំពោះមុខក្រុមមេធាវីការពារក្តី

បន្ទាប់ពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួររបស់ខ្លួនដោយសារអស់ពេលវេលា ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ដោ ចាប់ផ្តើមពីក្រុមមេធាវីរបស់ នួន ជា បន្ទាប់មក អៀង សារី និង ចុងក្រោយក្រុមមេធាវីរបស់ ខៀវ សំផន ។

## ៤.១) សក្ខីកម្មរបស់សាក្សីចំពោះមុខក្រុមមេធាវីការពារក្តី នួន ជា

ក្នុងការសួរដេញដោលសាក្សី ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ ជាមេធាវីជាតិ និងលោក ម៉ៃឃើល ផេស្តមេន ជាមេធាវីអន្តរជាតិ បានសួរសាក្សីដោយផ្តោតសំខាន់ អំពីមូលហេតុនៃការចូលរួមធ្វើបដិវត្ត ទស្សនាវដ្តីទង់បដិវត្ត អត្តចរិករបស់ជនជាប់ចោទ នួន ជា អង្គការលេខរបស់ក្រសួងការបរទេស ជាពិសេសអំពីការធ្វើសម្បថរបស់សាក្សីមុនពេលចូលមកផ្តល់សក្ខីកម្ម ។

ចាប់ផ្តើមដំបូងលោកមេធាវី សុន អរុណ បានចោទសំណួរមួយចំនួនពាក់ព័ន្ធនឹងការប្រមូលកម្លាំង ដើម្បីចូលរួមក្នុងចលនាបដិវត្តចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ សំណួរមួយក្នុងចំណោមសំណួរជាច្រើនដែលលោក សុន អរុណ បានចោទសួរគឺថា តើសាក្សីធ្លាប់បានឃើញវត្តមានជនបរទេសមកតាំង ទីលំនៅក្នុងប្រទេសកម្ពុជាដែរឬទេ ជាពិសេសកងទ័ពរបស់ វៀត កុង? ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា ទាំងមុនពេល និងក្នុងអំឡុងពេលដែលលោកចូលរួមក្នុងចលនាបដិវត្ត លោកមិនដែលបានឃើញ វត្តមានរបស់ជនបរទេសឡើយ ។ លោកចូលរួមក្នុងចលនាបដិវត្តក្នុងឆ្នាំ១៩៧០ តាមរយៈការអំពាវនាវរបស់រណសិរ្សរួបរួមជាតិ ដែលដឹកនាំដោយសម្តេចព្រះ

នរោត្តម សីហនុ ដែលព្រះអង្គអំពាវនាវឲ្យកូន ចៅរត់ចូលព្រៃម៉ាកគី ដើម្បីរួបរួមកម្លាំងប្រឆាំងនឹងរបប លន់ នល់ និងបណ្តេញចក្រពត្តិអាមេរិកចេញពីប្រទេសកម្ពុជា ។ ក្នុងអំឡុងពេលនោះ លោកស្ថិតនៅក្នុងរណសិរ្សរួបរួមជាតិ ដោយទទួលបន្ទុកឃោសនាអប់រំប្រជាជនអំពីការបង្កបង្កើនផល ការតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក និងរំដោះប្រទេសពីការគ្រប់គ្រងរបស់ លន់ នល់ នៅតាមតំបន់ដែលខ្លួនរស់នៅ ។ សាក្សីបញ្ជាក់ថា ក្នុងការវាយរំដោះទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ គឺមានការរួបរួមរវាងកម្លាំងរណសិរ្សរួបរួមជាតិកម្ពុជា និងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកមិនដឹងថាមានការចូលរួមពីកម្លាំងរបស់វៀតណាមឡើយ ហើយកងទ័ពទាំងនេះបានបែងចែកជា១៨មុខព្រួញដើម្បីវាយចូលទីក្រុងភ្នំពេញ ។

ទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តវិញ លោក នី កន បញ្ជាក់ថា លោកមិនដែលបានឃើញឡើយក្នុងអំឡុងពេលលោកចូលរួមក្នុងចលនាបដិវត្ត ព្រោះទស្សនាវដ្តីទង់បដិវត្តគឺជាឯកសារផ្ទៃក្នុង របស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះក្នុងការអប់រំប្រជាជននៅតាមមូលដ្ឋាន គឺលោកទទួលបានតែខ្លឹមសារនយោបាយដែលត្រូវបានដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្តតែប៉ុណ្ណោះ ។ គួររំឭកថា នៅពេលតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារទស្សនាវដ្តីទង់បដិវត្តជូនសាក្សីពិនិត្យ លោកបានបញ្ជាក់ថា តាមរយៈខ្លឹមសារដែលលោកបានយកទៅឃោសនាអប់រំប្រជាជន និងខ្លឹមសារដែលមាន កំណត់ក្នុងទស្សនាវដ្តីទង់បដិវត្ត គឺមានលក្ខណៈដូចគ្នា ។ ដូច្នេះលោកអះអាងថា ទស្សនាវដ្តីទង់បដិវត្តដែលលោកបានពិនិត្យគឺពិតជាឯកសារ របស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្លឹមសារគោលនយោបាយមួយចំនួនរបស់បក្សដែលលោកបានចាំគឺ វាយសម្រុក បង្កបង្កើនផល ភាពជាម្ចាស់ការនិងឯករាជ្យ ជម្រុញការដោះស្រាយជីវភាពតាមមូលដ្ឋាន ។ ខ្លឹមសារសម្រាប់ធ្វើការឃោសនាអប់រំ គឺមានការប្រែប្រួលអាស្រ័យទៅតាមពេលវេលា កាលៈទេសៈ មជ្ឈដ្ឋានរស់នៅរបស់ប្រជាជន ។ មុនឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅតាមមូលដ្ឋានត្រូវគេឃោសនាឲ្យខិតខំបង្កបង្កើនផលដើម្បីឧបត្ថមកងទ័ពជួរមុខ រួបរួមកម្លាំងដើម្បីវាយសម្រុកលើខ្មាំងសត្រូវ ការចូលរួមជួយដឹកជញ្ជូនជាដើម ហើយក្រោយឆ្នាំ១៩៧៥ គឺការឃោសនាអប់រំផ្តោតលើការបង្កបង្កើនផល លើកទំនប់ ជីកប្រឡាយ ការកសាងប្រទេសជាតិ ។

ចុងក្រោយលោកមេធាវី សុន អរុណ ដាក់បង្ហាញឯកសារស្តីពីអង្គការលេខរបស់ក្រសួងការ បរទេសដែលត្រូវបានរៀបចំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបញ្ជាក់ថា លោកទើបតែបានឃើញ ឯកសារនេះជាលើកដំបូងនៅពេលដែលចៅក្រមស៊ើបអង្កេតយកមកបង្ហាញតែប៉ុណ្ណោះ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ក្រសួងការបរទេសមានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង គឺមិនទាន់ ត្រូវបានអនុវត្តឲ្យបានពេញលេញឡើយ ព្រោះរយៈពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រង គឺមានរយៈពេលខ្លី ។ អ្វីដែលសាក្សីបានបញ្ជាក់យ៉ាងច្បាស់នោះគឺ ក្រោមគ្មានឯករាជ្យឡើយ គឺត្រូវគោរពថ្នាក់លើរបស់ខ្លួន ។

បន្ទាប់ពីបញ្ចប់សំណួររបស់ខ្លួន លោកមេធាវី សុន អរុណ បានផ្ទេរឲ្យសហភាគរបស់ខ្លួនគឺលោក មេធាវី ម៉ៃឃើល ដេស្តមេន ដើម្បីសួរលោក នី កន បន្ត ។ ចាប់ផ្តើមដំបូងនៃសំណួររបស់ខ្លួន លោកមេធាវី ដេស្តមេន បានផ្តោតលើការធ្វើសច្ចាថរបស់សាក្សីមុននឹងចូលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ សំណួរពាក់ព័ន្ធនឹងបញ្ហានេះ បានបណ្តាលឲ្យមានការជជែកគ្នាយ៉ាងខ្លាំងរវាងអង្គជំនុំជម្រះ និងក្រុមមេធាវីការពារក្តីរបស់ នួន ជា ដែលនាំឲ្យមានការកត់សម្គាល់អំពីអត្តចរិករបស់លោកមេធាវី ដេស្តមេន ពីប្រធានអង្គជំនុំជម្រះ ។ មូលហេតុដែលនាំឲ្យប្រធានអង្គជំនុំជម្រះធ្វើការកត់សម្គាល់នេះដោយសារថា នៅពេលចាប់ផ្តើមដំបូងលោកមេធាវីបានសួរសាក្សីថា តើបានធ្វើសច្ចាហើយឬនៅហើយធ្វើនៅកន្លែងណា? ភ្លាមនោះប្រធានអង្គជំនុំជម្រះហាមមិនឲ្យសាក្សីឆ្លើយ ដោយលោកបានលើកឡើងថា ព័ត៌មាននេះត្រូវបានបញ្ជាក់ជូនភាគីម្តងរួចហើយ នៅពេលចាប់ផ្តើមបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ថាសាក្សីបានស្បថរួចរាល់ហើយមុននឹងអនុញ្ញាតឲ្យផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ តបនឹងការសម្រេចរបស់អង្គជំនុំជម្រះ លោក ដេស្តមេន បានលើកឡើងថា តាមធម្មតាសាក្សីត្រូវមកធ្វើសច្ចាជាសាធារណៈនៅក្នុងសាលសវនាការ ។ ឆ្លើយតបនឹងការលើកឡើងនេះ ប្រធានអង្គជំនុំជម្រះបញ្ជាក់ថា ការដែលអនុញ្ញាតឲ្យសាក្សីមកធ្វើសច្ចាថនៅក្នុងសាលសវនាការ គឺសម្រាប់

តែសាក្សីដែលកាន់សាសនាផ្សេងៗ តែប៉ុណ្ណោះ ដូចជាសាសនាគ្រិស្ត ជាដើម ។ ចំណែកសាក្សីដែលកាន់សាសនាព្រះពុទ្ធគឺគត្រូវឲ្យធ្វើ សម្បថនៅ ចំពោះមុខលោកតាដំបងដែកដោយអនុលោមតាមក្រម នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ។ ម្យ៉ាងវិញទៀត បើមេធាវីមាន បំណងធ្វើមោឃភាពលើសក្ខីកម្មរបស់សាក្សីដោយផ្អែកលើភាព មិនត្រឹមត្រូវនៃការធ្វើសម្បថ គឺអាចធ្វើបាននៅពេលភាគីធ្វើសេចក្តី សន្និដ្ឋានបិទចុងបញ្ចប់នៃសវនាការ ។ បន្ថែមលើនេះទៀត ប្រធាន អង្គជំនុំជម្រះព្រមានដល់លោកមេធាវី ដោយមិនអនុញ្ញាតឲ្យសួរ សំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងការធ្វើសម្បថឡើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី លោកមេធាវី ដេស្តមេន នៅតែបន្តសួរ សំណួរពាក់ព័ន្ធនឹងបញ្ហានេះ ដោយលោកសួរសាក្សីថា តើសាក្សី នៅចាំខ្លឹមសារដែលខ្លួនបានធ្វើសម្បថដែរឬទេ បន្ថែមលើនេះ លោកបានដកស្រង់ខ្លឹមសារសម្បថនោះមកអានឲ្យសាក្សីស្តាប់ ម្តងទៀតដើម្បីជាការរំឭក ។ ជាថ្មីម្តងទៀត ប្រធានអង្គជំនុំជម្រះ បង្គាប់ទៅសាក្សីមិនឲ្យឆ្លើយតបនឹងសំណួររបស់លោកមេធាវី ដេស្តមេន ហើយលោកបានធ្វើការកត់សម្គាល់ថា លោកមេធាវី ដេស្តមេនមានអាកប្បកិរិយារឹងរូស មិនស្តាប់តាម ការណែនាំរបស់ អង្គជំនុំជម្រះ ។ ជាការឆ្លើយតប លោកមេធាវី ដេស្តមេន បានលើក ឡើងថា អង្គជំនុំជម្រះមិនទុកលទ្ធភាពឲ្យខ្លួនសួរអំពីភាពអាចទុកចិត្ត បានរបស់សាក្សីក្នុងការផ្តល់សក្ខីកម្ម ហើយអ្វីដែលខ្លួនបានធ្វើ ក៏មិន មែនជាអាកប្បកិរិយារឹងរូសដែរ ព្រោះមេធាវីមានសិទ្ធិធ្វើដូច្នេះ ។ គួររំឭកថា ការធ្វើកំណត់សម្គាល់លើអាកប្បកិរិយារបស់លោក មេធាវី ដេស្តមេន នៅពេលនេះគឺមិនមែនជាលើកទី១ឡើយ ពោលគឺ មានការធ្វើកំណត់សម្គាល់ជាច្រើនដងមកហើយអំពីអាកប្បកិរិយា មិនសមរម្យរបស់លោកមេធាវី ដេស្តមេន ។

សំណួរបន្ទាប់ដែលលោកមេធាវី ម៉ៃឃើល ដេស្តមេន លើកមកសួរសាក្សីគឺពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់លោក គាត ឈន់ និង លោក ហោ ណាំហុង ដោយលោកបានសួរថា តើអ្នកទាំងពីរមានឋានៈអ្វី ហើយទទួលបន្ទុកលើការងារអ្វីខ្លះនៅក្នុង ក្រសួងការបរទេស ។ ជាការឆ្លើយតប លោក នីកន បញ្ជាក់ថា លោក មិនដឹងថាអ្នកទាំងពីរមានឋានៈអ្វីឡើយ ។ លោកធ្លាប់បានឃើញ លោក គាត ឈន់ ទទួល គណៈប្រតិភូបរទេសមួយចំនួន ។ ចំណែក លោក ហោ ណាំហុង វិញគឺលោកមិនដែលបានស្គាល់ឡើយ ហើយក៏ មិនដឹងថាលោក ហោ ណាំហុង ធ្វើអ្វីនៅមន្ទីរបឹងត្របែក(មន្ទីរ-៣២) ដែរ ។

ចុងក្រោយលោកមេធាវី ម៉ៃឃើល ដេស្តមេន ស្នើសុំ អង្គជំនុំជម្រះដាក់បង្ហាញឯកសារមួយដើម្បីសួរសាក្សី ។ មុននឹង សម្រេច ប្រធានអង្គជំនុំជម្រះសួរបញ្ជាក់លោកមេធាវីថា តើ ឯកសារនេះមេធាវីបាន ដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយ ឬនៅ? ហើយត្រូវបានអនុញ្ញាតឲ្យយកមកដេញដោលដែរឬទេ? ជាការឆ្លើយតប លោកមេធាវីបានលើកឡើងថា លោកបានដាក់ ឯកសារនេះនៅក្នុងប្រព័ន្ធ **Interface** របស់លោកដើម្បីឲ្យភាគី ផ្សេងៗទៀតបានដឹង ។ ជាងនេះទៅទៀត លោកបានធ្វើសំណើទៅ មន្ត្រីច្បាប់របស់ អង្គជំនុំជម្រះយូរមកហើយដើម្បីសុំដាក់ឯកសារនេះ នៅចំពោះមុខអង្គជំនុំជម្រះ ក៏ប៉ុន្តែមិនទាន់មានការឆ្លើយតបនៅ ឡើយ ។ ជាលទ្ធផល អង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើរបស់ លោកមេធាវី ដេស្តមេន ដោយផ្តល់សំអាងហេតុថា លោកមេធាវី មិនទាន់បានបំពេញលក្ខខណ្ឌឲ្យបានត្រឹមត្រូវពាក់ព័ន្ធនឹងការដាក់ ឯកសារ ពោលគឺឯកសារដែលអាចយកមកដេញដោលបាន គឺត្រូវមានការទទួលយកជាមុនដោយអង្គជំនុំជម្រះ ។

### ៤.២) សក្ខីកម្មរបស់សាក្សីចំពោះមុខក្រុមមេធាវីការពារក្តី អៀង សារី

ទោះបីសាក្សីជាបុគ្គលម្នាក់ធ្វើការនៅក្រសួងការបរទេស ដែលគ្រប់គ្រងដោយ អៀង សារី ក៏ដោយ ក្នុងការសួរដេញដោល សាក្សីក្រុមមេធាវីការពារក្តី អៀង សារី បានចំណាយពេលតិចជាង មេធាវីក្រុមផ្សេងៗទៀត ពោលគឺលោកមេធាវីជាតិ អាង ឧត្តម បានចោទសំណួរមួយចំនួនប៉ុណ្ណោះទៅសាក្សី ។ សំណួរដំបូង របស់លោកមេធាវី អាង ឧត្តម គឺពាក់ព័ន្ធនឹងទំនាក់ទំនងរវាង លោក នី កន និង ចៀម ។ ឆ្លើយតប នឹងសំណួរនេះ លោក នី កន បញ្ជាក់ថា ចៀម គឺជាប្រធានមន្ទីរនៃក្រសួងការបរទេស ហើយក៏ ជាប្រធានរបស់លោកផ្ទាល់ដែរ ។ រាល់កិច្ចការផ្សេងៗពាក់ព័ន្ធ នឹងផ្នែកពិធីការ ឬការជូនភ្ញៀវបរទេសធ្វើទស្សនកិច្ច គឺលោក ទទួលការណែនាំពី ចៀម ។ ចៀម ជាអ្នកចូលរួមក្នុងកិច្ចប្រជុំធំៗ ជាមួយកម្មាភិបាលជាន់ខ្ពស់របស់ក្រសួង ហើយដាក់ផែនការណ៍

បន្តឲ្យកម្មាភិបាលថ្នាក់ក្រោមអនុវត្ត ។ ជាក់ស្តែងរូបលោកផ្ទាល់គឺតែងតែទទួលបានបញ្ជាពី ចៀម ឲ្យជូនភ្ញៀវទៅធ្វើទស្សនកិច្ចនៅតាមភូមិភាគបន្ទាប់ពី ចៀម បានជួបប្រជុំជាមួយថ្នាក់លើរួចហើយ ។ បន្ទាប់ពីជូនភ្ញៀវបរទេសត្រឡប់មកវិញ គឺលោកត្រូវរាយការណ៍ឲ្យ ចៀម ដែលជាប្រធានរបស់ខ្លួន ហើយ ចៀម នឹងរាយការណ៍ទៅថ្នាក់លើបន្តទៀត ។ ជាទូទៅលោក នី កន រាយការណ៍ អំពីផ្នែកសន្តិសុខសម្រាប់គណៈប្រតិភូ និងទីន្លែងដែលលោកបានជូនគណៈប្រតិភូទៅធ្វើទស្សនកិច្ច ហើយ ពេលខ្លះលោករាយការណ៍អំពីភាពអត់ឃ្លាន និងការខ្វះខាតទីជម្រករបស់ប្រជាជននៅតាមតំបន់ដែលលោកបានឃើញក្នុងអំឡុងពេលដំណើរទស្សនកិច្ចទាំងនោះ ។

បន្ទាប់ពីសួរទំនាក់ទំនងរវាងសាក្សី និង ចៀម លោកមេធាវីបានបង្ហាញឯកសារដែលសាក្សីបាន ផ្តល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតដើម្បីសួរបញ្ជាក់សាក្សី ។ ឯកសារនេះនិយាយពីការចាប់បុគ្គលមួយចំនួនដូចជា មាឃ ទូច ហៅ កែម(ជាមន្ត្រីទូតប្រចាំនៅប្រទេស ឡាវ) ហួត សម្បត្តិ និង អ៊ិន លន ហៅ ណាត មកដាក់នៅមន្ទីរ ស-២១ ។ លោក នី កន បានបញ្ជាក់ជូនចៅក្រមស៊ើបអង្កេតថា រាល់ការផ្លាស់ប្តូរ និង ការចាប់ខ្លួនមន្ត្រីទូត គឺជាការសម្រេចរបស់ថ្នាក់លើ ដែលរួមមាន ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន ។

មុននឹងចូលដល់សំណួរដើម្បីឲ្យសាក្សីបញ្ជាក់នូវអ្វីដែលលោកបានឆ្លើយនេះ លោក អាង ឧត្តម បាន ចោទសំណួរមួយចំនួនដូចជា តើសាក្សីធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំធំៗជាមួយកម្មាភិបាលជាន់ខ្ពស់របស់ ក្រសួងដែរឬទេ? ធ្លាប់បានមើលរបាយការណ៍ ឬមានបុគ្គលណាម្នាក់ប្រាប់អំពីខ្លឹមសារនៃកិច្ចប្រជុំទាំងនោះដែរឬទេ? ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា លោកមិនដែលបានចូលរួមប្រជុំជាមួយកម្មាភិបាលជាន់ខ្ពស់របស់ក្រសួងឡើយ ហើយក៏មិនដែលបានអានខ្លឹមសារនៃកិច្ចប្រជុំធំៗរបស់កម្មាភិបាលទាំងនោះដែរ ដោយសារតែភាពលាក់ការណ៍ខ្ពស់នៃរបបខ្មែរក្រហម ។ ប៉ុន្តែលោកបានដឹងកិច្ចការ និងផែនការ មួយចំនួនរបស់ថ្នាក់លើតាមរយៈ ចៀម បង្គាប់ឲ្យខ្លួនអនុវត្ត ។ ដោយសាក្សីបញ្ជាក់ដូច្នេះ លោកមេធាវីបានចោទសំណួរចុងក្រោយទៅសាក្សីថា« ដោយលោកមិនដែលបានចូលរួមប្រជុំធំៗជាមួយកម្មាភិបាលជាន់ខ្ពស់របស់ក្រសួង ហើយមិនដែលបានមើលរបាយការណ៍នៃកិច្ចប្រជុំទាំងនោះ ដូច្នេះតើត្រូវឬទេ ដែលលោកឆ្លើយថា ការផ្លាស់ប្តូរ ឬចាប់មន្ត្រីទូត ជាការសម្រេចរបស់ ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន គឺជាការស្មានប៉ុណ្ណោះ? » ។ ជាការឆ្លើយតប លោក នី កន បញ្ជាក់ថា តាមការអនុវត្តជាក់ស្តែង កិច្ចការនេះគឺជាការសម្រេចរបស់ថ្នាក់លើ ។

## ៤.៣) សក្ខីកម្មរបស់សាក្សីចំពោះមុខក្រុមមេធាវីការពារក្តី ខៀវ សំផន

ក្នុងការសួរដេញដោលសាក្សី ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន ជាមេធាវីជាតិ និងលោកស្រី អានតា ហ្គីស្សេ ជាមេធាវីអន្តរជាតិ បានសួរសាក្សីដោយផ្តោតសំខាន់អំពីទំនាក់ទំនងរវាងសាក្សី និងជនជាប់ចោទ ខៀវ សំផន បុព្វហេតុនៃការចូលរួមបដិវត្តដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងតួនាទីរបស់សាក្សីក្នុងការឃោសនាអប់រំប្រជាជនជាដើម ។ ឆ្លើយតប នឹងក្រុមធាវីការពារក្តី លោក នី កន បញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកមិនដែលបានទាក់ទងដោយផ្ទាល់ជាមួយ ខៀវ សំផន ឡើយ ។ ប៉ុន្តែលោកបានស្គាល់ដោយសារ ខៀវ សំផន គឺជាកម្មា ភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ចំពោះការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកវិញ លោក នី កន បញ្ជាក់ថា បន្ទាប់ពីមានការ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីដំណែងក្បាល គឺមិនទាន់មានការទម្លាក់គ្រាប់បែកនៅតាមជនបទឡើយ ។ ប៉ុន្តែក្រោយពីមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងកម្លាំងរបស់ លន់ នល់ និង ខ្មែរក្រហមដែល សហការណ៍ជាមួយកម្លាំងរបស់រណសិរ្សរួបរួមជាតិ ទើបមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក ។ ការទម្លាក់នេះបានធ្វើឲ្យប៉ះពាល់ប្រជាជននៅតាមជនបទជាច្រើន ដែលបណ្តាលឲ្យប្រជាជនទាំងនោះចូលរួមចលនាបដិវត្តដើម្បីតស៊ូប្រឆាំងរបប លន់ នល់ និងបណ្តេញចក្រពត្តិអាមេរិកចេញពីប្រទេសកម្ពុជា ។ ចំពោះសំណួរពាក់ព័ន្ធការឃោសនាអប់រំប្រជាជនដើម្បីអូសទាញឲ្យចូលរួមក្នុងចលនាបដិវត្ត គឺលោក នី កន បានបញ្ជាក់ជូនមេធាវីការពារក្តីដូចអ្វីដែលលោកធ្លាប់បានបញ្ជាក់ជូនភាគីផ្សេងៗទៀត ដែលបានសួរអំពីបញ្ហានេះដែរ ។

បន្ទាប់ពីសវនាការស្តាប់សក្ខីកម្មរបស់លោក នី កន ត្រូវបាន

បញ្ចប់ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោក សគីម លុត ។

## III) សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី សគីម លុត

បន្ទាប់ពីការស្តាប់សក្ខីកម្មរបស់សាក្សី នី កន នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន ចាប់ផ្តើមស្តាប់សក្ខីកម្មរបស់សាក្សីថ្មីមួយរូបទៀត ។ លោក សគីម លុត ហៅ មី គឺជាអតីតអគ្គនាយករងនៅធនាគាពាណិជ្ជកម្មកម្ពុជា និងជាអ្នកបកប្រែជូនគណៈប្រតិភូបរទេស នៅពេលមានកិច្ចប្រជុំមួយចំនួន ។ ការស្តាប់សក្ខីកម្មរបស់លោក សគីម លុត មានរយៈពេលបីថ្ងៃ ដោយអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីនីមួយៗ សួរដេញដោលអំពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងការសួរដេញដោលនេះ ភាគីបានផ្តោតលើប្រវត្តិរូប និងការចូលរួមក្នុងបដិវត្តរបស់សាក្សី បញ្ហាទាក់ទងនឹងធនាគាពាណិជ្ជកម្ម ការងារជាអ្នកបកប្រែ ការជូនគណៈប្រតិភូបរទេសធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា និងការធ្វើជំនួញរវាងប្រទេសកម្ពុជា ជាមួយប្រទេសចិន ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

លោក សគីម លុត ហៅ មី កើតឆ្នាំ១៩៣១ នៅស្រុកឈូក ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៤២ ផ្លូវលេខ២៣៤ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ រ័ត្ន សគីម ម្តាយឈ្មោះ ញ៉ក់ សាគុន ។ លោក សគីម លុត មានប្រព័ន្ធឈ្មោះ អ៊ុក សាម៉ាល់ និងមាន កូនចំនួន៤នាក់ ។

មុនរបបកម្ពុជាប្រជាធិបតេយ្យ លោក សគីម លុត គឺជាសាស្ត្រាចារ្យម្នាក់ បន្ទាប់មកធ្វើការនៅ ខាងរទេះភ្លើង ។ ក្នុងអំឡុងឆ្នាំ១៩៦៣-១៩៦៤ បន្ទាប់ពីទទួលបានការហ្វឹកហ្វឺនរយៈពេល ៦ខែពាក់ព័ន្ធនឹងកិច្ចការធនាគា លោកត្រូវបានតែងតាំងជាប្រធានសាខាធនាគាប្រចាំនៅក្រុងព្រះសីហនុ ។ បន្ទាប់មកលោកត្រូវបានបញ្ជូនទៅប្រទេសបារាំងចំនួនបីខែ ដើម្បីទទួលការហ្វឹកហ្វឺនបន្ថែមនៅធនាគាប្រទេសបារាំង ។ ពេលត្រឡប់មកវិញ លោកត្រូវបានចាត់តាំងឲ្យទទួលបន្ទុកជាប្រធានផ្នែកឥណទានដោយស្ថិត នៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ថៅ សៅ ដែលធ្វើការនៅធនាគារជាតិ ។ លោក សគីម លុត បញ្ជាក់ថា លោកបានចូលរួមក្នុងចលនាបដិវត្តចាប់តាំងពីរបបសង្គមរាស្ត្រនិយមមកម្ល៉េះ ហើយក្នុងអំឡុងពេលនោះ លោកបានជួយឧបត្ថម្ភជាប្រាក់ខ្លះដល់ក្រុមខ្មែរក្រហមក្នុងការធ្វើបដិវត្ត ដើម្បីឲ្យប្រទេសមានការរីកចម្រើន និងបំបាត់អំពើពុករលួយ ។


សាក្សី សគីម លុត

នៅពេលទាហានខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាម លោក សគីម លុត ត្រូវបានជម្លៀស ទៅដល់ស្រុកកៀនស្វាយ ហើយលោកបានរស់នៅជាមួយបងប្អូននៅទីនោះ ។ ក្រោយមកលោកត្រូវបានបញ្ជូនមកសហករណ៍មួយទៀតដែលមានទីតាំងនៅខាងត្បូងទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧៦ លោកត្រូវបានគេបញ្ជូនមកទីក្រុងភ្នំពេញ ដើម្បីជួបពិភាក្សាជាមួយគណៈប្រតិភូចិនអំពីការបង្កើតធនាគាពាណិជ្ជកម្ម មួយដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ បន្ទាប់មកលោកត្រូវបានចាត់តាំងឲ្យធ្វើជាអគ្គនាយករងរបស់ធនាគានេះរហូតដល់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរំលំ ។

### ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

ក្នុងការសួរដេញដោលសាក្សី លោក វ៉េង ហ៊ិត ដែលជាតំណាងសហព្រះរាជអាជ្ញាជាតិ បានសួរផ្តោតលើអង្គហេតុមួយចំនួនទាក់ទងនឹងការចូលរួមក្នុងចលនាបដិវត្តរបស់សាក្សី ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការងាររបស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកលោក ថារីក អាប់ឌុលឡាក់ ដែលជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិវិញ លោកបានសួរបញ្ជាក់

បន្ថែមលើអង្គហេតុទាក់ទងនឹងការជម្លៀសប្រជាជន និងការងាររបស់សាក្សីនៅទីក្រុងភ្នំពេញ ។ បន្ទាប់មកលោក បានផ្ដោតសំខាន់លើអង្គហេតុទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅរបស់ធនាគារពាណិជ្ជកម្ម និងគណៈ កម្មាធិការពាណិជ្ជកម្ម ។

### ក) ការចូលរួមក្នុងចលនាធ្វើបដិវត្ត និង តួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ពាក់ព័ន្ធនឹងការធ្វើបដិវត្ត លោក សគឹម ល្មុត បញ្ជាក់ថា លោកបានចូលរួមក្នុងចលនាបដិវត្តក្នុងអំឡុងទសស្សន៍វត្តឆ្នាំ៥០ ក្នុងគោលបំណងកសាងប្រទេសឲ្យមានការរីកចម្រើន និងលុបបំបាត់អំពើពុករលួយនៅក្នុងសង្គមខ្មែរ ។ តាមរយៈការចូលរួមនេះ លោកបានផ្ដល់ជាប្រាក់ឧបត្ថម្ភមួយចំនួនដល់កម្មាភិបាលថ្នាក់ក្រោមរបស់ខ្មែរក្រហម ដើម្បីរៀបចំការប្រជុំផ្សេងៗនៅតាមមូលដ្ឋាន ។ បន្ទាប់ពីបញ្ជាក់ដូច្នេះ តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារជាសៀវភៅនិពន្ធដោយ ហ្វីលីព ស្សុត ដែលលោក បានសរសេរថា លោក សគឹម ល្មុត គឺជាអ្នកបម្រើការងារនៅរតនាគារ ហើយបានផ្ដល់ប្រាក់កម្ចីដល់ចលនាបដិវត្តរបស់ខ្មែរក្រហម ។ ភ្លាមៗនោះ លោក សគឹម ល្មុត បដិសេធចំពោះការលើកឡើងនេះ ដោយលោកបញ្ជាក់ថា «គឺរឿងនេះមិនពិតទេ មិនពិតទាល់តែសោះ ខ្ញុំអត់ទេបាទ ខ្ញុំមិនទទួល ស្គាល់ ។...ខ្ញុំ ថានេះគឺជាការគិតស្មានរបស់អ្នកនិពន្ធនេះទេ ។ ខ្ញុំមិនដែលធ្វើជាហិរញ្ញិកសម្ងាត់អីឲ្យចលនាខ្មែរក្រហម គឺ គ្មានដាច់ខាតក្រៅពីលុយកាក់បន្តិចបន្តួច ។ នេះគឺជាការសន្និដ្ឋានដោយគ្មានភស្តុតាងរបស់អ្នកនិពន្ធហ្នឹង» ។

ពាក់ព័ន្ធនឹងតំណាក់កាលតស៊ូបដិវត្តនេះដែរ សាក្សីបញ្ជាក់ថា លោកបានស្គាល់ ខៀវ សំផន និង អៀង សារី ក្នុងទសស្សន៍វត្តឆ្នាំ៦០ ។ ប៉ុន្តែលោកមិនដឹងថាអ្នកទាំងពីរធ្វើអ្វីឡើយក្នុងអំឡុងពេលតស៊ូបដិវត្ត ។ បន្ថែមលើនេះទៀត លោកស្គាល់លោក វ៉ាន់ រិទ្ធ តាំងពីមុនឆ្នាំ១៩៧៥ មកម្លេះ ដែលពេលនោះ លោក វ៉ាន់ រិទ្ធ បានរត់ចេញពីទីក្រុងភ្នំពេញទៅតំបន់រំដោះរបស់ខ្មែរក្រហម ដោយសារមានការតាមចាប់ខ្លួនរបស់កងទ័ព លន់ នល់ ។

ចំពោះតួនាទី និងភារកិច្ចរបស់លោក សគឹម ល្មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានបញ្ជាក់ថា លោកត្រូវបានចាត់តាំងឲ្យធ្វើជាអគ្គនាយករងនៃធនាគាពាណិជ្ជកម្មនៃកម្ពុជាដែលមានឈ្មោះ ម៉ី ចាន់ ឬ ម៉ី ខាន់ (សាក្សីចាំមិនច្បាស់) ជាអគ្គនាយក ។ ប៉ុន្តែលោកមិនដែលបានឃើញ ឬជួបផ្ទាល់ជាមួយអគ្គនាយករបស់ខ្លួនឡើយ ហើយធនាគារនេះមិនមានប្រតិបត្តិការអ្វីឡើយ ព្រោះគ្មានផ្នែករដ្ឋបាល ផ្នែកហិរញ្ញវត្ថុ ពោលគឺមានតែឈ្មោះតែប៉ុណ្ណោះ ។ តំណាងសហព្រះរាជអាជ្ញាជាតិបន្តសំណួររបស់ខ្លួនដោយចោទសួរថា «រវាងឋានៈរបស់ ឡឿន និងឋានៈរបស់លោក តើអ្នកណាបញ្ជាអ្នកណា?» ។ លោក សគឹម ល្មុត បញ្ជាក់ថា លោកមានឋានៈជាអគ្គនាយករងនៃធនាគារពាណិជ្ជកម្ម ចំណែក ឡឿន គឺជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម ដូច្នេះលោកត្រូវស្ដាប់បង្គាប់របស់ ឡឿន ។ លោកបានបញ្ជាក់បន្ថែម ទៀតថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជាមិនប្រើពាក្យ«ក្រសួង» ឡើយ គឺប្រើពាក្យ«គណៈកម្មាធិការ» ដែលពាក្យទាំងពីរនេះមានន័យដូចគ្នា ។ ឡឿន គឺជាប្រធានគណៈកម្មាធិការ ពាណិជ្ជកម្ម ចំណែក អន ជាប្រធានគណៈកម្មាធិការឧស្សាហកម្ម ដែលគណៈកម្មាធិការទាំងពីរនេះស្ថិត នៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការសេដ្ឋកិច្ចដែលដឹកនាំដោយ វ៉ន វេត និង ខៀវ សំផន ។ ក្នុងនាមជាអគ្គនាយករងធនាគារ លោកធ្លាប់បានចូលរួមប្រជុំជាមួយ អៀង សារី នៅពេលកិច្ចប្រជុំទាំងនោះពាក់ព័ន្ធនឹងផ្នែកសេដ្ឋកិច្ចការធ្វើពាណិជ្ជកម្ម ឬធនាគារ ។ បន្ថែមលើនេះទៀត លោកធ្លាប់បានចូលរួមកិច្ចប្រជុំរវាងគណៈកម្មាធិការពាណិជ្ជកម្ម និងគណៈប្រតិភូបរទេសមួយចំនួន ដូចជាគណៈប្រតិភូកូរ៉េ គណៈប្រតិភូមកពីប្រទេសយូហ្គោស្លាវី គណៈប្រតិភូចិនជាដើម ។ ពាក់ព័ន្ធនឹងការចូលរួមកិច្ចប្រជុំផ្សេងៗទៀត តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញឯកសារកំណត់ហេតុកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ ដើម្បីឲ្យសាក្សីបញ្ជាក់ពីសមាសភាពអ្នកចូលរួមកិច្ចប្រជុំទាំងនោះ ។ ឯកសារទី១គឺជា កំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ដែលមានបញ្ជាក់ពីសមាសភាពអ្នកចូលរួមប្រជុំ រួមមាន អៀង សារី និង ខៀវ សំផន ។ បន្ទាប់មកលោកសួរបញ្ជាក់ អំពីតួនាទីរបស់បុគ្គលទាំងពីរនេះ ។ មុននឹងឆ្លើយតបនឹងសំណួរនេះ លោក សគឹម ល្មុត បញ្ជាក់ថា លោកមិនដែលបានឃើញឯកសារនេះពីមុនឡើយ ហើយលោកក៏មិនដែលបានចូលរួមក្នុងកិច្ចប្រជុំនេះដែរ ។ ភ្លាមនោះ



ធនាគារជាតិនៃកម្ពុជាសម័យសង្គ្រាមរវាង លន់ នល់ និងខ្មែរក្រហម (ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ហ្សាស្តេី ជៅ ជាមេធាវីការពារក្ដីជនជាប់ចោទ នួន ជា លើកឡើងថា ក្នុងករណីសាក្សីមិនធ្លាប់ស្គាល់ឯកសារណាមួយ ឯកសារនោះគប្បីត្រូវដកចេញពីសាក្សី ។ ជាលទ្ធផលអង្គជំនុំជម្រះសម្រេចដកឯកសារនេះចេញពីសាក្សី ។ ជាការធ្វើកំណត់សម្គាល់តំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថា សាក្សីត្រូវបានបង្ហាញឯកសារនេះម្ដងរួចហើយនៅតំណាក់កាលផ្ដល់បទសម្ភាសន៍ជូនសហចៅក្រមស៊ើបអង្កេត ។ ប៉ុន្តែលោកនឹងគោរពចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដោយមិនសួរទាក់ទងនឹងឯកសារនេះឡើយ ។ គួររំឭកអំពីការលើកឡើងរបស់លោកមេធាវី ម៉ៃឃើល ខាណាវ៉ាស ដែលបានបញ្ជាក់ថា “...សាក្សីបានបញ្ជាក់រួចហើយថា គាត់មិនបានដឹងអំពីឯកសារនេះពីមុនមកនោះទេ ។ គាត់ទើបតែដឹង ឯកសារនេះជាលើកដំបូង ។ ដូច្នេះអ្នកស៊ើបអង្កេត គឺគាត់ព្យាយាមបង្កើតឲ្យសាក្សីមានការចងចាំ ដាស់ការចងចាំរបស់សាក្សី តើគាត់បានដឹងទេនៅពេលនោះ? និយាយដោយស្មោះត្រង់ទៅ គឺខ្ញុំគិតថា មិនអាចយកឯកសារដែលមានបញ្ជីឈ្មោះមនុស្សមកបង្ហាញទេ ។ ប៉ុន្តែយើងអាចសួរសាក្សីនេះថា ក្រោយពីបានឃើញឯកសារនេះ តើគាត់ដឹងអ្វីខ្លះដែរ? អាចចងចាំអ្វីខ្លះដែរ យោងទៅលើអង្គហេតុទាំងឡាយដែលគាត់នឹងអាចចងចាំពីពេលនោះមក ។ មិនមែនត្រូវបង្កើតការចងចាំក្រោយពីការបង្ហាញឯកសារនេះនោះទេ» ។ ឯកសារទី២ គឺជាសេចក្ដីសង្ខេបនៃកំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ ។ ឯកសារនេះនិយាយអំពីការរៀបចំគណៈកម្មាធិការមួយចំនួននៅជុំវិញមន្ទីរ

៨៧០ និងការចាត់តាំងគណៈប្រតិភូមួយដែលមានសមាសភាព ដូចជា ឌឿន, គ្រិន, សាយ, ឈឿន, ហុក, ល្មុត ដើម្បីទទួល និងចរចាជាមួយគណៈប្រតិភូពាណិជ្ជកម្មចិន ។ លោក សគីម ល្មុត បញ្ជាក់ថា លោកមិនដែលបានចូលរួមប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ឡើយ ដូច្នេះលោកមិនបានដឹងអំពីការសម្រេចរបស់គណៈកម្មាធិការនេះដែរ ។

### ខ) អំពីការជម្លៀសប្រជាជន

ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោក សគីម ល្មុត បញ្ជាក់ជូនតំណាងសហព្រះរាជអាជ្ញាថា នៅពេលរសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញចំនួន២ ទៅ ៣ ថ្ងៃ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ លោកត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែង និងទ្រព្យសម្បត្តិដែលខ្លួនមាន ដោយយកបានតែសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនមួយចំនួនប៉ុណ្ណោះ ។ នៅពេលធ្វើដំណើរដល់រង្វង់មូលក្បាលថ្នល់ ទោះបីជា លោកមានបំណងធ្វើដំណើរទៅស្រុកឈូក(ក្នុងខេត្តកំពត) ដែលជាស្រុកកំណើតរបស់លោកក្តី ប៉ុន្តែលោក ត្រូវបានក្រុមទាហានខ្មែរក្រហមបង្ខំឲ្យធ្វើដំណើរតាមផ្លូវជាតិលេខ១ រហូតទៅដល់ស្រុកគៀនស្វាយ ។ លោក សគីម ល្មុត បញ្ជាក់ទៀតថា ប្រជាជនត្រូវបានទាហានខ្មែរក្រហមជម្លៀសទៅដល់គៀនស្វាយ ដោយរស់នៅកកកុញនៅទីនោះ ដែលម្នាក់ៗមិនដឹងថាខ្លួននឹងបន្តដំណើរទៅទីណាទៀតឡើយ ។ ទោះបីនៅទីនោះមានប្រជាជនរស់នៅដូច្នេះក្តី ប៉ុន្តែខ្មែរក្រហមមិនបានរៀបចំឲ្យមានមន្ទីរពេទ្យ ឬទីជម្រកសម្រាប់ប្រជាជនឡើយ ។ ចំណែករូបលោកផ្ទាល់គឺត្រូវបានទាហានខ្មែរក្រហមអនុញ្ញាតឲ្យទៅរស់នៅជាមួយបងប្អូននៅស្រុកគៀនស្វាយ ។ បន្ទាប់ពីរស់នៅស្រុកកៀនស្វាយបានមួយរយៈ លោកត្រូវបានបញ្ជូនបន្តឲ្យទៅរស់នៅសហករណ៍មួយដែលមានទីតាំងនៅខាងត្បូងទីក្រុងភ្នំពេញ ។ ពេលទៅដល់ភ្លាម លោក និងប្រជាជនផ្សេងៗទៀតដែលរស់នៅក្នុងសហករណ៍នោះ ត្រូវបានតម្រូវឲ្យធ្វើប្រវត្តិរូបផ្ទាល់ខ្លួនដើម្បីផ្តល់ជូនប្រធានសហករណ៍ ។ ប្រវត្តិរូបនេះត្រូវបញ្ជាក់អំពី ឈ្មោះ ប្រវត្តិសិក្សារៀនសូត្រ ការងារ និងតួនាទីដែលខ្លួនធ្លាប់ធ្វើនៅក្នុងរបបមុន ។ ប្រជាជនត្រូវបានគេប្រាប់ឲ្យយកទ្រព្យសម្បត្តិទៅដាក់ក្នុង សហករណ៍ទាំងអស់គ្នា ។

គួររំពឹកថា នៅពេលដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិសួរអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោក ម៉ៃឃើល ខារណាវ៉ាស ជាមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងថា អង្គហេតុទាក់ទងនឹងការជម្លៀសប្រជាជនត្រូវបានតំណាងសហព្រះរាជអាជ្ញាជាតិសួររម្លងរួចហើយ ។ ដូច្នេះតំណាងសហព្រះរាជអាជ្ញាអន្តរជាតិកំពុងសួរសំណួរទៅសាក្សីលើអង្គហេតុច្រំដែល ។ លោកមេធាវីកត់សម្គាល់បន្ថែមថា អង្គជំនុំជម្រះទំនងជាអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាចោទសំណួរច្រំដែលទៅសាក្សី ។ ជាការឆ្លើយតប លោក តារីក លើកឡើងថា លោកគ្រាន់តែសួរបញ្ជាក់លើ ចំណុចជាក់លាក់មួយចំនួនដើម្បីឲ្យមានភាពច្បាស់លាស់តែប៉ុណ្ណោះ ។ ជាលទ្ធផល អង្គជំនុំជម្រះសម្រេចបដិសេធចំពោះការជំទាស់របស់លោក ខារណាវ៉ាស ដោយផ្តល់សំអាងហេតុថា ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន តំណាងសហព្រះរាជអាជ្ញាជាតិគ្រាន់តែសួរសំណួរទូទៅតែប៉ុណ្ណោះ ដូច្នេះតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាចសួរសំណួរជាក់លាក់ដើម្បីឲ្យសាក្សីបញ្ជាក់បន្ថែមបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបញ្ជាក់ជូនតំណាងសហព្រះរាជអាជ្ញា និងភាគីផ្សេងៗទៀតថា ក្នុងករណីមានការបែងចែកអង្គហេតុគ្នាដើម្បីសួរសាក្សី គឺគប្បីសួរអង្គហេតុនោះឲ្យបានលម្អិតចៀសវាងការសួរលើអង្គហេតុនោះបន្ថែមដែលនាំឲ្យកើតមានសំណួរច្រំដែល ។

### គ) អំពីគណៈកម្មាធិការពាណិជ្ជកម្ម :

ទាក់ទងនឹងគណៈកម្មាធិការពាណិជ្ជកម្ម លោក សគីម ល្មុត បញ្ជាក់ថា នៅឆ្នាំ១៩៧៦ គណៈកម្មាធិការពាណិជ្ជកម្មមានទីតាំងនៅជិតផ្សារចាស់ ហើយត្រូវបានដឹកនាំដោយ ឌឿន ដែលមានឋានៈជាប្រធាន ។ ក្រោយមក គណៈកម្មាធិការនេះ បានប្តូរទីតាំងមកកន្លែងមួយផ្សេងទៀត(ទីតាំងក្រសួងការពារជាតិបច្ចុប្បន្ន) ដឹកនាំដោយ វ៉ាន់ រិទ្ធ បន្ទាប់ពី ឌឿន ត្រូវបានចាប់ខ្លួន ។ គណៈកម្មាធិការពាណិជ្ជកម្មមានបុគ្គលិកបម្រើការងារប្រហែល២០ នាក់ ហើយត្រូវបានបែងចែកជាពីរផ្នែក គឺផ្នែកទទួលកិច្ចការក្នុងប្រទេស និងផ្នែកទទួលកិច្ចការក្រៅប្រទេស ។ គណៈកម្មាធិការនេះមានភារកិច្ចកំណត់មុខទំនិញដែលត្រូវនាំចូលប្រទេសកម្ពុជា និងទំនិញដែលត្រូវនាំចេញទៅលក់នៅក្រៅប្រទេស ។ ទំនិញដែលត្រូវនាំទៅលក់នៅក្រៅ

ប្រទេស រួមមាន ស្រូវ ពោត សណ្តែក ម្រេច កាហ្វេជាដើម ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាសួរថា តើរាល់ការនាំទំនិញចេញចូលប្រទេសកម្ពុជា ត្រូវឆ្លងកាត់ធនាគារពាណិជ្ជកម្មដែរឬទេ? ហើយធនាគារនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការ ពាណិជ្ជកម្មដែរឬយ៉ាងណា? លោក សគីម ល្មុត បញ្ជាក់ជូនអង្គជំនុំជម្រះថា ការនាំទំនិញចេញ ឬចូលប្រទេសកម្ពុជា គឺមិនមានការឆ្លងកាត់ធនាគារពាណិជ្ជកម្មឡើយ ហើយធនាគារនេះក៏មិនស្ថិតនៅក្រោមការ គ្រប់គ្រងរបស់គណៈកម្មាធិការពាណិជ្ជកម្មដែរ ។ បន្ទាប់ពីសាក្សីបញ្ជាក់ដូច្នេះ តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារដែលសាក្សីធ្លាប់បានផ្តល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា *«ពេលមកដល់ទីក្រុងភ្នំពេញ ខ្ញុំត្រូវបានចាត់តាំងឲ្យជួបប្រជុំជាមួយគណៈប្រតិភូចិនដើម្បីពិភាក្សាអំពីការធ្វើពាណិជ្ជកម្ម ។ ចិនបានផ្តល់ទឹកប្រាក់ចំនួន ១៤៨លានដើម្បីបង្កើតធនាគារសម្រួលដល់ការធ្វើពាណិជ្ជកម្មនេះ ។ ធានាគារនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការពាណិជ្ជកម្ម»* ។ លោក សគីម ល្មុត បាន ទទួលស្គាល់នូវចម្លើយនេះ ប៉ុន្តែលោកបញ្ជាក់បន្ថែមថា លោកមិនសូវចាំច្បាស់អំពីចំនួនទឹកប្រាក់ដែលចិនបានផ្តល់ជូនឡើយ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារមួយទៀតជូនសាក្សីពិនិត្យចំណាររបស់លោក វ៉ាន់ រិទ្ធ ។ ឯកសារនេះគឺជារបាយការណ៍ដែលលោក វ៉ាន់ រិទ្ធ បានផ្ញើជូនលោក សគីម ល្មុត ដោយរាយការណ៍អំពីទំនិញដែលបាននាំចេញទៅលក់នៅក្រៅប្រទេស ហើយមានចំណារបញ្ជាក់ថា *« បានផ្ញើជូនបង វ៉ន និងបង ហែម រួចហើយ»* ។ លោក សគីម ល្មុត បញ្ជាក់ថា «បងវ៉ន» គឺជាឈ្មោះរបស់ វ៉ន វេត ចំណែក «បងហែម» គឺសំដៅលើ ខៀវ សំផន ហើយចំណារនេះពិតជា ចំណាររបស់លោក វ៉ាន់ រិទ្ធ ។ បន្ថែមលើនេះទៀត តំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារចំនួនពីរទៀត ដើម្បីឲ្យសាក្សីពិនិត្យចំណាររបស់លោក វ៉ាន់ រិទ្ធ ។ ឯកសារទី១គឺជារបាយការណ៍ដែលក្រសួងពាណិជ្ជកម្មរាយការណ៍ជូនថ្នាក់លើរបស់ខ្លួនរួមមាន វ៉ន វេត និង ខៀវ សំផន និងបង៩១ (សាក្សីមិនចាំឈ្មោះបង៩១) ស្តីពីការជួបប្រជុំជាមួយគណៈប្រតិភូកូរ៉េ ។ ចំពោះឯកសារទី២ គឺជារបាយការណ៍ដែលគណៈកម្មាធិការពាណិជ្ជកម្មរាយការណ៍ឲ្យ វ៉ន វេត និង ខៀវ សំផន អំពីកិច្ចប្រជុំជាមួយគណៈប្រតិភូមកពីប្រទេសយ៉ូហ្គោស្លាវី ស្តីពីការកំណត់មុខទំនិញដូចជា អង្ករ និងកាហ្វេ ដែលត្រូវ យកទៅលក់នៅ


អាប់ឌុលហាក់ ថារីក

ប្រទេសយ៉ូហ្គោស្លាវី ។ បន្ទាប់ពីបានពិនិត្យរបាយការណ៍ទាំងពីរនេះ លោក សគីម ល្មុត បញ្ជាក់ថា របាយការណ៍ទាំងនេះគឺស្របគ្នានិងស៊ីសង្វាក់ទៅនឹងខ្លឹមសារដែលលោកបានជួបប្រជុំជាមួយគណៈប្រតិភូកូរ៉េ និងគណៈប្រតិភូយ៉ូហ្គោស្លាវី ។ ដូច្នេះចំណារដែលមាននៅក្នុងឯកសារទាំងនេះគឺពិតជាចំណាររបស់ វ៉ាន់ រិទ្ធ ដែលបានរាយការណ៍ឲ្យ វ៉ន វេត និង ខៀវ សំផន ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាចោទសួរថា ហេតុអ្វីកិច្ចប្រជុំទាំងនេះចាំបាច់ត្រូវរាយការណ៍ឲ្យ វ៉ន វេត និង ខៀវ សំផន? ជាការឆ្លើយតប លោក សគីម ល្មុត បញ្ជាក់យ៉ាងច្បាស់ថា គណៈកម្មាធិការពាណិជ្ជកម្មត្រូវរាយការណ៍ ជូនគណៈកម្មាធិការសេដ្ឋកិច្ចដែលជាថ្នាក់លើរបស់ខ្លួន ពោលគឺត្រូវរាយការណ៍ឲ្យ វ៉ន វេត និង ខៀវ សំផន ។ ចុងក្រោយតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថា លោកមានឯកសាររបាយការណ៍ប្រជុំជាង២០ ទៀតដែលសាក្សី បានចូលរួមក្នុងកិច្ចប្រជុំទាំងនោះហើយ បានរាយការណ៍ឲ្យ ខៀវ សំផន ។

បន្ទាប់ពីបញ្ចប់សំណួរពាក់ព័ន្ធនឹងការពិនិត្យចំណាររបស់លោក វ៉ាន់ រិទ្ធ ដែលបានរាយការណ៍ឲ្យ វ៉ន វេត និង ខៀវ សំផន

តំណាងសហសហព្រះរាជអាជ្ញាបានបន្តសំណួរពាក់ព័ន្ធនឹងក្រុមហ៊ុន រ៉ែនហុង ដែលត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើពាណិជ្ជកម្មក្រៅប្រទេស ។ លោក សគឹម ល្មុត បញ្ជាក់ថា ក្រុមហ៊ុនរ៉ែនហុង មានទីតាំងនៅទីក្រុងហុងកុងប្រទេសចិន ដែលត្រូវបានបង្កើតឡើង ដើម្បីធ្វើពាណិជ្ជកម្មជាមួយប្រទេសលោកសេរី ។ ក្រុមហ៊ុននេះមានភាគហ៊ុនរបស់ សុខ និង ណាត ហើយដែលភាគហ៊ុនទាំងនេះត្រូវបានផ្ទេរមកឲ្យ គ្រិន កាន់កាប់ជំនួសបន្ទាប់ពីអ្នកទាំងពីរត្រូវបានគណៈកម្មាធិការពាណិជ្ជកម្មបញ្ជាឲ្យវិលចូលស្រុកខ្មែរវិញ ។ បន្ថែមលើនេះ តំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារជាលិខិតមួយ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ដែលបានធ្វើដោយគណៈកម្មាធិការពាណិជ្ជកម្មស្តីពីការចាត់តាំង គ្រិន ឲ្យទទួលភារកិច្ចជំនួស សុខ និង ណាត នៅក្រុមហ៊ុន រ៉ែនហុង ដើម្បីឲ្យអ្នកទាំងពីរវិលមកប្រទេសកម្ពុជាវិញ ។ បន្ទាប់ពីបង្ហាញឯកសារ តំណាងសហព្រះរាជអាជ្ញា សួរសាក្សីថា តើមាន អ្វីកើតឡើងចំពោះ ណាត និង សុខ នៅពេលអ្នកទាំងពីរវិលមកប្រទេសកម្ពុជាវិញ? ជាការឆ្លើយតប លោក សគឹម ល្មុត បញ្ជាក់ថា លោកមិនដឹងអំពីបញ្ហានេះឡើយ ព្រោះវាជាសេចក្តីសម្រេចរបស់គណៈកម្មាធិការពាណិជ្ជកម្ម ។

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តសំណួរអំពីទំនាក់ទំនងរវាង អន ជាមួយ ខៀវ សំផន និង វ៉ាន់ រ៉េត ។ ប៉ុន្តែសាក្សីបានឆ្លើយថាខ្លួនមិនដឹងពីទំនាក់ទំនងនេះទេ ដោយខ្លួនបានមកស្នាក់នៅជិតក្រសួងឧស្សាហកម្មមួយរយៈខ្លីប៉ុណ្ណោះ ។ លោក ថារីក បានសួរថាតើអ្នកណាជាប្រធានធំនៅក្រសួង ឧស្សាហកម្ម វ៉ាន់ រ៉េត ឬខៀវ សំផន? សាក្សីបានឆ្លើយថា ខ្លួនមិនដឹងទេ ព្រោះពេលដែលលោកមកដល់ក្រសួងនេះ គឺគេមិនបានបញ្ជាក់ពីរចនាសម្ព័ន្ធនោះទេ ។ ការណ៍ដែលលោកដឹងគឺនៅពេលក្រោយមកទេ គឺតាមចៅក្រមស៊ើបអង្កេត ដែលលោកដឹងថាមានឈ្មោះ ខឿន និងវ៉ាន់រិទ្ធ ។ លោកតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារទៅសាក្សី A-៣៨ និងលើអេក្រង់ទូរទស្សន៍ ។ លោកបានអានអត្ថបទសម្រង់«នៅពេលដែលខ្ញុំចូលធ្វើការនៅទីនោះ គឺ អន ជាប្រធានក្រសួង ។ បើតាមខ្ញុំស្មានគឺឈ្មោះ ហែម ជាអ្នកមើលពីលើទៀត ប៉ុន្តែគាត់មិនបង្ហាញមុខទេ ។ ប្រហែលជាលោក ហែម នៅក្នុងគណៈកម្មា ធិការសេដ្ឋកិច្ចខាងលើ ហើយគាត់ជាអ្នកគ្រប់គ្រងនៅទីនោះឯង» ។ សាក្សីបានយល់ស្របតាមអ្វីដែលសហព្រះរាជអាជ្ញាបានអាន ហើយថាលោកបានឆ្លើយបែបនោះមែន ប៉ុន្តែដោយសារលោកបានឃើញឯកសារមួយចំនួនទើបលោកឆ្លើយដូច្នេះ ។លោកថារីកបានសួរពីការផ្តល់មតិយោបល់ដែលលោកល្មុតបានធ្វើ ។លោកព្រះរាជអាជ្ញាបានលើកបញ្ចឹឯកសារចំនួន៦ដែលបាននិយាយពីកំណត់ហេតុទីផ្សារក្នុងកំឡុង ខែមករានិងតុលា ឆ្នាំ១៩៧៨ ។ លោក សគឹម ល្មុត



បានឆ្លើយថា លោកបានធ្វើការពាក់ព័ន្ធនឹងក្រសួងពាណិជ្ជកម្មនោះ មានច្រើនណាស់ហើយដែលមានចុះហត្ថលេខានោះលោកចុះលើ ឯកសារដែលលោកប្រាកដថាបានអានមែន ហើយមិនមែនមាន ន័យថាលោកបានដឹងគ្រប់រឿងនៅរបបនោះឡើយ ។ សាក្សីមិន បានជ្រាបពីដំណើររបស់ វ៉ន វេត នៅក្រសួងឧស្សាហកម្មនោះទេ បើទោះជាលោក នៅក្នុងក្រសួងនោះរហូតដល់ចប់ក៏ដោយ ។ សាក្សីបានឮថាគេដកហូត លោក វ៉ន វេត តែលោកមិនហ៊ាន សួរទៅ វ៉ាន់រិទ្ធ ឡើយ ។ លោកព្រះរាជអាជ្ញាបានបន្តសួរ និងបង្ហាញ ឯកសារដែលចៅក្រមស៊ើបបានសួរទាក់ទងនឹងការប្រជុំថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ ។ ឯកសារនិយាយពីការប្រជុំរវាង អៀង សារី និងគណៈប្រតិភូចិន ហើយមានវត្តមានរបស់លោក សរគឹម លុត, សេង ទុំ និង អន ។ សាក្សីបានទទួល ស្គាល់ថាពិតជាមានការប្រជុំមែន តែលោកមិនចាំទេ ហើយលោកមានការភ្ញាក់ផ្អើលដែរ ដែល អៀង សារី នៅខាងក្រសួងការបរទេស តែមកចូលរួមប្រជុំជាមួយភ្ញៀវ



ក្រុមអ្នកជំនាញការខ្មែរក្រហមនៅក្នុងកំពង់ផែកំពង់សោម (ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្រសួងឧស្សាហកម្មនោះទៅវិញ ។ លោកមិនភ្ញាក់ផ្អើលអ្វីទេ លោកគ្រាន់តែឆ្ងល់នៅក្នុងចិត្តថាហេតុអ្វីបានជា អៀង សារី មកប្រជុំជាមួយក្រសួងឧស្សាហកម្ម ហើយបាននិយាយពីបញ្ហាទាក់ទងនឹងក្រសួងនេះទៀត ហើយកិច្ចប្រជុំនោះមានលក្ខណៈសំខាន់ដោយសារតែមានគណៈប្រតិភូពីប្រទេសចិនបានចូលរួមជាមួយដែរ ។

## ៣) សក្ខីកម្មរបស់សាក្សីចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រី ស៊ីន សុវ៉ាន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសំណួររបស់ខ្លួន ដោយសួរឡើងវិញអំពីការចូលរួមរបស់សាក្សីក្នុងចលនាតស៊ូ នៅក្នុងសម័យសង្គមរាស្ត្រនិយម ។ ភ្លាមៗ លោក ខាណាវ៉ាស ជាមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានក្រោកឈររួចលើកឡើងថា សំណួរគួរតែចាប់ផ្តើមពីអ្វីដែលសហព្រះរាជអាជ្ញាមិនទាន់បានសួរ ។ លោកចៅក្រមធ្វើការរំឭកដល់លោកស្រីមេធាវីពីការប្រើប្រាស់ពេលវេលាឲ្យមានអត្ថប្រយោជន៍ ។ បន្ទាប់មកលោកស្រីបានសួរអំពីអ្នកមកខ្ចីប្រាក់នៅធនាគារ ប៉ុន្តែសំណួរនេះមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយឡើយ ។ លោកស្រីបានបន្តសំណួថា តើលោកសាក្សីយល់យ៉ាងណាចំពោះការឧបត្ថមប្រាក់ក្នុងបដិវត្ត ។ លោកសាក្សីបានឆ្លើយតបថា នេះគឺជារឿងតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ដែលគេអន្ទៀសលុយបន្តិចបន្តួចមិនមានអីចម្លែកទេ គឺធ្វើតាំងពីមុនឆ្នាំ១៩៧៥ម៉្លេះ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះអំពីប្រភេទរូបិយប័ណ្ណដែលប្រើសម្រាប់ទូទាត់ជាមួយប្រទេសចិន គឺលុយយ័ន ហើយចំពោះប្រទេសផ្សេងទៀត គឺប្រើប្រភេទលុយផ្សេង ។

ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ថា លោកស្គាល់ ឌឿន ជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម តែលោកមិនដឹងថា ឌឿន ធ្វើការនៅ៨៧០ ទេសូម្បីឈ្មោះ៨៧០ ក៏មិនធ្លាប់ឮដែរ ។ ចំណែក វ៉ន វេត លោកជួបបានតែម្តងប៉ុណ្ណោះនៅឆ្នាំប្រហែលដើមឆ្នាំ១៩៧៦ ។ លោកស្រីមេធាវី បានបន្តសំណួរថា លោកធ្លាប់ធ្វើការនៅស៊ីសុវត្ថិតើលោកស្គាល់ អៀង សារី ខៀវ ធីរិទ្ធទេ? សាក្សីបានឆ្លើយតបថាលោកស្គាល់បុគ្គលទាំងពីរតាំងពីនៅមុនពេលធ្វើការនៅទីនោះទៅទៀត ។ សាក្សីធ្លាប់បម្រើការជានាយករងធនាគារពាណិជ្ជកម្មក្រៅប្រទេស រាល់ការងារនោះលោកធ្វើដោយមិនមានបញ្ជាផ្ទាល់ពីនរណាទេ គឺតាមនិរសារពីមន្ទីរកណ្តាលមួយ ។ ការងារស្នូលនៅធនាគារ គឺប្រតិបត្តិការរវាងខ្មែរ និងបរទេស ប៉ុន្តែមានតែពីរនាក់ប៉ុណ្ណោះ មិនមានគណនេយ្យនោះទេ គឺមានតែឈ្មោះប៉ុណ្ណោះ ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ណេគ្គី បានបញ្ចេញនូវភាពសប្បាយរីករាយចំពោះលទ្ធភាព របស់សាក្សីដែលអាចស្តាប់ភាសាបារាំងបាន ។ ឆ្លើយតបនឹងសំណួរ សាក្សីបានបញ្ជាក់ថាលោកមិនបានទទួលបញ្ជីដែលរាយការណ៍ពីស្រូវអង្ករដែលនាំចេញទេ លោកទើបតែឃើញបញ្ជីនេះនៅថ្ងៃនេះប៉ុណ្ណោះ ។ សាក្សីបានបន្តទៀតថា នៅពេលដែលលោកធ្វើជាអ្នកបកប្រែជូនគណៈប្រតិភូទៅទស្សនានៅតាមសហករណ៍ លោកមិនបានឃើញមានការធ្លាក់ចុះនូវការហូបចុកអីទេ ដោយសារសហករណ៍នោះមានលក្ខណៈពិសេស ព្រោះមានកន្លែងអាចរកម្ហូបអាហារបាន ។ លោកមេធាវី ណេគ្គី បានធ្វើការរំឭកដល់សាក្សីអំពីឈ្មោះ ផន និង សួន សាក្សីបានបញ្ជាក់ថា ប្រហែលជាកម្មាភិបាលថ្នាក់មធ្យម ឬថ្នាក់កណ្តាល ឬផ្នែកបច្ចេកទេសមកពីក្រសួងពាណិជ្ជកម្ម ហើយលោកបានប្រៀបធៀបតំណែងរបស់អ្នកទាំងពីរនោះថា បើនៅក្នុងពេលបច្ចុប្បន្នគឺប្រហែលនឹងថ្នាក់ការិយាល័យ ។

មុនពេលលោកចេញដំណើរពីភ្នំពេញនៅឆ្នាំ១៩៧៦ សាក្សីមិនបាននៅជាមួយ អន ឡើយ ហើយលោកក៏មិនដឹងថាវាសនារបស់ អន យ៉ាងណានោះដែរ ។ លោកមិនធ្លាប់ដឹងថាអ្នកនៅក្រសួងនោះមាន ការបាត់ខ្លួននិងបញ្ជាបញ្ជូនឈ្មោះទៅស-២១ ឡើយ គឺលោកទើបតែដឹងនៅក្នុងសវនាការនេះប៉ុណ្ណោះ ។ នៅក្នុងក្រសួងពាណិជ្ជកម្ម សាក្សីបានជួយបង្ហាញពីបែបបទធ្វើបញ្ជីប៉ុន្តែពេលទំនិញ នាំចេញ-ចូល នោះ លោកមិនបានដឹងទេ ។ សាក្សីបានជម្រាបថា ការបំពេញការងារជាអ្នកបកប្រែជូនគណៈប្រតិភូសេដ្ឋកិច្ចពាណិជ្ជកម្មនោះលោកបានស្គាល់ឈ្មោះ គ្រិន ដែលជាប្រធានដៃនៅកំពង់សោម ។ ឆ្លើយតបនឹងសំណួរអំពីឈ្មោះនេះ សាក្សីបានផ្តល់ចម្លើយថាលោកចាំថាគេបញ្ជូនលោក គ្រិន ទៅហុងកុង ដោយក្រសួងពាណិជ្ជកម្ម ប៉ុន្តែត្រង់ចំណុចថាបញ្ជូនទៅ

ដើម្បីជំនួសឈ្មោះ សុខ នោះសាក្សីមិនជ្រាបទេ ។ សាក្សីក៏បានបញ្ជាក់ពីកម្រិតស្គាល់គ្នារវាងលោកជាមួយលោក និង វ៉ាន់ រិទ្ធ ដែលជាសិស្សរបស់លោកពេលសាក្សីធ្វើការនៅសាលាស៊ីសុវត្ថិ ។ លោកថាលោកមិនមាននិយាយឆ្លើយឆ្លងគ្នាអំពីគណៈកម្មាធិការពាណិជ្ជកម្មអីទេ បើទោះជាធ្លាប់ស្គាល់លោក រិទ្ធ ពីមុនមកក៏ដោយ ។

## ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្ដី

នៅពេលចាប់ផ្ដើមសវនាការនាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន មុនគេដើម្បីសួរសាក្សី សគីម លុត ។ លោកមេធាវីជាតិ គង់ សំអុន បានចាប់ផ្ដើមសំណួរទាក់ទងនឹងការផ្ដល់ជំនួយដល់ចលនាបដិវត្ត ។ សាក្សីបានឆ្លើយថា ក្រៅពីជំនួយជាថវិកា លោកមិនមានជួយជាកម្លាំងកាយ និងចិត្តទេ ។ ឆ្លើយតបនឹងសំណួរ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថាខ្លួនធ្លាប់ជួប ខៀវ សំផន នៅមុនឆ្នាំ១៩៧៥ ដោយសារគាត់ជាសភាតំណាងប្រជាជន តែមិនធ្លាប់ជួបផ្ទាល់ ។ មុនឆ្នាំ១៩៧៨ លោកបានជួបគាត់មិនមែនក្នុងកិច្ចការរាជការទេ គឺជួបដោយចៃដន្យ ប៉ុណ្ណោះនៅកន្លែងខ្លះក្នុងទីក្រុងភ្នំពេញ ។ លោកសាក្សីធ្លាប់ឮពាក្យសមានជន ហើយលោកក៏ស្ថិតនៅក្នុងប្រភេទសមានជននេះដែរ ។ លោកសាក្សីបានពន្យល់ថាសមានជននៅមុនឆ្នាំ១៩៧៥ គឺជាជនដែលមានចិត្តជួយបដិវត្ត ប៉ុន្តែមិនសកម្មទេ ។

ទាក់ទងនឹងការជម្លៀសលោកសាក្សីបានចាកចេញពីភ្នំពេញជាមួយគេឯងក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ ក្រោយមកប្រធានសហករណ៍ឲ្យលោកត្រលប់មកភ្នំពេញវិញ តែគេមិនប្រាប់មុនថាមកទីណាទេ ។ គេបានឌុបលោកដឹកតាមម៉ូតូមកមន្ទីរឧស្សាហកម្មជាមួយអនុប្រធានសហករណ៍ ។ ពេលមកដល់ភ្លាមលោកបានជួបប្រធានក្រសួងឧស្សាហកម្ម គឺលោកអន ។ អន បានប្រាប់ឲ្យលោកនៅចាំនៅទីនោះសិន ចាំថ្នាក់លើមកប្រាប់ ។ មិនយូរប៉ុន្មាន អ្នកដែលមកជួបលោកនោះគឺលោក វ៉ន វេត ដែលលោកគិតថា វ៉ន វេត មានឋានៈធំជាងលោក អន ។ ពេលនោះ គេប្រាប់ឲ្យទៅចូលប្រជុំជាមួយគណៈប្រតិភូ ដោយត្រៀមខោអាវ និងរៀបចំខ្លួន ។ លោកមេធាវីបានសួរថាតើមូលហេតុអ្វីបានជា វ៉ន វេត ដឹងពីសមាសភាពលោកពីរឿងបេះខាងធនាគារ សាក្សីបានឆ្លើយថាលោកមិនដឹងទេថា វ៉ន វេត ដឹងរឿងនេះពីណា ប៉ុន្តែមានមនុស្សច្រើនណាស់ដែលដឹងពីសមត្ថភាពរបស់លោក ។ ទាក់ទងនឹងឈ្មោះ វ៉ាន់ រិទ្ធ សាក្សីបានបំភ្លឺថាខ្លួនបានជួបនៅពេលក្រោយមក គឺពេលដែលជួបជាមួយ ឌឿន ប្រជុំជាមួយគណៈប្រតិភូ ។ សាក្សីធ្លាប់បានណែនាំការងារធនាគារទៅកម្មាភិបាលខ្មែរក្រហម គឺជួយពន្យល់ជាទ្រឹស្ដី នៅពេលគណៈប្រតិភូចិនពន្យល់ ហើយអ្នកទាំងនោះស្ដាប់មិនយល់ លោកក៏បានពន្យល់នៅកន្លែងណាដែលគេសួរទាក់ទងនឹងទ្រឹស្ដីទូទៅដែលគេប្រើប្រាស់លើសកលលោកប៉ុណ្ណោះ មិនមែនបើកវគ្គសិក្សាទេ ។ សាក្សីក៏បានបញ្ជាក់ដែរថា លោកមិនធ្លាប់មានផែនការ ឬគោលការណ៍ស្នើដើម្បីឲ្យធនាគារមានការរីកចម្រើនអីទេ ។

បន្ទាប់ពីមេធាវីជាតិបានសួរចប់ លោក អាកទូ វែកគែន មេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន បានចាប់ផ្ដើមសំណួរដោយចោទសួរសាក្សីថា តើលោកធ្លាប់ចាត់ទុកថាលោក ហែម ជាថ្នាក់លើរបស់លោកទេ? សាក្សីបានឆ្លើយតបថា លោកមិនដែលចាត់ទុកជាផ្លូវការទេ គឺគ្រាន់តែគិតក្នុងចិត្តប៉ុណ្ណោះ ប៉ុន្តែជាក់ស្ដែងមិនមែនទេ ។ បន្ទាប់មកលោកមេធាវីបានសួរថា តើលោក ខៀវ សំផន មានតំណែងអ្វីនៅរបបខ្មែរក្រហម? សាក្សីបានឆ្លើយថា ខៀវ សំផន ប្រហែលជានាយករដ្ឋមន្ត្រីនៅពេលនោះ ។ សាក្សីបានផ្ដល់ភាពច្បាស់លាស់ជូនអង្គជំនុំជម្រះថា លោកមិនមែនគិតស្រមៃថា ខៀវ សំផន ជានាយករដ្ឋមន្ត្រីទេ គឺនៅពេលនោះមានការប្រកាសជាផ្លូវការ ប្រកាសជាអន្តរជាតិថាគាត់ជានាយករដ្ឋមន្ត្រី តែត្រង់ថាជាថ្នាក់លើរបស់លោកនោះ គឺការងារផ្ទាល់ជាមួយលោកនោះគឺមិនដឹងទេ ព្រោះ ខៀវ សំផន មិនដែលចុះមកបញ្ជាលោកអំពីកិច្ចការធនាគារនោះដែរ ។ សាក្សីបានបន្ត ទៀតថាលោកមិនស្គាល់អក្សរនិងហត្ថលេខារបស់លោក ខៀវ សំផន ទេ ។

## ៤.១) ការសួរដេញដោលដោយក្រុមមេធាវី នួន ជា

លោក សុន អរុណ ជាមេធាវីការពារក្ដី នួន ជា បានធ្វើការសួរដេញដោលសាក្សី ដោយផ្ដោតលើប្រវត្តិនៃការចូលបដិវត្តនៅសម័យសង្គមរាស្ត្រនិយម ។ បើទោះជាសាក្សីមិនចាំឆ្នាំដែលលោកបានចូលរួមនៅក្នុងបដិវត្ត ប៉ុន្តែសាក្សីចាំថាពេលនោះលោកមានការងាររធ្វើរួចហើយមិនមែនជានិស្សិតទេ ។ លោកមេធាវីបានសួរ អំពី

ពាក្យថា ហ៊ុន និងហ៊្រុន ហើយសាក្សីបានទទួលស្គាល់ថា លោកធ្លាប់ឮពាក្យទាំងនេះនៅពេលមានវគ្គសិក្សាជាមួយព្រះករុណា ប៉ុន្តែលោកមិនចាំថានៅក្នុងឆ្នាំណាទេ ។

លោកមេធាវីបានសួរអំពីការចូលមកប្រទេសកម្ពុជា ដោយទ័ពវៀតណាមមកប៉ែកខាងត្បូងប្រទេសកម្ពុជា ។ សាក្សីបានឆ្លើយថា លោកធ្លាប់ឮតែមិនសូវច្បាស់ឡើយ ។ លោកមេធាវីបានធ្វើការលើកឡើងផ្ទាល់ខ្លួន ដោយសួរទៅសាក្សីថា "តែដោយយថាហេតុយ៉ាងណានៅពេលនោះក្រុម ខ្មែរកុម្មុយនីស្ត វៀតណាមនោះមិនបានដឹកនាំប្រទេសទៅជាក្រុមកុម្មុយនីស្ត ប៉ុល ពត និយមចិនជាអ្នកកាន់កាប់អំណាចពីឆ្នាំ១៩៧៥ ដល់១៩៧៩ទៅវិញ ។ តើរឿងនេះលោកដឹងច្បាស់ដូចមាននៅក្នុងឯកសារទេ? ឬក៏លោកឮគេថា? ខ្ញុំនិយាយពីមុនដំបូងបំផុតថាលោកជាអ្នកបញ្ញវន្តម្នាក់ហើយដែលមានវ័យចំណាស់ល្មមដឹង" ។ ភ្លាមៗនោះមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអាជ្ញាបានធ្វើការជំទាស់នឹងអ្វីដែលលោកមេធាវី អរុណ បានលើកឡើង ។ លោកប្រធានអង្គជំនុំជម្រះបានគាំទ្រការជំទាស់នេះ ហើយបានផ្តល់ហេតុផលថា លោកមេធាវីមិនអាចប្រើការសន្និដ្ឋានរបស់ខ្លួនមកសួរដេញដោលសាក្សីដូច្នេះទេ ហើយសំណួររបស់លោកមិនមាននៅក្នុងដីការដំណោះស្រាយទេ ។ ដោយហេតុថាសំណួរភាគច្រើនរបស់លោកមេធាវី អរុណ មិនទាក់ទង ដូច្នេះលោកសូមបញ្ចប់សំណួររបស់ខ្លួន ។

បន្ទាប់ពីបញ្ចប់សំណួររបស់ខ្លួន លោក អរុណ បានផ្ទេរវេទិកាសួរជូនដៃគូរបស់លោក ដែលជាមេធាវីអន្តរជាតិ ។ លោកមេធាវី ហ្សាស្តើ ប៉ៅ បានចាប់ផ្តើមសំណួរទាក់ទងនឹងឯកសារដែលផ្តល់ដោយសហចៅក្រមស៊ើបអង្កេតថា តើអាចជួយដល់ការយល់ដឹងរបស់លោកអំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោក សគឹម ល្មុត បានឆ្លើយថា ឯកសារទាំងនោះអាច ជួយបានខ្លះ ហើយតាមរយៈឯកសារទាំងនោះធ្វើឲ្យលោកដឹងថាក្រសួងណារាយការណ៍ទៅនរណា ។សាក្សីបានជម្រាបជូនអង្គជំនុំជម្រះដែរថា នៅក្នុងរបបនោះលោកមិនដែលចូលរួមប្រជុំនាំស្រូវអង្ករចេញពីកម្ពុជាឡើយ ។ នេះជាភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។ លោកក៏មិនដឹងពីការនាំចេញស្រូវ ឬផលិតផលផ្សេងទៀតនោះ


ហ្សាស្តើ ប៉ៅ

ទេ ។ ការណ៍ដែលលោកថាស្រូវមិនអាចនាំចេញច្រើននោះវាជាការសន្និដ្ឋានអត្តនោម័តរបស់លោកប៉ុណ្ណោះ ដោយសារមិនមានដើងលេខអ្វីច្បាស់លាស់ទេ ។ លោកមេធាវីបានបន្តសួរដោយដាក់ឯកសារ បន្ទាប់មកលោកបានអានសេចក្តីសម្រង់ហើយសួរថាតើមានទឹកជំនន់ខ្លាំងទេនៅឆ្នាំ១៩៧៨? សាក្សីបានឆ្លើយថាខ្លួនមិនចាំទេ ។ លោកមេធាវីបានបង្ហាញឯកសារជូនសាក្សី ប៉ុន្តែសាក្សីមិនធ្លាប់បានឃើញឯកសារនេះទេ ដូច្នេះអង្គជំនុំជម្រះបានដកឯកសារនោះវិញ និងរំឭកដល់មេធាវី ថាគួរតែពិនិត្យនិងដាក់ឯកសារទៅក្នុងបញ្ជីជាមុនមិនមែនដាក់ហើយបាននិយាយថាមិនច្បាស់ដូច្នេះទេ ។ លោកមេធាវីបានស្នើថាបើមិនអនុញ្ញាតឲ្យសួរលើឯកសារនេះទេនោះលោកមិនមានអ្វីសួរទេ ។

គួរកត់សម្គាល់ថា ក្រុមមេធាវីការពារក្តី អៀង សារី មិនមានសំណួរទៅសាក្សីទេ ។ នៅមុនពេលបញ្ចប់សវនាការសួរដេញដោលសាក្សី សគឹម ល្មុត លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បានសួរទៅកាន់សាក្សីអំពីអត្តសញ្ញាណរបស់ឈ្មោះ ហែម ថាតើផ្អែកលើការវិភាគរបស់លោក តើមានឈ្មោះនរណាផ្សេងដែលក្រៅពី ខៀវ សំផន ឬទេ? សាក្សីបានឆ្លើយថាវាជាបញ្ហាស្មុគស្មាញមួយ គឺលោកដឹងថាឯកសារមួយចំនួនត្រូវបញ្ជូនទៅឈ្មោះ ហែម ហើយជាទូទៅគេស្គាល់ថា ហែម ជាខៀវ សំផន តែបើរកឯកសារណាដែលមកបញ្ជាក់ថាពិតជាឈ្មោះរបស់ខៀវ សំផន នោះគឺគ្មានទេ តែលោក

មិនដឹងថាមាននរណាផ្សេងដែលមានឈ្មោះ ហែម ក្រៅពីខៀវ សំផន នោះទេ ។

## IV) សវនាការស្តីពីការស្តាប់សក្ខីកម្មរបស់សាក្សី សៅ សារុន

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ នាពេលរសៀលបន្ទាប់ពីបញ្ចប់សវនាការសួរដេញដោល សាក្សី សគីម លុត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តសវនាការរបស់ខ្លួននៅក្នុងដំណាក់កាលទីមួយស្តីអំពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៅក្នុងដំណាក់កាលទីមួយ ។ សាក្សីថ្មីនេះមានរហ័សនាម CTW-៦០៤ ដែលមានឈ្មោះថា សៅ សារុន ប៉ុន្តែនៅអំឡុងឆ្នាំ ១៩៧៤-៧៥ លោកធ្លាប់បានប្រើឈ្មោះ នូ សារុន ។ បច្ចុប្បន្នសាក្សីមានអាយុប្រហែល ៨០ ឆ្នាំ និង កំពុងរស់នៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ឪពុករបស់លោកឈ្មោះ សៅ នូ និងម្តាយឈ្មោះ ទ្រេន វ៉ែង ។ លោកមានប្រពន្ធឈ្មោះ នូ ម៉ឹត ហៅ យន់ និងមានកូន ១០នាក់ គឺប្រុស ៥នាក់ និងស្រី៥នាក់ ប៉ុន្តែស្លាប់អស់ ៤នាក់ ។


សាក្សី សៅ សារុន

## ១) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

### ១.១) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាជាតិ

សំណួរដំបូងរបស់លោកព្រះរាជអាជ្ញាជាតិបានសួរបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួនខ្លះៗរបស់សាក្សី ។ ចូលដល់ការសួរនាំអំពីឈ្មោះប្រើក្នុងរបបកម្ពុជាប្រជាធិតេយ្យទៅកាន់សាក្សី លោកតំណាងសហព្រះរាជអាជ្ញាបានដាក់ឯកសារដែលបញ្ជាក់ថា សាក្សីមានប្រើឈ្មោះ បៃ នៅក្នុងរបបនោះ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាតិ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនបានធ្វើប្រវត្តិរូបជូនប្រធានតំបន់ឈ្មោះ ឡាំង ។ លោកសហព្រះរាជអាជ្ញាស្នើដាក់បញ្ចាំងឯកសារដែលនិយាយថា លោកចូលបដិវត្តតាមរយៈឈ្មោះ កែត និង បុន ហើយខទ្ទេសនាមដោយ បុន និង ឡាំង ។ ពេលនោះសាក្សីបានទទួលស្គាល់ថាត្រឹមត្រូវ ។ សាក្សីបានរៀបរាប់ថាខ្លួនបានរៀនសូត្រតិចតួចអំពីមាគ៌ាបក្ស និងមាគ៌ាបដិវត្ត ដែលធ្លាប់បានទទួលការអប់រំអំពីមាគ៌ាបក្សចំនួន១០ដង និងវគ្គខ្លីៗជាច្រើនដង ប៉ុន្តែលោកមិនចាំថាអ្នកណាជាអ្នកអប់រំទេ គ្រាន់តែដឹងថាមានអ្នកចូលរួមប្រហែល១០ នាក់ ។

#### ក) តួនាទីមុនឆ្នាំ ១៩៧៥

តួនាទីរបស់សាក្សីនៅមុនឆ្នាំ១៩៧៥ គឺធ្វើជាអ្នកណែនាំប្រជាជនឲ្យយល់ពីបដិវត្ត ការកសាងសេដ្ឋកិច្ច ការវាយចក្រពត្តិអាមេរិក ការធ្វើស្រែចម្ការ និងការដាំដំណាំ ដើម្បីផ្គត់ផ្គង់ការហូបចុកឲ្យបានគ្រប់គ្រាន់ ដោយគោរពតាមការណែនាំពីថ្នាក់លើ ។ ចំណែកគោលដៅបដិវត្តនៅពេលនោះ លោកដឹងត្រឹមថា គឺការទៅវាយចក្រពត្តិអាមេរិកប៉ុណ្ណោះ ។ ឆ្លងតាមការដាក់បង្ហាញឯកសារសាក្សីបានទទួលស្គាល់ថា លោកធ្លាប់ធ្វើជាអនុលេខាភូមិ គ្រប់គ្រងឈ្លបនិងជំទប់អ-៤ ។ ក្នុងតួនាទីជាឈ្លបភូមិ លោកធ្វើជាអ្នកការពារភូមិកុំឲ្យមានចោរលួច ចោរប្លន់ជាដើម ។នៅឆ្នាំ១៩៧១ លោក សៅ សារុន ត្រូវបានតែងតាំងជាលេខាស្រុកពេជ្រដា ដោយលេខាតំបន់១០៥ ដែលតំបន់នេះ អាចនិយាយបាន ថាជាតំបន់ឯករាជ្យ ។ តំបន់មណ្ឌលគិរី ត្រូវបានខ្មែរក្រហមរំដោះតាំងពីឆ្នាំ១៩៧០ ពេលនោះតួនាទីរបស់លោកគឺដោះស្រាយជីវភាពជូនប្រជាជន ប្រហែល

២០០០ ទៅ៣០០០នាក់ កុំឲ្យការហូបចុកមានភាពខ្វះខាត ។ សមាជិកនៅស្រុកពេជ្រចិន្តា មានប្រហែល ៣០ នាក់ ដែលមានតួនាទីរៀងៗខ្លួន តាមឃុំទាំង៤ ដូចជា ឃុំក្រាំងតេះ ឃុំប៊ូស្រា ឃុំទោស្វាយ និងឃុំកៅកែ្វ ។ ក្នុងឃុំនីមួយៗ មានលេខាឃុំ ហើយលេខាឃុំមួយចំនួនត្រូវបានតែងតាំងដោយលេខាស្រុក ។ សាក្សីធ្វើជាលេខាស្រុកតាំងពីឆ្នាំ១៩៧១ ដល់១៩៧៨ ។ លោកបានជម្រាបថាតំបន់១០៥ មាន៥ស្រុកគឺស្រុកកោះញែក ស្រុកច្បារ ស្រុកពេជ្រចិន្តា ស្រុកអូររាំង និងស្រុកកែវសីម៉ា ។ លោកតំណាងសហព្រះរាជអាជ្ញា បានបន្តដាក់ឯកសារស្តាប់ចម្លើយសាក្សីជាមួយចៅក្រមស៊ើបអង្កេត ដែលនៅក្នុងឯកសាររៀបរាប់ពីឈ្មោះលេខាស្រុកទាំង៥ខាងលើ ហើយសាក្សីក៏បានទទួលស្គាល់ការលើកឡើងនោះជាការត្រឹមត្រូវ ។ ឆ្លើយតបនឹងសំណួរសាក្សីបានជម្រាបជូនអង្គជំនុំជម្រះថាខ្លួនស្គាល់លោក ហាំ អនស៊ី ដែលជាប្អូនរបស់ ឡាំង ដោយសាររស់នៅភូមិជិតគ្នាតាំងពីតូច ប៉ុន្តែលោកមិនដឹងថាមានតួនាទីជាអ្វីនោះទេ ។

ក្នុងឆ្នាំ១៩៧៥ លោកសារុន ធ្លាប់ធ្វើជាអ្នកទទួលខុសត្រូវការងារសង្គមកិច្ចនៅក្នុងស្រុកចំនួនពីរជិតគ្នាគឺ ស្រុកពេជ្រចិន្តា និងស្រុកអូររាំង ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះ ថាថ្នាំពេទ្យប្រើនៅ ទីនេះត្រូវបានបញ្ជូនមកពីភ្នំពេញ តែលោកមិនដឹងថាអ្នកណាជាអ្នកប្រគល់ទេ ព្រោះខាងតំបន់ជាអ្នកប្រគល់មក ។ លោកក៏បានបញ្ជាក់ទៀតថា ជាទូទៅនៅខាងមណ្ឌលគិរី បញ្ហាសុខភាពមានដូចជា ជំងឺគុនចាញ់ ជំងឺរបេង និងជំងឺផ្សេងៗទៀត ។

នៅចន្លោះឆ្នាំ១៩៦៣-៧៥ សាក្សីមិនបានចូលរួមប្រជុំជាមួយមេដឹកនាំបក្សទេ ។ លោកធ្លាប់បានប្រជុំជាមួយតាធុច និងតាឡាង ដែលនិយាយអំពីការវាយចក្រពត្តិអាមេរិក សក្តិភូមិ និងនាយទុន ។ សាក្សីបានឆ្លើយថាលោកមិនបានឃើញ ប៉ុល ពត និង អៀង សារី ទេ ។ នៅពេលក្រោយមក លោកបានចូលរួមប្រជុំនៅខេត្តកំពង់ធំ ដែលមានអ្នកចូលរួមជាច្រើន ប៉ុន្តែលោកមិនស្គាល់អ្នកទាំងនោះឡើយ ។ លោកតំណាងសហព្រះរាជអាជ្ញាបានអានសេចក្តីសម្រង់ដែលនិយាយថា ការប្រជុំនោះមានអ្នកចូលរួមប្រជុំធំ គឺ ធុច និង ប៉ុល ពត បន្ទាប់មកសាក្សីបានទទួលស្គាល់ថាវាជាការត្រឹមត្រូវ ប៉ុន្តែនៅពេលនោះលោកមិនដឹងថា ប៉ុល ពត មានមុខងារជាអ្វីទេ ។ លោកសារុន បានបន្តទៀតថា នៅក្នុងការប្រជុំដែលមានរយៈពេល១០ថ្ងៃនេះ ប៉ុល ពត ជាអ្នកខាងទ្រឹស្តីនាមឲ្យវាយចក្រពត្តិអាមេរិក ប៉ុន្តែសាក្សីមិនដឹងទេថាសត្រូវរបស់បក្សជាមន្ត្រី និងទាហាននៃរបប លន់ ណុល ឡើយ ។

នៅថ្ងៃបន្ទាប់លោក សេង ប៊ុនយាង បានចាប់ផ្តើមដោយការសួរនាំអំពីការចូលរួមនៅក្នុងកិច្ច ប្រជុំនៅខេត្តកំពង់ធំ ក្នុងឆ្នាំ១៩៧២ ។ សាក្សីបានឆ្លើយថាខ្លួនមិនបានចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ ។ លោកសហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារដែលនិយាយពីការប្រជុំនៅកំពង់ធំ ។ ភ្លាមៗសាក្សីបានទទួលស្គាល់ចំពោះការចូលរួមនៅក្នុងការប្រជុំនោះវិញ និងថែមទាំងបានរំឭកថាការប្រជុំគឺធ្វើឡើង ជាមួយ នួន ជា ដែរ ប៉ុន្តែខ្លួនទើបតែស្គាល់ នួន ជា នៅពេលនោះប៉ុណ្ណោះ ដោយសារការខាងទ្រឹស្តីនាម ហើយក៏មិនដឹងថា នួន ជា នៅពេលនោះមាននាទីជាអ្វីដែរ ។ ការប្រជុំនៅកំពង់ធំក្នុងឆ្នាំ១៩៧១ គឺដូចគ្នានឹងការប្រជុំនៅឆ្នាំ១៩៧២ ដែរ ដែលមានរយៈពេលប្រហែល១០ថ្ងៃ ។ ពេលនោះលោកបាន ឃើញ ប៉ុល ពត តែម្នាក់ប៉ុណ្ណោះជាអ្នកផ្តល់បទខាងទ្រឹស្តីនាម ។ ដោយសារចម្លើយបែបនេះ លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនយាង បានដាក់បង្ហាញឯកសារដែលសាក្សី បានផ្តល់បទសម្ភាសន៍ជូនសហចៅក្រមស៊ើបអង្កេតដោយនិយាយថា« នៅក្នុងកិច្ចប្រជុំនោះគឺមានតែ នួន ជា ម្នាក់ប៉ុណ្ណោះដែលជាអ្នកផ្តល់ខាងទ្រឹស្តីនាម» ។ ឆ្លើយតបនឹងការលើកឡើងនេះ សាក្សីបែរជាទទួលស្គាល់ថាគឺជាការត្រឹមត្រូវ ។

លោក សារុន បានអះអាងថាខ្លួនមិនធ្លាប់បានឮពីមន្ទីរ ស-២១ ទេ ហើយពេលនោះលោកក៏ មិនស្គាល់ ខៀវ សំផន ដែរ ប៉ុន្តែ លោកស្គាល់ ខៀវ សំផន នៅក្រោយពេលរំដោះភ្នំពេញរួច ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា នៅមណ្ឌលគិរី សហករណ៍ត្រូវបានបង្កើតនៅអំឡុងឆ្នាំ១៩៧៧ ។ ពីឆ្នាំ១៩៧៣-៧៥ មិនមានប្រជាជនជម្លៀសមកនៅកោះញែកទេ លុះដល់ឆ្នាំ ១៩៧៦-៧៧ ទើបមានការផ្លាស់ប្រជាជនមកបង្កបង្កើនផល ធ្វើស្រែចម្ការនៅកោះញែក ។ សាក្សីបានបន្តទៀតថា ពីឆ្នាំ ១៩៧១-៧៥ ការហូបចុករបស់ប្រជាជនគឺដាច់ពីគ្នា ប៉ុន្តែនៅឆ្នាំ១៩៧៦-៧៧ ទើបហូបរួមគ្នាវិញ ។ មុនឆ្នាំ១៩៧៥ មានបង្កើតជាក្រុមសាមគ្គី ប្រវាស់ដៃគ្នាធ្វើ

ស្រែចម្ការដោយមានបញ្ហាពីតំបន់ ។

### ខ) របនាសម្ព័ន្ធថ្នាក់ជាតិ និងរបនាសម្ព័ន្ធទំនាក់ទំនង

ឆ្លើយតបនឹងសំណួរដោយតំណាងសហព្រះរាជអាជ្ញា លោក សៅ សារុន បានបញ្ជាក់ថា លោកមិនបានសង្កេតឃើញមុខងាររបស់ខ្លួនមានការផ្លាស់ប្តូរទេហើយការយល់ដឹងអំពីលទ្ធិកៈបក្សកុម្មុយនីស្តកម្ពុជាគឺបានដឹងតាមរយៈការចូលរួមប្រជុំ ។ ក្នុងតួនាទីជាលេខាស្រុកពេជ្រចិន្តា លោករាយការណ៍មកតំបន់អំពីការដាំដុះស្រែចម្ការមិនសូវញឹកញាប់ទេគឺមួយឬពីរសប្តាហ៍ម្តងប៉ុណ្ណោះ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរថា ចំពោះអំណាចក្នុងតួនាទីជាលេខាស្រុក តើលោកមានសិទ្ធសម្លាប់មនុស្សទេ? សាក្សីបានឆ្លើយថា អត់មានទេ ។ ជាទូទៅ លោក សារុន ធ្លាប់បានចូលរួមប្រជុំនៅតំបន់តាមរយៈការអញ្ជើញក្នុងរយៈពេលមួយ ឬពីរខែម្តងនៅឯមន្ទីរតំបន់ ។ នៅក្នុងការប្រជុំមានមនុស្សជាច្រើន គឺមកពីគ្រប់ស្រុក ហើយជាទូទៅគេលើកអំពីបញ្ហាគ្រប់គ្រងប្រជាជនដោះស្រាយកន្លែង ស្នាក់នៅ និងធ្វើយ៉ាងណាឲ្យប្រជាជនផុតពីភាពក្រីក្រ និងរាយការណ៍ទៅថ្នាក់លើអំពីស្ថានភាពប្រជាជនប្រាប់ទៅតំបន់ ។ នៅពេលបម្រើការងារជាលេខាស្រុកនៅក្នុងរបបខ្មែរក្រហម លោកបានទទួលរបាយការណ៍ពីតាមឃុំជារៀងរាល់ខែអំពីការបង្កបង្កើនផល ការរៀបចំផ្ទះ និងស្ថានភាពទូទៅនៅក្នុងឃុំ ហើយលោកធ្វើការក្នុងមួយសប្តាហ៍តែមួយថ្ងៃ ឬកន្លះថ្ងៃប៉ុណ្ណោះ ។

លោកព្រះរាជអាជ្ញាបានសួរពីមន្ទីរក-១១ ហើយសាក្សីបានបញ្ជាក់ថាមន្ទីរនេះមានអ្នកទទួលខុសត្រូវឈ្មោះ សុភា ដែលកាន់តួនាទីខាងយោធាតំបន់ ។ ចំណែកនៅតំបន់១០៥ មានមន្ទីរពាណិជ្ជកម្ម ដែលឈ្មោះម្យ៉ាងទៀតហៅថាមន្ទីរក-១៦ ទទួលខាងសេដ្ឋកិច្ចតំបន់ ដែលមានទីតាំងនៅជិតមន្ទីរតំបន់ដែរ ។ ប៉ុន្តែលោកមិនដឹងថានរណាទទួលបន្ទុកនៅមន្ទីរនេះទេ ។ សាក្សីបានជម្រាបថានៅស្រុកមិនមានមន្ទីរ អប់រំកែប្រែទេគឺមានតែនៅមន្ទីរតំបន់ប៉ុណ្ណោះដែលមន្ទីរកែប្រែមានទីតាំងស្ថិតនៅជិតមន្ទីរតំបន់ដែរ ។

### គ) អំពីកិច្ចប្រជុំវគ្គអប់រំនយោបាយ

នៅក្នុងបន្ទប់សវនាការ សាក្សី សៅ សារុន បានបំភ្លឺថា ការអប់រំបក្ស និងនយោបាយបក្ស គឺ និយាយអំពីការបង្រួបបង្រួមគ្នាការពារទឹកដី ។ នៅពេលធ្វើជាលេខាស្រុកពេជ្រចិន្តា លោកមិនដែលចូលរួមប្រជុំវគ្គនយោបាយនៅទីក្រុងភ្នំពេញទេ គឺប្រជុំតែនៅក្នុងតំបន់ប៉ុណ្ណោះ ។ បន្ទាប់ពីលោកតំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារដែលនិយាយពីការចូលរួមប្រជុំពីរដងនៅបុរីកីឡា និងម្តងទៀតនៅចន្លោះបុរីកីឡា និងផ្លូវសហព័ន្ធរុស្ស៊ី ដែលម្តងៗគឺ១២-១៣ថ្ងៃនោះ សាក្សីបាន យល់ស្រប ។ លោកចាំថាមានថ្នាក់ដឹកនាំមួយចំនួនបានចូលរួម និងបិទវគ្គ ដូចជា ប៉ុល ពត ខៀវ សំផន អៀង សារី និងអៀង ធីរិទ្ធ ។

### ឃ) កិច្ចប្រជុំស្វ័យតិតៀន

នៅខេត្តមណ្ឌលគិរី ការប្រជុំស្វ័យទិតៀន មិនសូវញឹកញាប់ទេគឺប្រហែល៦ខែម្តង ហើយបើប្រជុំនៅស្រុកមានគណៈស្រុក ចូលរួម ។ ការប្រជុំនេះគឺចែកតាមក្រុម ដែលជាក់ស្តែងមានពី៥ ទៅ៨នាក់ក្នុងមួយក្រុម ។ ការប្រជុំបែបនេះធ្វើឡើងក្នុងគោលបំណងកុំឲ្យកម្មាភិបាលខូច និងពង្រឹងឲ្យមានការយកចិត្តទុកដាក់ជាមួយប្រជាជន ។ មានអ្នកខ្លះបានលើកឡើងធ្វើស្វ័យតិតៀនខ្លួនឯង ប៉ុន្តែមិនមាន ការនាំយកទៅដាក់ពិន័យអ្វីទេ ។

## ១.២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

លោកតំណាងសហព្រះរាជអាជ្ញាបានលើកឡើងអំពីកិច្ចសម្ភាសន៍បួនលើកដែលសាក្សីធ្លាប់ធ្វើជាមួយចៅក្រមស៊ើបអង្កេត ។ ប៉ុន្តែការបង្ហាញនេះត្រូវបាន សាក្សីបដិសេធថាខ្លួនមិនចាំទេបន្ទាប់ពីការដាក់បង្ហាញឯកសារនោះ ។ ក្រោយមក សាក្សីបានអះអាងថាខ្លួនបានឆ្លើយយ៉ាងស្មោះត្រង់ជូនលោកចៅក្រមស៊ើបយ៉ាងអស់ពីចិត្ត ។ លោកតំណាងសហព្រះរាជអាជ្ញាបានសួរថា តើមានបានអានឡើងវិញនូវអ្វីដែលលោកឆ្លើយនោះឬទេ? លោក សារុន បានឆ្លើយថាចៅក្រមស៊ើបអង្កេតបានអានឡើងវិញជូនលោកស្តាប់ ។ អង្គភាពគាំពារសាក្សី បានអានម្តងទៀតឲ្យលោកស្តាប់មុនមកផ្តល់សក្ខីកម្មនេះផងដែរ ហើយលោកមិនមានអ្វីកែប្រែទេ ។

លោកតំណាងសហព្រះរាជអាជ្ញាមានការចាប់អារម្មណ៍អំពីមន្ទីរក-១៦ ដែលជាមន្ទីរសេដ្ឋកិច្ច ប្រចាំតំបន់ ។ មន្ទីរនោះនៅជិតមន្ទីរតំបន់ប្រហែល១០០ម៉ែត្រ ។ បើទោះបីជាលោកសហព្រះរាជអាជ្ញាព្យាយាមសួរសាក្សីអំពីឯកសារទង់បដិវត្តក៏ដោយ ប៉ុន្តែត្រូវបាន

សាក្សីឆ្លើយថាខ្លួនមិនចាំឯកសារទាំងនោះទេ ។ មានការបង្ហាញ ឯកសារ និងអានជូនសាក្សីគឺសារទូរលេខដែល ឡេង ផ្ញើមកមន្ទីរ៨៧០ ។ នៅក្នុងចម្លើយតបរបស់ខ្លួន សាក្សីបានលើកឡើងថាលោកមានវត្តមាននៅមហាសន្និបាតមួយ នៅឆ្នាំ១៩៧៥ ដែលមានរយៈពេលបីថ្ងៃ នៅទីក្រុងភ្នំពេញ ។ លោកសហព្រះរាជអាជ្ញាបានបន្តសំណួរអំពីការធ្វើដំណើរមកភ្នំពេញ ដើម្បីចូលរួមនៅក្នុងមហាសន្និបាតខែ ខសភា ឆ្នាំ១៩៧៥ ។ នៅក្នុងដំណើរ ដែល មានគ្នាបីនាក់ សាក្សីបានមកទីក្រុងភ្នំពេញតាមរយៈឡានពីមណ្ឌលគិរីមកក្រចេះ ហើយជិះកាណូតពីក្រចេះមកភ្នំពេញ ។ លោកសាក្សីដំបូងបានឆ្លើយថាខ្លួនមកស្នាក់នៅភ្នំពេញរយៈពេលបីថ្ងៃមួយយប់ ហើយក៏ត្រលប់ទៅវិញ ។ ប៉ុន្តែនៅពេលដែលតំណាងសហព្រះរាជអាជ្ញាអានសក្ខីកម្មដែលសាក្សីបានធ្វើនៅចំពោះមុខចៅក្រមស៊ើបអង្កេតថា នៅពេលនោះបានមកស្នាក់នៅភ្នំពេញរយៈពេល១០ថ្ងៃនោះ សាក្សីក៏បានឆ្លើយថា “ជាការត្រឹមត្រូវហើយ គឺមាន១០ថ្ងៃប៉ុណ្ណឹងទេ” ។ សាក្សីបានបន្តទៀតថា ការមកចូលរួមប្រជុំនោះមានតំណាងទាំងអស់មកពីភូមិភាគនីមួយៗ និងតំណាងមកពីខាងអង្គភាពយោធាដូចជាមកពីខាងកងពលជាដើម តែលោកមិនស្គាល់អ្នកទាំងនោះទេ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ថាអ្នកនិយាយនៅក្នុងអង្គប្រជុំលោកឃើញមាន ប៉ុល ពត និងនួន ជា ដែលមានកាលវិភាគប្រជុំក្នុងមួយថ្ងៃគឺ ពេលព្រឹកពីម៉ោង៧-១១ និងពេលរសៀលចាប់ពីម៉ោង២ដល់ម៉ោង៥ ទើបសម្រាកហូបបាយ ។ នៅក្នុងការប្រជុំលើកនេះ សាក្សីបានឃើញមានវត្តមានរបស់ប៉ុល ពត និង នួន ជា ជាអ្នកធ្វើបទខុទ្ទេសនាមពេញមួយថ្ងៃ ។ គោលបំណងប្រជុំគឺ និយាយអំពីការកសាងប្រទេសជាតិឲ្យរីកចំរើន ដឹកនាំប្រជាជនឲ្យបង្កបង្កើនផល មានបាយហូប និង លំនៅស្ថានគ្រប់គ្រាន់ ។ លោក ឌេល លីសាក់ បានសួរសាក្សីអំពីអ្វីដែល នួន ជា និង ប៉ុល ពត បានអប់រំនៅក្នុងអង្គប្រជុំដោយផ្តោតទៅលើបញ្ហានយោបាយ ការរៀបចំសហករណ៍ ការហាមមិនឲ្យចាយលុយ ការបិទផ្សារនិងវត្តអារាម ហើយថាអ្នកទាំងពីរបានលើកឡើងដែរថា ថ្ងៃក្រោយនឹងបើកឲ្យមានវិញ ។ នៅត្រង់ចំណុចនេះ សាក្សីបានយល់ព្រមថា គឺពិតជាមាននិយាយពីបញ្ហានេះមែន ។ សេចក្តីលម្អិតអំពីការប្រជុំបិទផ្សារ នោះគឺ ប៉ុល ពត បានជម្រាបដល់អង្គប្រជុំថា ប្រាក់នឹងត្រូវបើក ឲ្យចាយវិញ ចំណែកការជម្លៀសប្រជាជនវិញ គឺនឹងត្រូវបញ្ជូនឲ្យមករស់នៅក្នុងទីក្រុងវិញ ។ លើសពី នេះសាក្សីបានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះថា លោកបានឮការលើកឡើងពីការធ្វើទំនប់ប្រឡាយតាមរយៈ ប៉ុល ពត ដែលបញ្ជាឲ្យអ្នកនៅតាមតំបន់រៀបចំផែនការ និងគម្រោងធ្វើទំនប់ប្រឡាយ ដោយ តម្រូវឲ្យមានការឯកភាពគ្នានៅក្នុងតំបន់ទើបអាចលើកផែនការនោះបាន ។

## ក) ការប្រជុំបិទវត្តអារាម

ការប្រជុំដែលនិយាយអំពីការបិទវត្តអារាមមានរយៈពេលបីថ្ងៃ ។ លោកតំណាងសហព្រះរាជអាជ្ញាបានសួរថា តើកម្មាភិបាលនៅក្នុងកិច្ចប្រជុំមានឲ្យពួកគេទៅបិទវត្តអារាមនៅតំបន់រៀងៗខ្លួនដែរឬទេ?

សាក្សីបានឆ្លើយថាអត់ទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទៀតថា នៅទីនោះជនជាតិភាគតិចមានជំនឿលើការសែនព្រេនជាសំខាន់ និងការកាន់សាសនាព្រះពុទ្ធ ។ តើជនជាតិភាគតិចត្រូវបានគេហាមឃាត់មិនឲ្យសែនទេ? សាក្សីបានបញ្ជាក់ត្រង់ចំណុចនេះថា គេមិនហាមទេគ្រាន់តែមិនឲ្យកាប់គោក្របីធំៗ គឺអនុញ្ញាតឲ្យកាប់គោក្របីតូចៗ ព្រោះខ្លាចអស់សត្វសម្រាប់ជួយធ្វើស្រែ ហើយការណែនាំនោះគឺអ្នកគ្រប់គ្រងនៅតាមស្រុក និងឃុំ ជាអ្នកណែនាំ ។ តាមការបញ្ជាក់របស់សាក្សី ការកសាងវត្តអារាមនៅមណ្ឌលគិរី បានចាប់ផ្តើមនៅឆ្នាំ១៩៦៣ ។ រហូតមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺមានវត្តចំនួននៅខេត្តមណ្ឌល



ការបំផ្លាញវត្តអារាម (ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

គីរី ។ សាក្សីបានបន្តទៀតថា ជាការពិតមិនមាននរណាបិទវត្ត អារាម នៅមណ្ឌលគិរីទេនៅក្រោយឆ្នាំ១៩៧៥ គឺមានការរត់ខ្ចាត់ខ្ចាយពីវត្តទាំងនោះដោយសារតែអាមេរិកមកទម្លាក់គ្រាប់បែក ។ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនមានព្រះសង្ឃណាគង់នៅក្នុងវត្តទៀតទេ តាំងពីអាមេរិកទម្លាក់គ្រាប់បែកនៅអំឡុងឆ្នាំ ១៩៧០-១៩៧៥ ព្រោះការទម្លាក់នោះច្រើនណាស់ គឺតាំងពីព្រឹកដល់ល្ងាច ។

សាក្សីនិយាយថា ប៉ុល ពត ផ្តល់យោបល់ឲ្យបង្កើតសហករណ៍កម្រិតទាបដែលមានលក្ខណៈតូចៗ ព្រោះដើម្បីសម្រួលដល់ការហូបចុកឲ្យមានភាពងាយស្រួល ។ ទាក់ទងនឹងភាពខុសគ្នានៃក្រុមសហករណ៍ទាប និងក្រុមសាមគ្គី លោក សារុន បានផ្តល់ភាពច្បាស់លាស់ថា សហករណ៍គឺហូបចុករួមគ្នា ឯក្រុមសាមគ្គីនោះគឺហូបនៅផ្ទះរៀងខ្លួន ហើយការណែនាំ គឺធ្វើពីតំបន់មកស្រុក និងពីស្រុកមកសហករណ៍ ។

## ១) ការរៀបអាពាហ៍ពិពាហ៍

នៅចំពោះមុខអង្គជំនុំជម្រះ សាក្សី សៅ សារុន បានរៀបរាប់ថា ផែនការការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺបក្សមានការរៀបការច្រើនគូក៏បានតិចក៏បាន ប៉ុន្តែលុះត្រាតែ ឪពុកម្តាយរបស់សាមីខ្លួនឯកភាពទើបអាចធ្វើបាន ។ អ្នករៀបការគឺអ្នកស្រលាញ់គ្នា ហើយមុននឹងរៀបការត្រូវមានការសួរបញ្ជាក់ជាថ្មីរវាងសាមីខ្លួនម្តងទៀត ។ ប្តីប្រពន្ធមិនអាចរៀបការដោយគ្មានការយល់ព្រមពីអង្គការបានទេ ។ សាក្សីបានជម្រាបថាក្នុងពេលលោកធ្វើជាអនុលេខានៅស្រុកពេជ្រចិន្តា លោកបាន រៀបចំពីធីរៀបការបានតែម្តងគត់ ។

បន្ទាប់ពី តាឡាំង បានស្លាប់នៅក្នុងឆ្នាំ១៩៧៨ លោកសៅ សារុន បានធ្វើការជំនួស តាឡាំង ដោយមានការតែងតាំងពីមហាសន្និបាត ប៉ុន្តែលោកធ្វើការងារជំនួសនោះបានតែ២ខែប៉ុណ្ណោះ ក៏មានទ័ពវៀតណាមចូលមករំដោះ ។ លោក សារុន ចាំបានថា បន្ទាប់ពីតាឡាំង បានស្លាប់ លោកបានចូលរួមនៅក្នុងអង្គប្រជុំជាមួយ ប៉ុល ពត និង សុន សេន និងអ្នកផ្សេងទៀត ពេលនោះថ្នាក់ដឹកនាំទាំងពីរនេះបានឲ្យលោកធ្វើការជំនួស តាឡាំង ហើយលោកក៏បានធ្វើការបដិសេធ ។ ទោះបីជាលោកព្យាយាម ប្រានចោលមុខងារនេះ ដោយលើកឡើងពីអសមត្ថភាពរបស់លោក ដែលមិនយល់ដឹងយ៉ាងណាក៏ដោយ ប៉ុល ពត ជម្រុញឲ្យលោកធ្វើការងារនៅមន្ទីរ៩២០ដដែល ។ ពេលនោះ ប៉ុល ពត បានប្រាប់ លោកថា «ឲ្យតែមិត្តឯងធ្វើការងារខាងកងពល៩២០នោះ គឺមាន តាសាន ជួយការងារក្នុងតំបន់» ។ ដោយសារមិនហ៊ានប្រកែក លោកសារុន ត្រូវបានតែងតាំងធ្វើការងារជំនួស តាឡាំង អ្នកដែលតែងតាំងនៅពេលនោះគឺ ប៉ុល ពត ប៉ុន្តែសាក្សីខ្លួនឯងមិនដឹងថាអ្នកណាបានបោះឆ្នោតតែងតាំងលោកនោះទេ ។ សាក្សីបានបញ្ជាក់ថានៅពេលដែលលោកចេញពីស្រុកពេជ្រចិន្តា ពីឆ្នាំ១៩៧១-៧៤ ហើយឈ្មោះ ម៉ាឡា បានធ្វើការជាប្រធានជំនួស ។



ពិធីរៀបអាពាហ៍ពិពាហ៍ ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ក) បុគ្គលដែលធ្លាប់ស្គាល់

ទាក់ទងនឹងឈ្មោះមួយចំនួនដែលលោកតំណាងសហព្រះរាជអាជ្ញាបានលើកយកមកសួរសាក្សី មានដូចជា តាសាន ស្វាយ និងឈិន ។ សាក្សីបានផ្តល់ចម្លើយថា តាសាន ជាអ្នកទទួលការងារជាមេកងពលនៅមណ្ឌលគិរី ក្នុងខែតុលា ឆ្នាំ១៩៧៨ ។ ឈ្មោះ ស្វាយ ជាលេខាស្រុកកោះញែក ហើយឈ្មោះនេះបានបាញ់សម្លាប់បងថ្លៃរបស់សាក្សីចំនួន២ នាក់គឺឈ្មោះ គី និង ដាំ (ជាសមាជិកស្រុក ពេជ្រ ចិន្តា) ។ ឯឈ្មោះ ឈិន លោកសាក្សីមិន ស្គាល់ទេ ។ ចំណែកបុគ្គលមួយចំនួនទៀត សាក្សីបានផ្តល់ចម្លើយថា លោកគ្រាន់តែដឹងថាប្រធាន មន្ទីរក-១៦ ឈ្មោះ នួន ប៉ុន្តែលោកមិនបានដឹងពីមូលហេតុដែលឈ្មោះនេះ រត់ចេញពីមន្ទីរនោះទេ ។ ចំពោះបុគ្គលឈ្មោះ ខាំភួន និងកូនម្នាក់ឈ្មោះ ខាំ សាក្សីបានបញ្ជាក់ថា លោកស្គាល់ឈ្មោះទាំងពីរនោះ តែលោកមិនដឹងថាខាំភួនត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ទេ ។

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញា សាក្សីបានឆ្លើយថា ប៉ុល ពត បានប្រជុំ លើកពីការទប់ទល់ជាមួយវៀតណាម ។ ហើយចំពោះការប្រជុំនៅមណ្ឌលគិរីមានការហៅយោធាតំបន់ គណៈស្រុកមកប្រជុំដែរ ។ ភ្លាមនោះសហព្រះរាជអាជ្ញាបាន ស្នើសុំដកស្រង់និងបង្ហាញឯកសារទាក់ទងនឹងបទសម្ភាសន៍របស់បុគ្គលឈ្មោះអានស៊ី ។ លោកសាក្សីឆ្លើយតបថាពិតមែនគឺធ្វើតាមថ្នាក់លើ ហើយអ្នកដែលឲ្យតាមរកខ្មាំងបង្កប់គឺ ប៉ុល ពត ។ សហព្រះរាជអាជ្ញាបានអានអត្ថបទដកស្រង់ ព្រមទាំងបានសួរទាក់ទងនឹងទូរលេខ៥៥ ។ សាក្សីឆ្លើយថា ទូរលេខនោះពិតជាបានចូលវើនៅមន្ទីរកងពលនោះមែន ។ បញ្ជីចម្លងជូននោះគឺអ្នកផ្សេងជាអ្នកសរសេរជូន ប៉ុល ពត ហើយការបញ្ជូនឯកសារទៅ ប៉ុល ពត ត្រូវតែបញ្ជូនជាប់រហូត ដែលចាប់ផ្តើមធ្វើបែបនេះក្រោយពេលតាឡាំងស្លាប់ ។ ការប្រជុំទាក់ទងនឹងការបញ្ជូនសារទូរលេខនោះ សាក្សីមិនចាំថាប្រជុំតូចឬធំទេ តែមានចំនួនច្រើនដង ប៉ុន្តែខ្លួនបានទៅចូលរួមក្នុងការប្រជុំនោះតែម្តងគត់ គឺនៅខែ៩ឆ្នាំ១៩៧៨ ហើយក្រោយមកវៀតណាមក៏ចូលមកដល់ ។

ព្រះរាជអាជ្ញាបានសួរទាក់ទងនឹងការមកភ្នំពេញនៅខែកញ្ញា ឆ្នាំ១៩៧៨ ដែលមានអ្នកចូលរួមមកពី គ្រប់ខេត្ត ។ នៅក្នុងសមាជបក្សនោះគេនិយាយទាក់ទងនឹងការដឹកនាំប្រជាពលរដ្ឋដោះស្រាយរឿងការហូបចុក និងផ្ទះសំបែងឲ្យប្រជាពលរដ្ឋ ប៉ុន្តែចំពោះការបើកផ្សារវិញខ្លួនមិនដែលឮទេ ។ ព្រះរាជអាជ្ញាបានស្នើដាក់បង្ហាញឯកសារបទសម្ភាសន៍ទាក់ទងនឹងការប្រជុំអំពីការបើកឲ្យមានទីផ្សារវិញ ដែល ប៉ុល ពត ជាគណៈអធិបតី ។ លោកសាក្សីថាឆ្លើយថាពិតជាមានមែន ប៉ុន្តែភ្លាមៗ លោកមិនចាំថាមេដឹកនាំណាមួយបានចូលរួមនោះទេ ទាល់តែគណៈចាត់តាំងហៅឈ្មោះទើបលោកបានដឹង ។ ពេលនោះ នួន ជា ជាអ្នកធ្វើបទខុទ្ទេសនាមឲ្យកម្មាភិបាលដែលចូលរួមដឹកនាំ និងដោះស្រាយបញ្ហាជូនប្រជាជនឲ្យបានល្អ ហើយពេលនោះមិនមានការធ្វើបទខុទ្ទេសនាមដោយ ខៀវ សំផន និង អៀង សារី ទេ ។ សាក្សីបានចាំថា នៅពេល ប៉ុល ពត ប្រកាសពីការបើកផ្សារ និងចាយលុយនោះ មិនមានអ្នកណាបញ្ចេញប្រតិកម្មអ្វីឡើយ ហើយគ្រាន់តែចាំទៀតថាសន្និបាតនោះមានរយៈពេល១០ថ្ងៃ ហើយមិនចាំថាមានទីតាំងនៅកន្លែងណាទេ ។ នៅក្នុងសន្និបាតដែលរៀបចំតុសម្រាប់ឲ្យអ្នកចូលរួមដោយអង្គុយនៅតាមខេត្តនីមួយៗនោះ អ្នកចូលរួមមានដូចជាតំណាងមកពីគ្រប់ខេត្ត តំណាងពីខាងយោធា និងគណៈមជ្ឈិមផង ។ ព្រះរាជអាជ្ញាបានអានឯកសារសម្ភាសន៍បន្តទាក់ទងនឹងការប្រជុំគណៈមជ្ឈិមនិង មេដឹកនាំខ្មែរក្រហមដែលក្នុងនោះមាន ខៀវ សំផន និងអៀង សារី ជាសមាជិកគណៈមជ្ឈិម ។ សាក្សីបានបញ្ជាក់ថាត្រឹមត្រូវ ប៉ុន្តែចំពោះតាម៉ុក ខ្លួនមិនស្គាល់បុគ្គលនេះទេ ។

### ឃ) ចម្លើយសារភាព

សាក្សីបានបញ្ជាក់ថា បន្ទាប់ពីមហាសន្និបាតនៅខែកញ្ញា ឆ្នាំ១៩៧៨ ដែលអង្គការបានតែងតាំងលោកតែម្នាក់ឯងនោះ អង្គការបានឲ្យលោកធ្វើចម្លើយសារភាព ពេលនោះលោកត្រូវបាន ប៉ុល ពត ឲ្យអានចម្លើយសារភាព ។ សាក្សីបន្តថាខ្លួនជាមនុស្សស្លូតត្រង់ ដូច្នេះចេះតែឆ្លើយតាមអ្វីដែលគេឲ្យអាន ។ សាក្សីបានលើកឡើងអំពីចម្លើយសារភាពមួយ ដែលគេផ្ញើមកឲ្យនៅកន្លែងធ្វើសន្និបាតនោះ ខ្លួន មិនដឹងថាចម្លើយដែលគេផ្ញើមកនោះមានប្រភពមកពីប្រភពណាទេ តែលោកមានការខឹងសម្បារណាស់នៅពេលចម្លើយនោះចេះតែឆ្លើយដាក់បន្ទុកមកលោក ដោយលោកមិនបានធ្វើអ្វីសោះ ។ ចម្លើយសារភាពនោះ សាក្សីថាមិនចាំពាក្យពេចន៍

ខ្លឹមសារនោះឡើយ ។

នៅក្នុងចម្លើយរបស់ អនស៊ី បានឲ្យដឹងថា ប៉ុល ពត បានប្រកាសថា មិនឲ្យចាប់ចងប្រជាជនទេ ទោះបីកងពល ក៏មិនមានសិទ្ធដែរ ហើយការឃាត់ខ្លួនឬចាប់ប្រជាជនទាល់តែមានការអនុញ្ញាតពីខាងគណៈមជ្ឈិម ។

## ២) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកប្រធានបានផ្ទេរវេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរដេញដោលសាក្សីបន្ត ។ លោកស្រីមេធាវី ទី ស្រីនណា បានចាប់ផ្តើមសំណួរទាក់ទងនឹងព្រឹត្តិការណ៍ពីឆ្នាំ១៩៧០ ដល់១៩៧៥ ដោយផ្តោតទៅលើអ្នកបង្កើតបក្សកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសាក្សីបានឆ្លើយតបថា លោកមិនយល់អំពីបញ្ហានេះទេ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ការបង្កបង្កើនផលនៅពេល នោះគឺដោះស្រាយបញ្ហាប្រជាជនឲ្យមានផ្ទះស្នាក់នៅ និងមានបាយហូប ។ នៅពេលនោះជីវភាពប្រជាជននៅក្នុងខេត្តទាំងមូល គឺមានសភាពសមរម្យ ទទួលបានការហូបចុកគ្រប់គ្រាន់ ហើយស្ថានភាពនៃកន្លែងស្នាក់នៅនាពេលនោះគឺផ្ទះធ្វើពីឫស្សី និងប្រក់ស្លឹក ។ ផ្ទះនោះគឺប្រជាជនជាអ្នកសាងសង់ដោយខ្លួនឯង ចំណែកលោកគ្រាន់តែណែនាំប៉ុណ្ណោះ ។ សាក្សីក៏បានជម្រាបទៀតថា នៅពេលខ្លួនកាន់កាប់ស្រុក ពេជ្រចិន្តា លោកបានទៅស្រុកកោះញែកមួយខែម្តងដើម្បីប្រជុំ ពេលណាដែលតាឡាំង លេខាតំបន់ ១០៥ ហៅលោកទៅប្រជុំនៅភ្នំក្រោលដែលគេហៅមន្ទីរក-១៧ ក្នុងស្រុកកោះញែក ។

សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលលោកកាន់កាប់នៅស្រុកពេជ្រចិន្តា មិនមាន មនុស្សថ្មីចេញចូលក្នុងស្រុកទេ មានតែអ្នកស្រុកនោះប៉ុណ្ណោះ ។ មេធាវីសួរទាក់ទងនឹងលេខាតំបន់និងប្រធានតំបន់ ។ សាក្សីឆ្លើយតបថាប្រធាន និងលេខាគឺដូចតែគ្នាទេ ។ នៅពេលធ្វើជាប្រធានតំបន់នោះ ខ្លួនទៅធ្វើនៅកន្លែងចាស់ ហើយមិនមានឯកសារណាបន្សល់ទុកនោះឡើយ ។

មេធាវីបានបន្តសំណួរអំពីមន្ទីរតំបន់ ម-១៧ សាក្សីថាខ្លួនមិនសូវយល់ពីមន្ទីរមួយនោះទេ ។ នៅពេល តាឡាំងកាន់អំណាចនៅតំបន់១០៥ មានមន្ទីរ៤ដូចជាមន្ទីរក-១៧ ជាកន្លែងធ្វើការរបស់តំបន់ (មានចម្ងាយប្រហែល១០០ម៉ែត្រពីមន្ទីរសន្តិសុខភ្នំក្រោល) , ក-១១ , ក-១៦ និងមួយទៀតខាងពាណិជ្ជកម្មតំបន់ ។ សាក្សីបានបន្តថាសមាសភាពអ្នកដឹកនាំ គឺខ្លួនមិនបានដឹងទេ ហើយចំពោះការគ្រប់គ្រងមានសមាជិកណាខ្លះក៏មិនបានដឹងដែរ ។ ទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល សាក្សីបានឆ្លើយ នៅក្នុងចម្លើយភាគច្រើនរបស់លោក គឺបង្ហាញពីភាពមិនសូវជ្រាបច្បាស់អំពីមន្ទីរមួយនេះដូចជា ថាមានចំនួនមនុស្សប៉ុន្មាននាក់នៅជាប់ឃុំ ឬក៏មិនដឹងពីប្រភេទមនុស្សដែលជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខនោះ ។ លោកស្រីមេធាវីបានស្នើសុំដល់លោកប្រធានអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារសម្ភាសន៍របស់សាក្សី និងចៅក្រមស៊ើបទាក់ទងនឹងការដោះលែងមនុស្សពីមន្ទីរឃុំឃាំងពេលដែលសាក្សីនៅជាលេខាស្រុក ។ មន្ទីរសន្តិសុខតំបន់មានទីតាំងនៅជិតមន្ទីរតំបន់ដែលគ្រប់គ្រងដោយតាសុភា ។ ចំណែកមន្ទីរសន្តិសុខតំបន់ និងមន្ទីរសន្តិសុខភ្នំក្រោលគឺដាច់ពីគ្នា ។ សាក្សីបានលើកឡើងថា ខ្លួនធ្លាប់ បានដោះលែងមនុស្សជាច្រើន តែលោកមិនចាំចំនួនប៉ុន្មាននាក់ទេ ដោយគ្រាន់តែដឹងថាខ្លួនធ្លាប់ដោះលែងបានពីរដង ។ នៅពេលដោះលែងអ្នកទោសចាស់ៗ លោកមិនមានការសុំយោបល់ពីមជ្ឈិមទេ ដោយសារខ្លួនមានសិទ្ធិសម្រេច និងដោយសារអ្នកទោសនោះមានជម្លោះតិចតួចទាក់ទងនឹងរឿងគ្រួសារប្តីប្រពន្ធប៉ុណ្ណោះ ។ ដូច្នេះបន្ទាប់ពីលោកដោះលែងទើបរាយការណ៍ទៅថ្នាក់លើ ។ ចំណែកអ្នកក្បត់បដិវត្តន៍ គឺមិនដែលមានទេ ហើយថាតើក្នុងពេល តាឡាំង កំពុងកាន់កាប់នោះលោកមិនដឹងថាមានជនក្បត់បដិវត្តន៍ ឬអត់ដែរ សូម្បីតែពេលទៅប្រជុំនៅភ្នំពេញក៏មិនមានការអប់រំអំពីជនក្បត់បដិវត្តន៍នោះឡើយ ។

ចំពោះការទំនាក់ទំនងនៅតំបន់១០៥ គឺមានតែប្រធានតំបន់ទេដែលអាចធ្វើទំនាក់ទំនងជាមួយគណៈអចិន្ត្រៃយ៍ ។ ចំណែកការដកសមាជិកមានតែ ប៉ុល ពត ទេដែលមានសិទ្ធិដក ។ ចំពោះពិធីរៀបការវិញ លោក សារុន បានអះអាងនៅចំពោះមុខអង្គជំនុំជម្រះថា ខ្លួនគ្មានសិទ្ធិបង្ខំនរណាម្នាក់ឲ្យរៀបការនោះឡើយ ។ លោកស្រីមេធាវី ស្រីនណា បានបន្តសំណួរទាក់ទងនឹងយោធាតំបន់ ១០៥ ហើយសាក្សីបានបញ្ជាក់ថា មានកំលាំងយោធាតែមួយប្រភេទ គឺយោធាតំបន់ហើយមានយោធាមជ្ឈិមមួយកងពល

ទៅឈរជើងនៅទីនោះហើយទំនាក់ទំនងគ្នាជាមួយយោធាតំបន់ ដោយសារយោធាតំបន់ជាអ្នកដឹងអំពីទីតាំងភូមិសាស្ត្រ ប៉ុន្តែការរាយការណ៍វិញគឺធ្វើឡើងផ្សេងៗគ្នា ។

ឆ្លើយតបនឹងសំណួររបស់មេធាវី សាក្សីបានឆ្លើយពាក់ព័ន្ធនឹងសន្និបាតដែលលោកបានចូលរួមជាមួយ ប៉ុល ពត ថា នៅពេលនោះ ប៉ុល ពត បានប្រកាសមិនឲ្យមានការចាប់ចងមនុស្សដាច់ខាត ចំណែកនៅតាមតំបន់ផ្សេងៗសាក្សីមិនបានជ្រាបទេ ។ សាក្សីធ្លាប់បានជជែកជាមួយជនជាប់ចោទ ខៀវ សំផន អំពីបញ្ហាសេដ្ឋកិច្ច ដែលនៅពេលនោះ ខៀវ សំផន បាននិយាយពីស្ថានភាពនៃការដាំដុះ និងការហូបចុករបស់ប្រជាជន តែមិនមានលើកពីផែនការបួនឆ្នាំនោះទេ ។ សេចក្តីណែនាំរបស់បក្ស និងការផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋានតែងតែយកមកអនុវត្តតាមជានិច្ច ។

លោកស្រីមេធាវីបានបន្តសួរទាក់ទងនឹងបញ្ហាថ្នាំពេទ្យនៅតំបន់ ដែលសាក្សីកាន់កាប់នៅរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សី សៅ សារុន បានបញ្ជាក់ថាថ្នាំពេទ្យត្រូវបានផ្តល់មកគ្រប់គ្រាន់ និងមានពេទ្យតាមជំនាញទៀតផង ។ ភ្លាមនោះមេធាវីបានស្នើសុំឲ្យមានការបង្ហាញឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបង្ហាញពីស្ថានភាពរបស់ឪពុកដែលឈឺ ហើយអង្គការមិនអនុញ្ញាតឲ្យមនុស្សឈឺទទួលអាហារ ។ សាក្សីថាខ្លួនមិនដែលឮថាមានមនុស្សឈឺ និងស្លាប់ដោយអត់អាហារទេ ។ មេធាវីបានបន្តដកស្រង់ និងបញ្ចាំងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីថា នៅឆ្នាំ១៩៧៥ មានស្ត្រីអាយុ២០ឆ្នាំ មានគ្រួសារហើយមានកូនខ្ចីតែមួយអាទិត្យ គេឲ្យទៅធ្វើការវិញ ។ ដូចនេះគាត់មិនមានកំលាំងពេលធ្វើការក៏សម្រាកនៅលើភ្លឺស្រែ ។ សាក្សីបានបញ្ជាក់ថាខ្លួនមិនយល់ពីបញ្ហានេះទេ ។

លោក សុន អរុណ មេធាវីការពារក្តី នួន ជា បានធ្វើការជំទាស់ថា មេធាវីតំណាងដើម បណ្តឹងរដ្ឋប្បវេណីមិនគួរយកសំណួរចម្លើយរបស់ភាគីផ្សេងមកសួរសាក្សីនោះទេ ។ លោកមេធាវី ខាណាវ៉ាស ការពារក្តី អៀង សារី ក៏បានជំទាស់ដែរថាមេធាវីមិនអាចយកចម្លើយរបស់សាក្សីផ្សេងមកចោទសួរទេ ហើយចម្លើយនោះមិនមែនសួរនាំនៅចំពោះមុខចៅក្រមស៊ើបអង្កេតនោះឡើយ ដូចនេះមិនអាចយកមកសួរបានទេ ។ លោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតប ថាខ្លួនមានការភ្ញាក់ផ្អើលនៅពេលមានការជំទាស់ ដោយលើកឡើងថាគាត់មានសិទ្ធិបង្ហាញតែឯកសារដែលជារបស់សាក្សី ។ សហព្រះរាជអាជ្ញាបានប្រើសក្ខីកម្មរបស់មនុស្សជាច្រើនប្រភេទ ហើយខាងមេធាវីការពារក្តីក៏ធ្វើដូច្នេះដែរ ។ ម្យ៉ាងទៀត ចម្លើយដែលខ្លួនយកមក ប្រើនេះគឺជារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលវាមានសារសំខាន់ណាស់ទោះបីមិនមានការស្បថក៏ដោយ ។ លោក ខែល លីសាក់ បានអះអាងថាចំពោះពត៌មានដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីគឺអាចយកជាការបានហើយ ការណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីមានផ្តិតម្រាមដៃនៅលើចម្លើយរបស់ខ្លួននោះ គឺជាទម្រង់នៃការធ្វើសម្បថហើយ ។ លោក ខាណាវ៉ាស បានឆ្លើយតបថា «ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនផ្តល់ដោយសម្បថនោះទេ ។ ចម្លើយរបស់សាក្សីគឺជាចម្លើយដែលផ្តល់ដោយចៅក្រមស៊ើបអង្កេតមានសម្បថដោយមានវៃគ្រា ប៉ុន្តែចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសម្បថទេ ចំណែកឯកសារដែលប្រើដើម្បីសួរដេញតាមជំហររបស់យើងគឺត្រូវមានគោលការណ៍ច្បាស់លាស់សម្រាប់អនុវត្តទាំងអស់គ្នា ។ ដូច្នេះចម្លើយរបស់ដើមបណ្តឹងគឺជាព័ត៌មានបំពេញបន្ថែមប៉ុណ្ណោះ ហើយលោកមិនជំទាស់ទេចំពោះការនាំយកដើមបណ្តឹងនោះមកផ្តល់សក្ខីកម្ម» ។ លោក វ៉ែកកែន មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនមានឈ្មោះនៅក្នុងបញ្ជីដែលនឹងត្រូវមកបង្ហាញខ្លួននៅក្នុងសវនាការនោះទេ ។ ប៉ុន្តែដោយសារបញ្ហានេះមានលក្ខណៈស្មុកស្មាញនៅពេលក្រោយមកអង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យភាគីលើកយកសក្ខីកម្មរបស់បុគ្គលទីបីមកសួរដេញដោលសាក្សី


មេធាវី ម៉ៃឃើល ខាណាវ៉ាស


ខែល លីសាក់

បានក្នុងករណីណាដែលបុគ្គលនោះមិនមានលទ្ធភាពមកផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការបាន ។

លោកស្រីមេធាវីបានបង្ហាញឯកសារដែលជាខ្លឹមសារនៅក្នុងសេចក្ដីថ្លែងការណ៍មួយបញ្ជាក់អំពីការដឹកមនុស្សទៅសម្លាប់នៅភ្នំក្រោល ។ សាក្សីបានឆ្លើយតបថាខ្លួនមិនដឹង មិនឮ និងមិនឃើញមានព្រឹត្តការណ៍ទាំងនេះទេនៅក្នុងអំឡុងឆ្នាំ១៩៧៥ ។ មេធាវីស្នើបង្ហាញឯកសារពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងមន្ទីរភ្នំក្រោលដែលមានខ្លឹមសារស្ដីអំពីការចាប់ខ្លួនមនុស្ស ។ សាក្សីនៅតែនិយាយថាខ្លួនមិនឃើញ មិនដឹង មិនឮ ។ មេធាវីអានឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តែសាក្សីនិយាយថាមិនមានការបង្ខំនោះទេ ។ សាក្សីបញ្ជាក់ថា នៅឆ្នាំ១៩៧៥ខ្លួននៅស្រុកនៅឡើយ ហើយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះក៏មិនមានដែរ ។

បន្ទាប់ពីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់សំណួររបស់ខ្លួន លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បានធ្វើការតាំងសំណួរទៅកាន់សាក្សី ។ ដំបូងលោកចៅក្រមបានចាប់ផ្ដើមសួរឲ្យសាក្សីបញ្ជាក់អំពីឈ្មោះពិតប្រាកដដើម្បីកុំឲ្យមានការភ័ន្តច្រឡំ ។ សាក្សីបានបញ្ជាក់ថាខ្លួនមានឈ្មោះ សៅ សារុន ។ លោកចៅក្រមបានសួរទាក់ទងនឹងបុគ្គលមួយចំនួនដោយចាប់ផ្ដើមពីឈ្មោះ តាឡាំង មុនគេ ។ លោកចៅក្រមបានលើកឡើងពីសម្ដីរបស់លោក សារុន មុនពេលលោកសារុន ធ្វើជាប្រធានតំបន់១០៥ ដើម្បីតាំងសំណួរ ។ លោក សារុន បានបញ្ជាក់ថា តាឡាំងគឺជាប្រធានតំបន់១០៥ ហើយបន្ទាប់ពី តាឡាំង ស្លាប់ គឺខ្លួនបានទទួលបន្ទុកនៅតំបន់ ១០៥ ដែលត្រូវបានតែងតាំងនៅពេលប្រជុំខែកញ្ញា ឆ្នាំ១៩៧៨ ។ លោកចៅក្រមបានសួរទាក់ទងនឹងឈ្មោះ ឆាន និង ហាំ ប៉ុន្តែសាក្សីបានឆ្លើយថាខ្លួនមិនដឹងព័ត៌មានអំពីអ្នកទាំងនោះទេ ។ លោកចៅក្រមបានរំឭកឈ្មោះមួយចំនួនទៀតទៅសាក្សី ប៉ុន្តែសាក្សីមិនបានចងចាំនោះទេ ។ លោក សារុន បានជម្រាបជូនអង្គជំនុំជម្រះថាខ្លួនមិនបានដឹងអំពីការកាត់ទោស ប៉ុល ពត ឡើយ ។ ក្រោយមកលោកចៅក្រមបានអានអំពីសារទូរលេខមួយចំនួនដែលផ្ញើ ទៅមន្ទីរ៩២០ ដែលមានការចម្លងជូនទៅឈ្មោះបុគ្គលមួយចំនួនដូចជា បង នួន និងប៉ង់ ជាដើម សាក្សីបានទទួលស្គាល់ថាខ្លួនធ្លាប់ផ្ញើទូរលេខនោះមែន ។ លោកចៅក្រមបានសួរពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ៩២០ ថាតើអ្នកណាជាប្រធានកងពលមុនពេលសាន កាន់តំណែងនេះ? សាក្សីបានឆ្លើយតបថាលោកមិនដឹងពីបញ្ហានេះទេដោយសារការងាររបស់ខ្លួននៅស្រុក មិនមែនកងពល ។ សាក្សីបានបន្តថា សាន ជាប្រធានកងពល ប៉ុន្តែបានស្លាប់ហើយ ។ ឆ្លើយតបនឹងសំណួររបស់លោកចៅក្រម សាក្សីបានជម្រាបថា ខ្លួនមិនស្គាល់ឈ្មោះ ម៉ែន ម៉េង ហៅឈិន ឈ្មោះ អៀ ជី ហៅសួយ ឬសោមទេ ។ ចៅក្រមសួរពីទំនាក់ទំនងរវាង ញ៉ែម សាន ដែលចូលរួមកាត់ទោស ប៉ុល ពត និង សាន ថាជាមនុស្សតែមួយឬយ៉ាងណា? តែសាក្សីថាមិនដឹងទេ ។ សាក្សីថាខ្លួនមិនដែលដឹងពីការកាត់ទោស ប៉ុល ពត ទេ ។ លោកចៅក្រមសួរសាក្សីមានបានប្រជុំជាមួយសានដែរទេ? សាក្សីថាមាន ប៉ុន្តែមិនមានបញ្ជីចាប់ខ្លួននោះទេ ។ ចំពោះមន្ទីរសន្តិសុខនៅតំបន់ ១០៥ សុភា ជាប្រធានសន្តិសុខ តើមានអនុ ឈ្មោះ វៀង ហៅ ខាន់ ដែរទេ? «អត់ទេ» សាក្សីឆ្លើយ ។

លោកចៅក្រមសួរអំពីទំនាក់ទំនងឈ្មោះ សៅ ចំពី ហៅ មុាំង ។ សាក្សីបានឆ្លើយថា សៅ ចំពី មាននាទីជាសមាជិកនៅក្នុងវរៈរបស់ តាវៀង និងជាប្អូនរបស់លោកហើយពេលនោះលោកមានទំនាក់ទំនងជាបងប្អូនធម្មតាប៉ុណ្ណោះ ។ សាក្សីបានទទួលស្គាល់ការលើកឡើងរបស់លោកចៅក្រម ឡាវ៉ែញ ដែល បានអានឯកសារស្ដីអំពីការប្រជុំជាមួយ តាឡាំង ស្ដីពីការការពារព្រំដែន ទឹកដី កុំឲ្យវៀតណាមចូលមក ។ តាមរយៈចម្លើយរបស់សាក្សីបានជម្រាបថា តាឡេង ជាអ្នកកាន់គុកមកពីមណ្ឌលគិរី ហើយគុកនោះនៅផ្ទាល់ដីដែលមានអ្នកទោសស្លៀកពាក់ធម្មតា និងមិនមានដាប់ច្រវ៉ាក់ទេ ។ ចៅក្រមអានឯកសារ ទូរលេខ៩៥ ដែលចម្លងជូន អ៊ំវ៉ាន់,អ៊ំវន, នួន ជា និងមន្ទីរឯកសារ ។ សាក្សីបានជម្រាបវិញថា បានសរសេរមែន តែមិនមានដាក់ឈ្មោះទេ មានតែឈ្មោះ ប៉ុល ពត ប៉ុណ្ណោះ ។

## ៣) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដី

### ៣.១) ការសួរដេញដោលដោយក្រុមមេធាវីការពារក្ដី នួន ជា

លោកមេធាវីអន្តរជាតិ ហ្សាស្តើ ប៉ាវ បានចាប់ផ្ដើមសួរសំណួរទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់អាមេរិក ។ សាក្សីបាន

បញ្ជាក់ថា ជាការពិតលោកបានឃើញមានការទម្លាក់គ្រាប់បែកដោយអាមេរិកនៅអំឡុងឆ្នាំ១៩៧០ដល់៧៥ ដោយប្រើគ្រាប់បែកបេ៥២ទៀតផង ។ ការទម្លាក់គ្រាប់បែកនេះធ្វើឡើងមកលើផ្ទះសំបែងប្រជាជន ហើយនៅតាមព្រៃដែនវិញ គឺទម្លាក់មកលើចំការក៏មានដែរ មិនតែប៉ុណ្ណោះនៅតាមភូមិខ្លះនៅសល់មនុស្សតែពីរឬបីនាក់ទេ ចំណែកគ្រួសាររបស់សាក្សីវិញ គឺស្លាប់អស់សមាជិក១១នាក់ ។ សាក្សីបានបញ្ជាក់ថាការស្លាប់គឺមានច្រើនជាងអ្នករបួស ចំណែកសាកសពត្រូវបានគេយកទៅកប់ដែរ ។ មេធាវីបន្តសួរថាតើការជម្លៀសនោះធ្វើឡើងដោយសារគេចគ្រាប់បែក ឬដោយសារមូលហេតុផ្សេង? សាក្សីបានឆ្លើយថា មិនមានការជម្លៀសទេ គឺនៅពេលមានទម្លាក់គ្រាប់បែកប្រជាជននាំគ្នារត់ចេញពីផ្ទះសម្បែង និងភូមិស្ថានតែម្តង ។ តាមការចងចាំរបស់លោក សារុន បានបញ្ជាក់ថាការទម្លាក់គ្រាប់បែកនេះមានទាំងយប់ទាំងថ្ងៃ ហើយមកម្តងៗ គឺមានឧទ្ធម្ភាគចក្របីគ្រឿង ។ លោកចាំថា មានវត្តមានទាហានអាមេរិកដែរនៅខាងស្រុកកែវសីម៉ា ស្ថិតនៅព្រំប្រទល់ខេត្តក្រចេះ ។ មេធាវីបន្តសួរផ្តោតលើមូលហេតុនៃកាទម្លាក់គ្រាប់បែកនៅខេត្តមណ្ឌលគិរី ប៉ុន្តែត្រូវបានលោកតំណាងសហព្រះរាជអាជ្ញា ឌែល លីសាក់ ធ្វើការជំទាស់ដោយសារសំណួរនេះគឺសួរពីយោបល់របស់សាក្សី ។ លោកមេធាវី ហ្សាស្តេ ប៉ាវ បានប្តូរវិធីសាស្ត្ររបស់ខ្លួនដោយការដាក់បង្ហាញឯកសារកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនិយាយពីការសំអាតខ្មាំងនៅខេត្តមណ្ឌលគិរីក្នុងឆ្នាំ១៩៧០ ។ លោកប្រធានបានរំឭកដល់មេធាវីដើម្បីបញ្ជាក់អំពីឯកសារដែលបង្ហាញ ថាវាមានភាពពាក់ព័ន្ធនឹងឯកសារ៣នៅចំពោះមុខអង្គជំនុំជម្រះ ។ ភ្លាមៗ តំណាងសហព្រះរាជអាជ្ញាក៏បានក្រោកឈរដើម្បីបញ្ជាក់ជូនអង្គជំនុំជម្រះថាឯកសារនោះបានប្រើជាឯកសារឧបសម្ព័ន្ធ ដូច្នេះខ្លួនមិនមានការជំទាស់ឡើយ ។

លោកមេធាវីបានអានឯកសារដែលនិយាយអំពីការទម្លាក់គ្រាប់បែកនៅមណ្ឌលគិរី ។ លោកមេធាវីបានសួរថាតើលោក បានដឹងពីសំណើដែល លន់ នល់ ស្នើឲ្យអាមេរិកមកទម្លាក់គ្រាប់បែកនៅមណ្ឌលគិរីឬទេ? សាក្សីបានបញ្ជាក់ថាខ្លួនមិនដឹងពីបញ្ហានេះទេ គឺគ្រាន់តែឃើញមានការទម្លាក់គ្រាប់បែកប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់ថាការទម្លាក់នោះនៅតាមភូមិចាស់កាន់តែទម្លាក់ខ្លាំងឡើង ។ សាក្សីបាន បន្តថាខ្លួនមិនដែលឮគេនិយាយពីមូលហេតុនៃការទម្លាក់គ្រាប់បែកនោះទេ ។ បន្ទាប់មកលោកមេធាវីបានប្តូរប្រធានបទ ដោយសួរទាក់ទងនឹងការប្រជុំនៅទីក្រុងភ្នំពេញប្រហែល១០ថ្ងៃ ក្រោយរំដោះភ្នំពេញឆ្នាំ១៩៧៥ ។ អ្នកដែលឧទ្ទេសនាមនៅក្នុងអង្គប្រជុំនោះគឺមានតែ ប៉ុល ពត ម្នាក់ប៉ុណ្ណោះ ។ ការប្រជុំ នោះកើតឡើងបន្ទាប់ពីការស្លាប់របស់ ឡាំង និង ខាំ ភួន ។ សាក្សី បានបញ្ជាក់ថាខ្លួនពិតជាបានទៅចូលរួមប្រជុំនៅពេលនោះមែន ហើយអ្នកដែលចូលរួមនោះមានច្រើននាក់ គឺប្រជុំសន្និបាតឆ្នាំ១៩៧៨ ។ សាក្សីបានបន្តថាលោកស្គាល់មេដឹកនាំដែលបានចូលរួមនៅក្នុងមហាសន្និបាតនោះនៅពេលដែលអ្នក ទាំងនោះត្រូវបានគេអញ្ជើញឲ្យឡើងលើវេទិកាប៉ុណ្ណោះ ដែលមានដូចជា ប៉ុល ពត, នួន ជា និង អៀង សារី ។ សាក្សីបានបន្តថាខ្លួនទទួលសារទូរលេខពីមជ្ឈិមនោះគឺពី ប៉ុល ពត ។ មេធាវីបានសួរ បញ្ជាក់ថាតើសាក្សីមានការលាក់លៀមពីតួនាទីរបស់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សាក្សីថាខ្លួនមិនមានអ្វីលាក់លៀមនោះទេ ។ មេធាវីបានបង្ហាញឯកសារដែលដកស្រង់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការបោសសំអាតខ្មែរក្រហមនៅមណ្ឌលគិរីសារជាថ្មីម្តងទៀត ដែលមានខ្លឹមសារថា “...បន្ទាប់ពីលោក សារុន ឡើងជាលេខាតំបន់នោះមានការសម្លាប់រង្គាលមានការចាប់ខ្លួនប្រជាជន..” ។ សាក្សីបានបញ្ជាក់ថាការលើកឡើងនេះមិនមែនជាការពិតទេ អ្នកដែលឆ្លើយបែបនេះគឺមួលបង្កាច់លោកប៉ុណ្ណោះ លោកមិនដែលចាប់ប្រជាជនយកទៅសម្លាប់ទេ លោកសូមបដិសេធការលើកឡើងនេះ ។ លោកមេធាវីបានលើកឡើងពីអត្ថបទរបស់លោក ស៊ីវ ហេឌ័រ ដែលនិយាយពីលេខាស្រុក ជាតួនាទីសំខាន់ក្នុងការសម្លាប់នោះ ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនយល់ស្របនោះទេដោយសារការគ្រប់គ្រងនៅក្នុងស្រុករបស់ខ្លួន និងនៅស្រុកផ្សេងគឺមានលក្ខណៈខុសគ្នា ។ សាក្សីបានបន្តថាតាំងពីខ្លួនមកកាន់អំណាចពីរខែនោះមិនដែលមានការចាប់ ឬសម្លាប់ប្រជាជនឡើយ ។

មេធាវីស្នើសុំប្រើឯកសារសក្ខីកម្មសាក្សី TCW-៣០៧ ដើម្បីសាកសួរលើសាក្សី សៅ សារុន ។ នៅក្នុងការលើកយកសក្ខីកម្មសាក្សីផ្សេងមកសួរនេះ លោកប្រធានអង្គជំនុំជម្រះបានសួរបញ្ជាក់

ទៅមេធាវីថាតើឯកសារនេះមាននៅក្នុងសំណុំរឿងក្តី០០២ហើយឬនៅ? លោកមេធាវីបានឆ្លើយតបថា ឯកសារនេះមាននៅក្នុងបណ្តុំឯកសារ គឺនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ប៉ុន្តែលោកមិនដឹងថាវាស្ថិតនៅក្នុងបញ្ជីឯកសារដែលដាក់ដោយភាគីឬអត់ទេ ។ អង្គជំនុំជម្រះបានធ្វើការរំឭកដល់ក្រុមមេធាវីការពារក្តី នួន ជា ឲ្យបញ្ជាក់ជូនអង្គជំនុំជម្រះនៅពេលដាក់បង្ហាញ គឺត្រូវបញ្ជាក់ពីបញ្ជីឯកសារណាមួយរបស់ភាគីណាមួយ ចំណែកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមានការជំទាស់ដែរ ។ លោកប្រធានក៏បានអនុញ្ញាតឲ្យមេធាវីការពារក្តីប្រើប្រាស់ឯកសារក្នុងកំរិតមួយដើម្បីសួរដេញដោលសាក្សី ហើយលោកប្រធានក៏បានបញ្ជាក់ដល់មេធាវីឲ្យមានការធានាកុំឲ្យមានការបញ្ចេញព័ត៌មានសម្ងាត់ ដែលអាចប៉ះពាល់ដល់សាក្សី ដូចជាការបញ្ចេញឈ្មោះជាដើម ។ មេធាវីបានបញ្ជាក់ថាខ្លួននឹងមិនបញ្ចេញព័ត៌មានលើអេក្រង់ទេ ដោយគ្រាន់តែអានប៉ុណ្ណោះ ។ មេធាវីបានសួរពីការចាប់មនុស្សមួយគ្រួសារយកទៅសម្លាប់ ។ សាក្សីបានបដិសេធថាមិនដែលមានការចាប់ខ្លួនមនុស្សទាំងគ្រួសារយកទៅសម្លាប់នោះទេ ។ មេធាវីបានបន្តសំណួរថានៅពេលដែលសាក្សីគ្រប់គ្រងនៅតំបន់៥ គឺដោយមានការចោទប្រកាន់ថាចេះមន្តអាគមន៍ ។ សាក្សីថាមិនដែលមានការចាប់ខ្លួនដោយសារការចេះប្រើមន្តអាគមន៍នោះទេ ។ លោកប្រធានបានសាកសួរមេធាវី ទាក់ទងនឹងអត្ថបទរបស់ ស៊ីវ ហេង៉ វ ដែលមេធាវីលើកឡើង ប៉ុន្តែមេធាវីបានបញ្ជាក់ថាខ្លួនមិនដឹង ថាឯកសារនោះមាននៅក្នុងសំណុំរឿងដែរឬអត់នោះទេ ។ តំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការដកស្រង់មួយផ្នែកនៃឯកសារនោះពិតជាមាននៅក្នុងសំណុំរឿង ។ លោកប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន បានរំឭកដល់ក្រុមមេធាវី នួន ជា ក្នុងការបញ្ជាក់លេខឯកសារដែលខ្លួនលើកឡើងមកបញ្ជាក់នោះឲ្យមេធាវីបញ្ជាក់ថា ឯកសារនោះបានដាក់នៅក្នុងបញ្ជីណាមួយនៃឯកសារដែលស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះ និងបង្ហាញពីអត្តសញ្ញាណរបស់ឯកសារជាបីភាសាផង ។ លោកប្រធានបានបញ្ជាក់ផងដែរថា ឯកសារដែលភាគីទាំងឡាយបានដាក់នៅក្នុង“អ៊ីនធីហ្វេស” មិនមានន័យថា ឯកសារនោះជំនួយឲ្យមានការអនុវត្តនៅវិធាន ៨៧(៤) ទេ ។ វិធាន៨៧(៤) គឺនៅតែមាន តម្លៃជាច្បាប់ស្តីពីនីតិវិធីនៃការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ។ ចំណែកឯឯកសារដាក់នៅក្នុងអ៊ីនធីហ្វេសសម្រាប់ភាគីទទួលព័ត៌មានបានមុនពេលដេញដោលនេះ គ្រាន់តែការជួយសម្រួលព័ត៌មានដើម្បីត្រៀមលក្ខណៈជាមុនបានពិនិត្យមើលឯកសារពាក់ព័ន្ធជាមុនដើម្បីពេលចូលមកដេញដោល គឺមានល្បឿន និងមានប្រសិទ្ធភាពប៉ុណ្ណោះ ។ ឯកសារទាំងអស់ត្រូវតែអនុវត្តត្រឹមត្រូវតាមនីតិវិធីនៅក្នុងវិធាន៨៧(៤) និងភ្ជាប់និងវិធាន៨៧(៣) អំពីលក្ខណៈពាក់ព័ន្ធនៃភស្តុតាង ។

លោកមេធាវីបានបន្តការសួរទាក់ទងនឹងកិច្ចប្រជុំដែលសាក្សីបានចូលរួមនៅទីក្រុងភ្នំពេញក្រោយការស្លាប់របស់ ឡាំង ហើយសាក្សីបានផ្តល់ចម្លើយជាមួយសហព្រះរាជអាជ្ញាថាមិនបានជួប ប៉ុល ពត នោះទេ ។ តំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថាការដកស្រង់របស់មេធាវីគឺគ្រាន់តែជាការដកស្រង់មួយផ្នែកប៉ុណ្ណោះដូច្នេះចំណុចខ្លះមានភាពខុសគ្នា ។ លោកប្រធានមិនអនុញ្ញាតឲ្យសាក្សីឆ្លើយ ដោយសារសំណួរច្រំដែល ។

## ៣.២) ការសួរដេញដោលដោយក្រុមមេធាវីការ ពារក្តី ខៀវ សំផន

មេធាវី អាកទូ វ៉ែកកែន បានសួរសាក្សីទាក់ទងនឹងសារទូរលេខទី១ដែលផ្ញើទៅមន្ទីរ៨៧០ ថាតើជូនទៅនរណា? សាក្សីបានបញ្ជាក់ថាសារទូរលេខពីលេខទីមួយដល់លេខទី៤ គឺផ្ញើជូន ប៉ុល ពត ។ មេធាវីបានសួរសាក្សីទៀតថាតើហេតុអ្វីបានជាសាក្សីផ្ញើឯកសារទៅ ប៉ុល ពត? លោកសារុន បានបញ្ជាក់ថាដោយសារ ប៉ុល ពត គឺជាមេ ដូច្នេះខ្លួនត្រូវតែរាយការណ៍ជូនថ្នាក់ លើបែបនេះហើយ ។ មេធាវីបានអានពីការសម្ភាសន៍របស់សាក្សីជាមួយចៅក្រមស៊ើបអង្កេតដែលបញ្ជាក់ថាសាក្សីបានជួបពិភាក្សាគ្នាជាមួយ ខៀវ សំផន អំពីបញ្ហាសេដ្ឋកិច្ច ។ សាក្សីបញ្ជាក់ថាខ្លួនបានជួបជនជាប់ចោទ ខៀវ សំផន ម្តង ហើយសំណេះសំណាលពីការដាំដុះតែប៉ុណ្ណោះ ហើយខ្លួនមិនដែលបានជូនបញ្ជីសេដ្ឋកិច្ចដល់ ខៀវ សំផន នោះទេ ។ សាក្សីបានបន្ថែមថា នៅពេលខ្លួនផ្តល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេតនោះមានការខុសខ្លះៗ ដោយសារកាលនោះខ្លួនមានជំងឺ និងមានការភ្លេចភ្លាំងច្រើន ។

គួរកត់សម្គាល់ថាក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី មិនមានសំណួរទៅកាន់សាក្សី សៅ សារុន ទេដូច្នេះបន្ទាប់

ពីក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានសួរចប់សព្វគ្រប់ លោកប្រធានអង្គជំនុំជម្រះបានប្រកាសបិទសវនាការសម្រាប់ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១២ តែម្តង ។

## V) សវនាការស្តីពីការស្តាប់សក្ខីកម្មរបស់សាក្សី ខឹម ង៉ន

នៅរសៀលថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដោយធ្វើការសាកសួរសាក្សី ខឹម ង៉ន ដែលមានរហ័សនាម TCW-៣២៣ ។ កិច្ចដំណើរការនេះបានចាប់ផ្តើមបន្ទាប់ពីមានការផ្អាកកិច្ចដំណើរ ការសាកសួរសាក្សី សៅ សារុន ដោយសារបញ្ហាសុខភាព ។ មុនពេលចាប់ផ្តើម លោកមេធាវី ពេជ អង្គ ជាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជម្រាបជូនអង្គជំនុំថា ខ្លួននឹងផ្ទេរការសួរសាក្សីជូន លោកមេធាវី ឡោ ជុនធី និង លោក បាណាបេ ។



សាក្សី ខឹម ង៉ន

### ១) ប្រវត្តិសាវតារសាក្សី ខឹម ង៉ន

កិច្ចដំណើរការបានចាប់ផ្តើមដោយលោកប្រធានអង្គជំនុំជម្រះសាកសួរព័ត៌មានទាក់ទងនឹងប្រវត្តិសវតាររបស់សាក្សី ។ សាក្សីបានបញ្ជាក់ថាខ្លួនមានឈ្មោះ ខឹម ង៉ន អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅស្រុកបុរីជលសារ ខេត្តតាកែវ ប្រកបរបរលក់នំគ្រោត រត់ម៉ូតូឌុប និងធ្វើស្រែ ហើយខ្លួនមិនបានរៀន សូត្រច្រើនទេត្រឹមថ្នាក់ទីដប់ពីជំនាន់មុនតែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថាខ្លួនមានឪពុកឈ្មោះ ឌុក អ៊ិត ម្តាយ ឈ្មោះ ជា រិន ហើយខ្លួនមានកូន១០នាក់ ។ លោកប្រធានបានធ្វើការណែនាំសាក្សីអំពីសិទ្ធិ និងករណីកិច្ចរបស់សាក្សីនៅក្នុងការផ្តល់សក្ខីកម្ម និងធ្វើការរំឭកដល់ភាគីក្នុងការរៀបចំសំណួរឲ្យបានល្អងាយស្រួលឲ្យសាក្សីយល់ ។ បន្ទាប់មកលោកប្រធានបានផ្ទេរវេទិកាជូនសហព្រះរាជអាជ្ញាដើម្បីសាកសួរបន្ត ។

### ២) ការសួរដេញដោលដោយសហព្រះរាជអាជ្ញា

លោកសហព្រះរាជអាជ្ញារងជាតិ ចាន់ តារាវស្មី បានចាប់ផ្តើមសួរពីប្រវត្តិខ្លះៗរបស់សាក្សីនៅមុនឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនប្រកបរបរជាកសិករនិងរត់ម៉ូតូឌុប នៅស្រុកកោះអណ្តែត ។ សាក្សីបានបន្ថែមទៀតថាខ្លួនបានចូលរួមចលនាបដិវត្តជាមួយមិត្តភក្តិតាំងពីអាយុប្រហែល១៦ឆ្នាំធ្វើជាទាហាននៅក្នុងភូមិ ហើយក្រោយមកខ្លួនត្រូវបានបញ្ជូនទៅធ្វើទ័ពស្រុកពីរទៅបីខែ ទើបត្រឡប់ទៅធ្វើជាប្រធានក្រុម និងធ្វើនិរសារនៅភូមិឃុំនិងស្រុក ។ នៅពេលរំដោះបានខេត្តតាកែវ នៅឆ្នាំ១៩៧៥ខ្លួននិងទ័ពប្រាំនាក់ទៀតត្រូវបានបញ្ជូនទៅភ្នំពេញដោយស្នាក់នៅស្ថានទូតចិន និងរៀននៅសាលាបច្ចេកទេសសូវៀតរយៈពេលមួយសប្តាហ៍ ហើយក្រោយមកខ្លួនត្រូវបានបញ្ជូន ទៅធ្វើការនៅក្រសួងការបរទេសជាអ្នកបំរើភ្ញៀវ ។ សហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងការចូលធ្វើកងទ័ពមុនឆ្នាំ១៩៧៥ ។ លោក ង៉ន បានបញ្ជាក់ថាខ្លួនចូលបំរើកងទ័ពដោយសារគេហៅឲ្យចូលធ្វើ ហើយពេលនោះខ្លួនក៏ដឹងថាអ្វីជាបដិវត្ត ឬខ្មែរក្រហមនោះទេ ។ សហព្រះរាជអាជ្ញារងបានបន្ត សំណួរទាក់ទងនឹងការបំពាក់បំប៉នយោបាយ នៅមុនឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថាខ្លួនបានទទួលការបំពាក់បំប៉ននយោបាយដែលកាលនោះមាន ឆួយ ជាអ្នកហៅទៅប្រជុំ ហើយខ្លឹមសារនៅពេលប្រជុំកាលនោះគឺគេអប់រំមិនឲ្យហូបបាយ ឬកេសជ្ជៈដែលសល់ពីភ្ញៀវ ។ ក្រៅពីនោះទៀតខ្លួនមិនធ្លាប់បានចូលប្រជុំជាមួយមេដឹកនាំធំឡើយដោយសារអ្នកដែលចូលរួមបានគឺទាហានដែលនៅក្នុងសម្ព័ន្ធយុវកកដែលជាកំលាំងស្នូលតែប៉ុណ្ណោះ ។ លោកសហព្រះរាជអាជ្ញាបាន បន្តសំណួរទាក់ទងនឹងការសរសេរប្រវត្តិរូប ។ លោក ង៉ន បានបញ្ជាក់ថា ខ្លួនបានធ្វើប្រវត្តិរូបមួយថ្ងៃបីដង ហើយខ្លួនមានការបារម្ភចំពោះសាច់ញាតិខ្លួនដែរដោយសារខ្លួនមានជាប់ខ្សែស្រឡាយក្បត់ ប៉ុន្តែក្រោយមកលោកបានដឹងថាបងប្អូនគាត់ត្រូវបានគេយកទៅសម្លាប់ ។ សាក្សីបានបន្តទៀតថា នៅមុនឆ្នាំ១៩៧៥ ខ្លួន

មិនមែនជាសមាជិកនៅក្នុងបក្សសម្ព័ន្ធយុវជនទេ គឺគ្រាន់តែជាយុទ្ធជនប៉ុណ្ណោះ ហើយនៅពេលនោះខ្លួនក៏ធ្លាប់បានទទួលការអប់រំឲ្យគោរពតាមវិន័យបក្ស ។ លោក ឆន បានរំឭកដែរថានៅពេលធ្វើជានិរសារ ខ្លួនត្រូវបាន សាន និង សៀង ប្រាប់ឲ្យរត់សំបុត្រឲ្យទាន់ពេលវេលា ។ សាក្សីបានបន្តថាខ្លួនធ្លាប់ត្រូវបានយកទៅកសាងនៅពេលមានកំហុស ។ នៅជំនាន់នោះសាក្សីបានបញ្ជាក់ថាខ្លួនធ្លាប់បានឮពាក្យថាការតស៊ូវណ្ណៈ មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែខ្លួនមិនយល់ថាមានន័យយ៉ាងម៉េចនោះទេទាក់ទងនឹងការរំដោះខេត្តតាកែវ សាក្សីបានបញ្ជាក់ថាខ្លួនពិតជាបានឮ ហើយនៅមុនឆ្នាំ ១៩៧៥ ខ្លួនបានឃើញមានការបញ្ជូនប្រជាជនមកក្រោយនៅស្រុកកោះអណ្តែត ប៉ុន្តែខ្លួនមិនដឹងថាប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅទីណាទេ ។ បន្ទាប់ពីបញ្ចប់ការសាកសួររបស់សហព្រះរាជអាជ្ញារងជាតិ លោកប្រធានបានផ្ទេរវេទិកាជូនលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន ដឺវ៉ាល់ ដើម្បីបន្តការសាកសួរដោយលោកបានរំឭកដល់តំណាងសហព្រះរាជអាជ្ញាឲ្យរៀបចំសំណួរដែលងាយស្រួលឲ្យសាក្សីបានយល់ ។ លោកតំណាងសហព្រះរាជអាជ្ញាបានចាប់ផ្តើមដោយការអានសេចក្តីដកស្រង់បទសម្ភាសន៍ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងសាក្សីទាក់ទងនឹងការរំដោះខេត្តតាកែវតាកែវដែលសាក្សីបានឃើញ ។ សាក្សីបានបញ្ជាក់ថា ខ្លួនពិតជាបានឃើញពីការរំដោះដែលនៅពេលនោះខ្លួនបានឮគេនិយាយថា បើប្រជាជនមានការរឹងទទឹងនឹងត្រូវគេយកទៅសម្លាប់ចោលប៉ុន្តែខ្លួនមិនបានដឹងថាជាអ្នកបញ្ជានោះទេ ។ លោកព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងការរៀនសូត្រនៅទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបានបញ្ជូនមករៀននៅសាលាបច្ចេកទេសសូវៀត ហើយគេបញ្ជូនទៅនៅតាមស្ថានទូត ផ្ទះលេខ៧ ជាមួយភ្ញៀវចិន ដែលនៅទីនោះ ហុង បានហៅខ្លួនទៅប្រជុំប្រាប់មិនឲ្យនិយាយអ្វីទាក់ទងនឹងរឿងនយោបាយ និងអប់រំពីការដើរហើរ ហូបចុកឲ្យបានសមរម្យពេលនៅជាមួយភ្ញៀវ ។ សាក្សីបានបន្តថា នៅពេលប្រព្រឹត្តកំហុសគឺត្រូវបញ្ជូនមកក្រោយ ឬផ្លាស់កន្លែងធ្វើការងារ ហើយខ្លួនក៏ធ្លាប់បានប្រព្រឹត្តកំហុសម្តងដែរក្នុងរយៈពេលមួយឆ្នាំ ធ្វើការនៅក្រសួងការបរទេស ហើយត្រូវបានបញ្ជូនឲ្យទៅដាំបន្លែនៅតាខ្មៅរយៈពេលបី ឬបួនខែទើបត្រលប់មកវិញ ។ សាក្សីបានបញ្ជាក់ថា កន្លែងធ្វើការងារនៅតាខ្មៅនោះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ហើយអ្នកដែលត្រូវបញ្ជូនទៅទីនោះ គឺមានមកពីតាមជនបទខ្លះដែរ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការធ្វើប្រវត្តិរូប លោក ឆន បានបញ្ជាក់ថា ហុង ដែលជាអ្នកគ្រប់គ្រងនៅផ្ទះលេខ៧ជាអ្នកបញ្ជាឲ្យខ្លួនធ្វើប្រវត្តិរូបពេលមកធ្វើការនៅក្រសួងការបរទេស ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាបានសួរទាក់ទងនឹងការប្រជុំនៅផ្ទះលេខ៧ សាក្សីបានបញ្ជាក់ថាខ្លួនត្រូវបានអប់រំពីរបៀបរស់នៅជាមួយភ្ញៀវ ហើយក្រៅពីការប្រជុំនៅផ្ទះលេខ៧ខ្លួនមិនដែលចូលប្រជុំនៅកន្លែងផ្សេងទៀតនោះទេ ពីព្រោះគេលាក់ការណ៍សំងាត់ ហើយមន្ទីរដែលសំខាន់នៅក្រសួងការបរទេសគឺមន្ទីរប-១ ។ នៅក្នុងក្រសួងការបរទេសមានអ្នកស៊ើបការណ៍សំងាត់ ហើយប្រសិនបើនរណាម្នាក់នៅក្នុងក្រុមប្រព្រឹត្តកំហុស គឺនឹងត្រូវរាយការណ៍ទៅថ្នាក់លើ ។

## ៣) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញា លោកប្រធានបានផ្ទេរវេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ លោកមេធាវី ឡោ ជុនធី បានចាប់ផ្តើមដោយការសាកសួរទាក់ទងនឹងលំនៅស្ថានរបស់សាក្សីនៅមុនពេលបែកឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា ខ្លួនរស់នៅខេត្តតាកែវធ្វើជាឈ្លប ហើយក្រោយមកធ្វើជាទ័ពនៅក្នុងភូមិ ។ ក្រោយពេលបែកក្រុងតាកែវខ្លួន បានទៅនៅភ្នំពេញ ហើយទទួលបានការរៀនសូត្រនិងធ្វើការនៅក្រសួងការបរទេស ។ លោកមេធាវីបានបន្តសំណួរទាក់ទងនឹងការចោទប្រកាន់ពីបទខុសសីលធម៌ ហើយសាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបាន ភៀង ជាអនុប្រធានមន្ទីរ ទិតៀនថាខុសសីលធម៌ដោយសារបានជជែកលេងជាមួយនារីៗ ហើយលោកត្រូវបានដកចេញពីការងាររយៈពេលបីខែ ។ លោកមេធាវីបានបន្តសំណួរទាក់ទងនឹងការបោសសម្អាតសមាជិកគ្រួសាររបស់សាក្សី ។ ជាការឆ្លើយតប លោក ឆន បានបញ្ជាក់ថា ខ្លួនបានទទួលដំណឹងពីបងប្អូនជីដូនមួយថាប្រពន្ធរបស់ខ្លួនត្រូវបានសម្លាប់ ហើយខ្លួនត្រូវបានបញ្ជូនទៅតាខ្មៅ ដោយសារតែសាច់ញាតិរបស់ខ្លួនត្រូវបានគេសម្លាប់ ។ ក្នុងនោះ លោកមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានក្រោកឈរហើយជំទាស់ថា

សំណួរដែលមេធាវីកំពុងសួរនោះ សុទ្ធតែត្រូវបានសាកសួរដោយសហព្រះរាជអាជ្ញារួចទៅហើយ ប៉ុន្តែលោកមេធាវីបានបញ្ជាក់ថាខ្លួនបានលើកយកសំណួរដែលសហព្រះរាជអាជ្ញាមិនទាន់បានសួរតែប៉ុណ្ណោះ ។ ទាក់ទងនឹងបញ្ហានេះ លោកប្រធានអង្គជំនុំជម្រះបានរំឭកដល់មេធាវីឲ្យសួរសំណួរដែលទាក់ទងនឹងអង្គហេតុនៅក្នុងដីកាដំណោះស្រាយ ។ បន្ទាប់មកលោកមេធាវីបានបញ្ចប់ការសាកសួររបស់ខ្លួន លោកប្រធានបានផ្ទេរវេទិកាជូនមេធាវី បុណណាបេ ដោយបានរំឭកសារជាថ្មីឲ្យមេធាវីរៀបចំសំណួរច្បាស់ៗ ហើយទាក់ទងនឹងអង្គហេតុ ។ លោកមេធាវីបានចាប់ផ្តើមដោយសួរសំណួរទាក់ទងនឹងស្ត្រីឈ្មោះ ធី ដែលបាននិយាយប្រាប់សាក្សីអំពីការបោសសម្អាតនៅក្រសួងការបរទេស ។ សាក្សីបានបញ្ជាក់ថាខ្លួនពិតជាបានស្គាល់ឈ្មោះ ធី ហើយបានរស់នៅជាមួយគ្នា ប៉ុន្តែខ្លួនមិនបានយល់ពីការបោសសំអាតនៅក្រសួងការបរទេសនោះទេ ។ លោកមេធាវីបានបន្តសំនួរដោយអានឯកសារសម្ភាសន៍ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងសាក្សីទាក់ទងនឹងការចាប់ខ្លួនមនុស្សនៅមន្ទីរប-១សាក្សីបានបញ្ជាក់ថា ធី ធ្លាប់ប្រាប់ខ្លួនពីការផ្លាស់កន្លែងប៉ុន្តែខ្លួនមានមិនចងចាំច្រើនទេ ។

### ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី នួន ជា

លោកមេធាវី ផេស្តមេន បានចាប់ផ្តើមសំណួរទាក់ទងនឹងឯកសារបទសំភាសន៍របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ២០០៤ ប៉ុន្តែសាក្សីមានការភាន់ច្រលំដោយឆ្លើយពីការរស់នៅរបស់ខ្លួនកាលពីសម័យខ្មែរក្រហមទៅវិញ ។ មេធាវីបានបង្ហាញឯកសារដើម្បីរំឭកដល់ការចងចាំរបស់សាក្សី ប៉ុន្តែលោកប្រធានបានសួរបញ្ជាក់ឲ្យមេធាវីបង្ហាញឯកសារដើម្បីបញ្ជាក់ថា ឯកសារនោះត្រូវបានដាក់នៅចំពោះមុខអង្គជម្រះស្របតាមវិធាន៨៧(៣) ។ លោក ផេស្តមែន បានបញ្ជាក់ថា ឯកសារនោះត្រូវបានដាក់នៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់តុលាការកាលពីឆ្នាំ២០១១ ហើយឯកសារនេះព្រះរាជអាជ្ញាក៏មានរួចហើយដែរ ។ លោកមេធាវីបានបន្តដោយការអានបទសម្ភាសន៍ទាក់ទងនឹងការប្រជុំជាន់ខ្ពស់ដែលមាន ប៉ុល ពត, អៀង សារី, សុន សេន, តា ម៉ុក, នួន ជា និងសម្តេច ហ៊ុន សែន ។ ទាក់ទងនឹងបញ្ហានេះសាក្សីបានបដិសេធថា ខ្លួនមិនដែលដឹងពីបទសម្ភាសន៍នោះឡើយ ។ មេធាវីបានបន្តសំណួរថាតើសាក្សីបានដឹងថា ហ៊ុន សែន បានចូលរួមប្រជុំដែរទេ ។លោកប្រធានបានរំឭកដល់មេធាវីមិនឲ្យសួរសំណួរដែលទាក់ទងនឹងកំរងសំណួរទាំងនោះទេ ។ លោកមេធាវីបានបន្តការសួរទាក់ទងនឹងការភ័យខ្លាចរបស់សាក្សីក្នុងការឆ្លើយទាក់ទងនឹង ហ៊ុន សែន ។ លោកប្រធានបានបង្គាប់មិនឲ្យសាក្សីឆ្លើយដោយសារសំណួរមិនពាក់ព័ន្ធហើយសាក្សីបានបដិសេធរួចទៅហើយ ។ លោកមេធាវីនៅតែ ទទូចសុំលោកប្រធានឲ្យសាក្សីឆ្លើយតែលោកប្រធាននៅតែមិនអនុញ្ញាត ហើយមេធាវីបានបញ្ចប់ការសួររបស់ខ្លួន ។

បន្ទាប់ពីបញ្ចប់សំណួររបស់ក្រុមមេធាវីរបស់ នួន ជា លោកប្រធានបានផ្តល់វេទិកាជូនលោក មេធាវី អៀង សារី ប៉ុន្តែលោកមេធាវីមិនមានសំណួរទៅកាន់សាក្សីទេ ចំណែកក្រុមមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន ក៏មិនមានសំណួរដែរ ។ ដូច្នេះការសួរសាក្សី ខឹម ងន ត្រូវបានបញ្ចប់ ។ សម្រាប់ពេលនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោក អឿន តាន ។

### VI) សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី អឿន តាន

បន្ទាប់ពីការស្តាប់សក្ខីកម្មរបស់សាក្សី ឃឹម ងន បានបញ្ចប់ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តស្តាប់សក្ខីកម្មរបស់សាក្សី អឿន តាន អតីតនិរសារ និងកងការពាររបស់ ប៉ុល ពត ។ សវនាការប្រព្រឹត្តទៅចំនួនពីរថ្ងៃ មានប្រជាជនកម្ពុជាប្រមាណ៤០០នាក់មកពីខេត្តកណ្តាល និងស្វាយរៀង ចូលរួមស្តាប់ដោយផ្ទាល់តាមរយៈការអញ្ជើញរបស់មន្ត្រីកិច្ចការសាធារណៈរបស់ តុលាការ ។

ដោយសាក្សីគឺជានិរសារ និងកងការពាររបស់ ប៉ុល ពត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភាគីបានផ្តោតសំខាន់អំពីសមាសភាពអ្នកចូលរួម និងកម្មវត្ថុដែលត្រូវបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំធំៗមួយចំនួនដែលត្រូវបានរៀបចំឡើងនៅមន្ទីរក-១, ជាពិសេសអំពីតួនាទីរបស់សាក្សីក្នុងការបញ្ជូនឯកសារពីថ្នាក់ក្រោមទៅ ប៉ុល ពត និងពី ប៉ុល ពត ទៅមេដឹកនាំផ្សេងៗទៀត និងការជូនដំណើរមេដឹកនាំទាំងនេះចុះទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានជាដើម ។ ក្រៅពីនេះមានសំណួរមួយចំនួនទៀតទាក់ទងនឹងប្រវត្តិសាវតារ និងគោលបំណង



សាក្សី អៀង គាន

របស់សាក្សីក្នុងការចូលរួមចលនាបដិវត្ត និងភារៈកិច្ចរបស់សាក្សីក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសួរនេះប្រព្រឹត្តទៅតាមលំដាប់ ដោយចាប់ផ្តើមពីតំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីក្រុម ។

## ១) ប្រវត្តិសាវតាររបស់សាក្សី

លោក អៀង គាន ហៅ ជូ គាន កើតក្នុងឆ្នាំ១៩៤៣ ជា ជនជាតិការចក់ ។ ទីលំនៅបច្ចុប្បន្ន ភូមិទន្ទ្រើក ឃុំតាសាញ ស្រុកសំឡូត ប្រកបមុខរបរធ្វើ ចំការ ចេះអាន និងសរសេរអក្សរខ្មែរតិចតួច ។ ឪពុកឈ្មោះ លូង និងម្តាយឈ្មោះ លឹម ។ លោក អៀង គាន មានកូនចំនួន៣ នាក់ ។ លោកបានចូលរួមក្នុងចលនាបដិវត្តនៅចន្លោះខែកុម្ភៈ និង មីនា ឆ្នាំ១៩៦៨ ក្រោមការណែនាំ របស់ ដៃ និង ទទួលស្គាល់ដោយ កងដែង ។ នៅឆ្នាំ១៩៦៨-១៩៧០ លោករស់នៅខេត្ត រតនៈគិរី ទទួលបន្ទុកបញ្ជូនសំបុត្រពីស្រុក អណ្តូងមាស ខេត្តរតនៈគិរី យកទៅ វើនសៃ និង ខេត្តមណ្ឌលគិរី ។ រហូតមកដល់ឆ្នាំ១៩៧០ លោកបានមករស់នៅជាមួយ ប៉ុល ពត នៅខេត្តកំពង់ចាម ដោយទទួលបន្ទុកជាអ្នករត់សំបុត្រ និងធ្វើជាកងការពារសន្តិសុខសម្រាប់ ប៉ុល ពត និងមេដឹកនាំផ្សេងៗទៀតក្រោមការចាត់តាំងរបស់ ប៉ង់ ។ ក្នុងតួនាទីនេះ លោកធ្លាប់បានការពារការកិច្ចប្រជុំមួយចំនួនធ្វើឡើងដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំផ្សេងៗទៀតនៅក្នុងខេត្តកំពង់ចាម ។ លោក អៀង គាន បញ្ជាក់យ៉ាងច្បាស់ថា លោកបានរស់នៅជាប់ជាមួយ ប៉ុល ពត ចាប់ពីឆ្នាំ១៩៧០ រហូតដល់របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំក្នុងឆ្នាំ១៩៧៩ ។ លោករស់នៅបែកពី ប៉ុល ពត រយៈពេលប្រហែលកន្លះខែ ដោយ ប៉ុល ពត ធ្វើដំណើរទៅទីក្រុងភ្នំពេញមុន ហើយលោកត្រូវនៅរៀបចំសម្ភារៈប្រើប្រាស់របស់មេដឹកបក្សកុម្មុយនីស្តកម្ពុជា ដោយយកទៅតាមក្រោយ ។ នៅពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៥ លោកបានមករស់នៅ មន្ទីរក-១ជាមួយ ប៉ុល ពត ដែលមានទីតាំងនៅជាប់ទន្លេបាសាក់ ក្នុងទីក្រុងភ្នំពេញ ។ ពេលនោះលោក ត្រូវបាន ប៉ង់ ចាត់តាំងឲ្យធ្វើជាប្រធានក្រុមកងការពារសន្តិសុខផ្នែកខាងក្នុងនៅមន្ទីរក-១ ។ ការងារសំខាន់បំផុតរបស់លោក គឺការពារសន្តិសុខសម្រាប់កិច្ចប្រជុំដែលត្រូវបានរៀបចំឡើងនៅមន្ទីរក-១ និងការបញ្ជូនសំបុត្រ ឬសារទូរលេខ សម្រាប់ ប៉ុល ពត ។ ក្រៅពីនេះ លោក អៀង គាន មានតួនាទីរៀបចំម្ហូបអាហារ សម្លៀកបំពាក់ និងកន្លែងស្នាក់នៅសម្រាប់ ប៉ុល ពត ។ តាមរយៈតួនាទីទាំងនេះ លោក អៀង គាន បានទៅយកសារទូរលេខ និងសំបុត្រជាច្រើននៅមន្ទីរក-៧ ហើយប្រគល់ឲ្យ ប៉ុល ពត និង នួន ជា ។ ជាងនេះទៅទៀត ក្រុមរបស់លោកគឺជាអ្នករៀបចំនិងការពាររាល់កិច្ចប្រជុំរបស់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានរៀបចំឡើងនៅមន្ទីរក-១ ។

## ២) ការសួរដេញដោលដោយតំណាង សហព្រះរាជអាជ្ញា

ក្នុងការសួរដេញដោលសាក្សី លោក វ៉េង ហ៊ត់ តំណាងសហព្រះរាជអាជ្ញាជាតិបានផ្តោតសំខាន់លើអង្គហេតុមុនឆ្នាំ១៩៧៥ ពោលគឺពាក់ព័ន្ធនឹងគោលបំណងរបស់លោក អៀង គាន ក្នុងការចូលរួមចលនាបដិវត្ត និងតួនាទីរបស់លោក អៀង គាន ក្នុងអំឡុងពេលនោះ ។ ចំណែកលោក ដារីក អាប់ឌុលហាក់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានផ្តោតសំខាន់លើអង្គហេតុដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសទាក់ទងនឹងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរក-១ និងការបញ្ជូនសំបុត្រ ឬសារទូរលេខផ្សេងៗពីមន្ទីរក-៧ឲ្យ ប៉ុល ពត និងពី ប៉ុល ពត ទៅមេដឹកនាំផ្សេងៗទៀត ។ គួរកត់សម្គាល់ថា ជាទូទៅតំណាងសហព្រះរាជអាជ្ញាបានបែងចែកគ្នាក្នុងការសួរសាក្សី ដោយតំណាងសហព្រះរាជអាជ្ញជាតិតែងតែផ្តោតសំខាន់លើអង្គហេតុមុនឆ្នាំ

១៩៧៥ ចំណែកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិផ្តោតលើអង្គហេតុក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែជារឿយៗ អង្គជំនុំជម្រះតែងរំឭកដល់តំណាងសហព្រះរាជអាជ្ញាជាតិថា គប្បីផ្តោតសំខាន់លើអង្គហេតុដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពោលគឺអង្គហេតុដែលកើតឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាតិ លោក អឿន តាន បញ្ជាក់ថា លោកបានចូលរួមក្នុងចលនាបដិវត្តនៅចន្លោះខែកុម្ភៈ និង មីនា ឆ្នាំ១៩៦៨ ។ គោលបំណងនៃការចូលរួមនេះ គឺសង្ឃឹមថានឹងទទួលបានការបណ្តុះបណ្តាលផ្សេងៗ ដើម្បីជួយឲ្យលោកមានចំណេះដឹងខ្លះ ព្រោះលោកជាមនុស្សមិនចេះអាន និងសរសេរអក្សរខ្មែរ ។ លោកបានចូលរួមក្នុងចលនានេះតាមរយៈការណែនាំរបស់ ដៃ ដែលជាអ្នកដឹកនាំអង្គភាពនិរសារ និងទទួលស្គាល់ដោយ កង ដែង ជាគណៈស្រុក ។ ក្នុងអំឡុង ពេលនោះលោកមានតួនាទីជានិរសាររត់សំបុត្រក្រោមការគ្រប់គ្រងរបស់ ដៃ ។ បន្ទាប់មកលោកទទួលធ្វើជាកងការពាររបស់ ប៉ុល ពត ក្រោមការគ្រប់គ្រងរបស់ ប៉ាំង ។ ក្នុងឋានៈជាកងការពារ លោកធ្លាប់ជូន ប៉ុល ពត ធ្វើដំណើរទៅខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង ដើម្បីជួបប្រជុំជាមួយកម្មាភិបាលផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ។

លោក អឿន តាន បញ្ជាក់បន្ថែមថា ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ លោករស់នៅជាមួយ ជាមួយ ប៉ុល ពត ក្នុងខេត្តកំពង់ចាម ។ លោកមានតួនាទីជាអ្នករត់សំបុត្រ និងជាកងការពារសម្រាប់ ប៉ុល ពត ។ ក្រុមរបស់លោកមានគ្នា៣០ នាក់ ទទួលបន្ទុកការពារ ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា និងមេដឹកនាំផ្សេងៗទៀត ។ ក្នុងអំឡុងពេលនោះ មេដឹកនាំទាំងនេះបានជួបប្រជុំគ្នាជាញឹកញ៉ាប់ ពោលគឺ ៣ ឬ៤ដងក្នុងមួយខែ ដែលពេលនោះផ្ទះរបស់ ខៀវ សំផន និង នួន ជា មានចម្ងាយពីផ្ទះរបស់ ប៉ុល ពត ប្រហែល២០០ ទៅ ៣០០ ម៉ែត្រតែប៉ុណ្ណោះ ។ នៅពេលមានកិច្ចប្រជុំរបស់មេដឹកនាំទាំងនោះម្តងៗ ក្រុមរបស់លោកត្រូវទទួលបន្ទុកការពារសន្តិសុខក្រោមការចាត់តាំងរបស់ ប៉ាំង ។ កងការពារត្រូវ ស្ថិតនៅចម្ងាយ២០ ម៉ែត្រពីអង្គប្រជុំ ដូច្នេះអ្នកការពារមិនអាចដឹងថាកិច្ចប្រជុំទាំងនោះនិយាយអំពីបញ្ហាអ្វីឡើយ ។ ក្រៅពីនេះ លោក អឿន តាន បានបញ្ជាក់បន្ថែមអំពីវត្តមានមន្ទីរ៨៧០ នៅមុនឆ្នាំ ១៩៧៥ ។ លោកបានលើកឡើងថា មុនឆ្នាំ១៩៧៥ មន្ទីរ៨៧០ មានទីតាំងនៅខេត្តកំពង់ចាម ដែលមាន ប៉ាំង ជាអ្នកទទួលបន្ទុកដឹកនាំរួម ។ របនាសម្ព័ន្ធរបស់មន្ទីរនេះ គឺមាន មន្ទីរក-១ មន្ទីរក-៣ និង មន្ទីរក-៧ ។ មន្ទីរក-៧ គឺជាអង្គភាពនិរសារ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ លីន ។

ទាក់ទងនឹងការធ្វើដំណើររបស់ ប៉ុល ពត ចេញពីខេត្តកំពង់ចាម លោក អឿន តាន បញ្ជាក់ថា បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាម ប៉ុល ពត, នួន ជា, ខៀវ សំផន និង ប៉ាំង គឺកំពុងរស់នៅខេត្តកំពង់ចាមនៅឡើយ ។ រហូតដល់ចុងខែមេសា ឆ្នាំ១៩៧៥ ទើបមេដឹកនាំទាំងនេះធ្វើដំណើរទៅទីក្រុងភ្នំពេញ ។ ប៉ាំង បានប្រាប់លោកថា ខ្លួន(ប៉ាំង) , ប៉ុល ពត, នួន ជា, ខៀវ សំផន និង មេដឹកនាំផ្សេងៗទៀតនឹងធ្វើដំណើរទៅទីក្រុងភ្នំពេញមុន ហើយចាត់តាំងឲ្យលោកនៅរៀបចំសម្ភារៈប្រើ ប្រាស់របស់មេដឹកនាំទាំងនោះយកទៅតាមក្រោយ ។ រហូតដល់ពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៥ ទើបលោកធ្វើដំណើរចេញពីខេត្តកំពង់ចាមជាមួយក្រុមរបស់លោកដែលដឹកជញ្ជូនសម្ភារៈប្រើប្រាស់របស់មេដឹកនាំទាំងនោះ ហើយបានមកស្នាក់នៅមន្ទីរក-១ ដែលជាកន្លែងធ្វើការរបស់ ប៉ុល ពត ។

ទាក់ទងនឹងមន្ទីរក-១ លោក អឿន តាន បានផ្តល់សក្ខីកម្ម ជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិថា មន្ទីរក-១ គឺជាកន្លែងស្នាក់នៅ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត ។ មន្ទីរនេះមានទីតាំងនៅជាប់ទន្លេបាសាក់រាជធានីភ្នំពេញ ។ លោកត្រូវបាន ប៉ាំង ចាត់តាំងឲ្យធ្វើជាប្រធានក្រុមកងការពារសន្តិសុខផ្នែកខាង ក្នុងនៅមន្ទីរក-១ ។ ក្រុមរបស់លោកមានគ្នា១០ នាក់ ទទួលបន្ទុករៀបចំម្ហូបអាហារសម្លៀកបំពាក់សម្រាប់ ប៉ុល ពត ។ ក្រៅពីនេះ គឺមានការផ្សារដាំដុះនៅក្នុងមន្ទីរ ជាពិសេសជួយរៀបចំបោសសម្អាត និងការពារសន្តិសុខនៅពេលមានកិច្ចប្រជុំនៅមន្ទីរក-១ ។ លោក អឿន តាន បញ្ជាក់យ៉ាងច្បាស់ថា មន្ទីរក-១ គឺជាកន្លែងធ្វើការ និងជួបប្រជុំរបស់ ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន និងមេដឹកនាំផ្សេងៗទៀត ។ មេដឹកនាំទាំងនេះបានជួបប្រជុំជារៀងរាល់ខែនៅមន្ទីរក-១ ដោយមានការចូលរួមពីកម្មាភិបាលមកពីគណៈស្រុក គណៈតំបន់ និងគណៈ

ភូមិភាគ ។ កិច្ចប្រជុំត្រូវបានរៀបចំឡើង យ៉ាងតិចគឺមានចំនួន១ ឬ២ ដងក្នុងមួយខែ ដោយចាប់ផ្តើមពីម៉ោង៧ ដល់ម៉ោង១១ព្រឹក និងបន្តពីម៉ោង២ ដល់ម៉ោង៥ល្ងាច ដែលម្តងៗមានរយៈពេលយ៉ាងតិច២ថ្ងៃ ។ គ្រប់កិច្ចប្រជុំទាំងអស់នៅមន្ទីរក-១ គឺតែងតែមានវត្តមានរបស់ ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន និង ប៉ង់ ។ លោក អៀង គាន បញ្ជាក់បន្ថែមថា ក្រៅពីកិច្ចប្រជុំដែលត្រូវបានរៀបចំជាប្រចាំដូចបានរៀបរាប់ខាងលើ គឺមានកិច្ចប្រជុំពិសេសមួយចំនួនទៀតពាក់ព័ន្ធការនឹងដោះស្រាយបញ្ហាស្បៀង លើកទំនប់ និងការជីកប្រឡាយជាដើម ដែលមានសមាសភាពចូលរួមប្រជុំដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន និងថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួនទៀតនៅទីក្រុងភ្នំពេញតែប៉ុណ្ណោះ ។ គ្រប់កិច្ចប្រជុំនៅមន្ទីរក-១ ក្រុម របស់លោកមានតួនាទីជួយរៀបចាំបោសសម្អាត និងការពារសន្តិសុខនៅកន្លែងប្រជុំនោះ ។ ទោះជាយ៉ាងនេះក្តី ជាទូទៅលោកមិនដឹងអំពីកម្មវត្ថុដែលកិច្ចប្រជុំទាំងនោះលើកមកពិភាក្សាឡើយ ព្រោះជាកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ប៉ុន្តែលោកបានដឹងខ្លះតាមរយៈ ប៉ង់ ដែលជាថ្នាក់លើរបស់ខ្លួន ។

ក្រៅពីកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៅមន្ទីរក-១ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានសួរផ្តោតសំខាន់អំពីតួនាទីរបស់សាក្សីក្នុងការបញ្ជូនសារទូរលេខ និងសំបុត្រផ្សេងៗឲ្យ ប៉ុល ពត និងមេដឹកនាំផ្សេងៗទៀតនៅមន្ទីរក-១ ។ ជាការឆ្លើយតប លោក អៀង គាន បញ្ជាក់ថា ជារៀងរាល់ថ្ងៃលោកបាន ទៅយកសារទូរលេខ ២ ឬ៣ដងក្នុងមួយថ្ងៃ ពីមន្ទីរក-៧ ដើម្បីប្រគល់ឲ្យ ប៉ុល ពត ។ សារទូរលេខទាំងនោះ នឹងត្រូវបញ្ជូនបន្តទៅ នួន ជា បន្ទាប់ពី ប៉ុល ពត បានមើលរួចហើយ ។ ជាងនេះទៅទៀត លោកក៏ជាអ្នកទទួលបន្ទុកយកសំបុត្រ ឬសារទូរលេខពី ប៉ុល ពត ទៅឲ្យមន្ទីរទូរលេខ ដែលគ្រប់គ្រងដោយ ផង់ ដើម្បីផ្ញើទៅកម្មាភិបាលថ្នាក់ក្រោមដែរ ។ សំបុត្រ និងទូរលេខត្រូវបាន ផ្ញើចេញពី ប៉ុល ពត ទៅកម្មាភិបាលថ្នាក់ក្រោម ២ ឬ៣ដងក្នុងមួយថ្ងៃ ។ សំណួរចុងក្រោយពាក់ព័ន្ធនឹងសារទូរលេខទាំងនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានចោទសួរថា នៅចុងបញ្ចប់នៃរបបកម្ពុជា ប្រជាធិបតេយ្យ ពោលគឺថ្ងៃទី៦-៧ ខែមករា ឆ្នាំ ១៩៧៩ ឯកសាររបស់ ប៉ុល ពត រក្សាទុកនៅឯណា? ជាការឆ្លើយតបលោក អៀង គាន បញ្ជាក់ថា ឯកសារទាំងនោះត្រូវបានរក្សាទុកនៅក្នុងមន្ទីរក-១ ទាំងអស់ ។

សំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺពាក់ព័ន្ធនឹងការជូនដំណើរ ប៉ុល ពត ទៅធ្វើទស្សនកិច្ចតាមបណ្តាខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា ។ លោក អៀង គាន បានបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានជូនដំណើរ ប៉ុល ពត ទៅធ្វើទស្សនកិច្ចនៅខេត្តមួយចំនួនដូចជា កំពង់ឆ្នាំង បាត់ដំបង និងសៀមរាប់ជាដើម ។ ប៉ុល ពត បានចុះដល់កន្លែងការដ្ឋាននៅ តាម មូលដ្ឋានដោយ ផ្ទាល់ ហើយបានជួបពិភាក្សាជាមួយគណៈតំបន់ និងអ្នកគ្រប់គ្រងការដ្ឋានដោយផ្ទាល់ ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាទាំងពីររួបបញ្ចប់សំណួររបស់ខ្លួន អង្គជំនុំជម្រះប្រគល់តួនាទីជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តសួរសាក្សីអំពីអង្គហេតុដូចបានគ្រោងទុក ។ ក្នុងការសួរដេញដោលលោក អៀង គាន គឺមានតែសហមេធាវីជាតិប៉ុណ្ណោះដែលបានចោទសំណួរ ចំណែក សហមេធាវីអន្តរជាតិមិនបានសួរដេញដោលសាក្សីឡើយ ។

ចាប់ផ្តើមដំបូង លោកមេធាវី គឹម ម៉េងឃី មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរ បញ្ជាក់លើអង្គហេតុមួយចំនួនទាក់ទងនឹងគោលបំណងរបស់សាក្សីក្នុងការចូលរួមក្នុងចលនាបដិវត្តការងាររបស់សាក្សីនៅខេត្តរតនៈគិរី ការជម្លៀសប្រជាជន វត្តមានរបស់ ប៉ុល ពត បន្ទាប់ពីវាយបែកទីក្រុងភ្នំពេញភ្លាមៗ និងការជូនដំណើរ ប៉ុល ពត ទៅជួបប្រជុំ ឬធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានជាដើម ។ គួរបញ្ជាក់ថា ភាគច្រើនអង្គហេតុទាំងនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាចោទសួររួចហើយ ហើយចម្លើយដែលសាក្សី ផ្តល់ជូនក៏មិនមានការខុសប្លែកគ្នាច្រើនដែរ ។ ប៉ុន្តែអ្វីដែលជាសំណួរថ្មីរបស់លោកមេធាវី គឹម ម៉េងឃី គឺពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ ប៉ុល ពត ក្នុងឆ្នាំ១៩៧៦ ។ បន្ទាប់មកលោកមេធាវី ពេជ អង្គ ជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចោទសំណួរមួយចំនួនទាក់ទងនឹងការបញ្ជូនសំបុត្រពី ប៉ុល ពត ទៅ នួន ជា និងពី នួន ជា និងមេដឹកនាំផ្សេងទៀតទៅ ប៉ុល ពត វិញ ។

លោក អៀង គាន បានផ្តល់សក្ខីកម្មចំពោះសំណួររបស់

លោកមេធាវី គីម ម៉េងឃី ថា គោលបំណងសំខាន់បំផុតដែលនាំឲ្យលោកចូលរួមក្នុងចលនាបដិវត្តគឺ ដើម្បីទទួលបានឱកាសរៀនសូត្រឲ្យមានចំណេះដឹងខ្លះ ។ លោកបញ្ជាក់ថា ជនជាតិភាគតិចភាគច្រើនគឺជាមនុស្សអវិជ្ជា ធ្វើតែស្រែចម្ការ មិនដឹងអំពីបញ្ហានៅក្នុងសង្គមខ្មែរ ឡើយ ។ ដូច្នេះលោកសម្រេចចិត្តចូលរួមក្នុងចលនានេះ គឺសង្ឃឹមថានឹង ទទួលបានចំណេះដឹងខ្លះ អាចរៀនសូត្រចេះសរសេរ និងអានអក្សរខ្មែរបានខ្លះ ។ ប៉ុន្តែនៅពេលចូលរួម គឺលោកទទួលបានការរៀនសូត្របន្តិចបន្តួចប៉ុណ្ណោះ ហើយអ្វីដែលលោកបានរៀនសូត្រច្រើន គឺរបៀបរត់សំបុត្រពីកន្លែងមួយទៅកន្លែងមួយទៀត ។ រហូតមកដល់ឆ្នាំ១៩៧៥ ទើបបក្សបង្រៀនច្រើនអំពី គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ទោះបីជាយ៉ាងណា លោកមិនអាចយល់បានស៊ីជម្រៅឡើយ ព្រោះការយល់ដឹងភាសាខ្មែររបស់លោកនៅមានកម្រិតទាប ។

ទាក់ទងនឹងការរត់សំបុត្រ លោក អៀន តាន បញ្ជាក់ថា ពេលនៅខេត្តរតនៈគិរី លោកមានតួនាទីជាអ្នករត់សំបុត្រពី កង ដែង ជាគណៈស្រុកអណ្ដូងមាស ខេត្តរតនៈគិរី យកទៅ វើនសៃ និង មណ្ឌលគិរី ។ ប៉ុន្តែលោកមិនដឹងថាអ្នកដែលត្រូវទទួលសំបុត្រនោះមានឈ្មោះអ្វីឡើយ ព្រោះលោកមិនចេះអានចំណារ ដែលត្រូវបានចារលើស្រោមសំបុត្រនោះបាន ។ រហូតមកដល់ឆ្នាំ១៩៧០ លោកបានមករស់នៅជាមួយ ប៉ុល ពត ក្នុងខេត្តកំពង់ចាម ។ ក្នុងអំឡុងពេលនោះលោកមានតួនាទីជាអ្នកការពារ និងជានិរសាររត់សំបុត្រ ។ លោកបានជូនដំណើរ ប៉ុល ពត ទៅធ្វើសមាជបក្ស នៅភូមិត្រពាំងទឹម ខេត្តកំពង់ចាម ។ ក្រោយមកជូនដំណើរ ប៉ុល ពត ទៅបើកកិច្ចប្រជុំនៅមន្ទីរដងក្ដារដែលមានទីតាំងនៅក្នុងភូមិដងក្ដារប៉ែកឦសាន្តនៃឃុំស្ដី ហើយកិច្ចប្រជុំនេះមានការចូលរួមពីប្រធានភូមិភាគផ្សេងៗ ។ ក្រៅពីនេះលោកធ្លាប់បានជូន ប៉ុល ពត ទៅធ្វើទស្សនកិច្ចនៅតាមបណ្ដាខេត្តមួយចំនួនដូចជាខេត្តកំពង់ឆ្នាំង សៀមរាប ពោធិ៍សាត់ បាត់ដំបងជាដើម ។ លោក អៀន បញ្ជាក់បន្ថែមថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់បានជូនដំណើរ ប៉ុល ពត ទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យការជីកប្រឡាយ និងលើកទំនប់មួយចំនួន ។

ពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ ប៉ុល ពត លោកមេធាវី គីម ម៉េងឃី ចោទសំណួរថា តើនៅ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ មានការប្រកាសថា ប៉ុល ពត មានជំងឺជាទម្ងន់ដែរឬទេ? លោក អៀន តាន បញ្ជាក់ថា លោកមិនដែលឮអំពីការប្រកាសនេះឡើយ ហើយក្នុងនាមលោកជាកងការពារ និងនៅជាប់លាប់ជាមួយ ប៉ុល ពត ក៏មិនដែលឃើញ ប៉ុល ពត មានជំងឺធ្ងន់ធ្ងរដែរ ។

ពាក់ព័ន្ធនឹងការបញ្ជូនសំបុត្រ ឬសារទូរលេខ ពី ប៉ុល ពត ទៅ នួន ជា លោក អៀន តាន បានផ្ដល់សក្ខីកម្មជូនលោកមេធាវី ពេជ អង្គ ថា ជាទូទៅសារទូរលេខដែលថ្នាក់ក្រោមផ្ញើឲ្យ ប៉ុល ពត នឹង ត្រូវបញ្ជូនបន្តទៅ នួន ជា បន្ទាប់ពី ប៉ុល ពត បានមើលចប់ ។ ប៉ុន្តែសម្រាប់រូបលោកផ្ទាល់ គឺមិនដែលបានទទួលសំបុត្រតបពី នួន ជា ផ្ញើឲ្យ ប៉ុល ពត វិញឡើយ ។ បន្ទាប់មកលោកមេធាវីបានដកស្រង់សំណួរ និង ចម្លើយដែលសាក្សីបានផ្ដល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតថា *« ពេលលោកយកលិខិត ទៅឲ្យ នួន ជា តើ នួន ជា មានផ្ញើអ្វីទៅឲ្យ ប៉ុល ពត វិញដែរឬទេ? »* ។ លោក អៀន តាន បានឆ្លើយថា *«អត់មានទេ! តែមានពេលខ្លះមានគេយកសំបុត្រពី នួន ជា ទៅឲ្យ ប៉ុល ពត ។ ការបញ្ជូនសំបុត្រពី នួន ជា ទៅឲ្យ ប៉ុល ពត គឺ ២ដងក្នុងមួយថ្ងៃ ។ ខ្ញុំមិនដែលឃើញសំបុត្រពី ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ផ្ញើឲ្យ ប៉ុល ពត ទេ ព្រោះខ្ញុំមិនមែនជាអ្នកធ្វើការជាមួយអ្នកទាំងនោះ ។ ខ្ញុំក៏ធ្លាប់ឃើញសំបុត្រ ផ្ញើមកពី សុន សេន ដែរ»* ។ លោក អៀន តាន បញ្ជាក់បន្ថែមជូនលោកមេធាវីថា សំបុត្រដែលផ្ញើមកពីសុន សេនឲ្យ ប៉ុល ពតគឺមានទំហំតូចៗ ដោយដាក់នៅក្នុងស្រោម ។ ចំណែកសំបុត្រដែលផ្ញើមកពី នួន ជា គឺមានកម្រាសក្រាស់ៗ ប៉ុន្តែលោកមិនដឹងថាសំបុត្រនេះនិយាយអំពីអ្វី និងមានប្រភពមកពីណាឡើយ ។

បន្ទាប់ពីក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបញ្ចប់សំណួររបស់ខ្លួន អង្គជំនុំជម្រះបានបន្តចោទសំណួរមួយចំនួនទៅសាក្សីមុនពេលប្រគល់តួនាទីជូនក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុម ។ សំណួររបស់អង្គជំនុំជម្រះបានផ្ដោតសំខាន់អំពីតួនាទីរបស់ជាប់ចោទ នួន ជា នៅពេលអវត្តមាន ប៉ុល ពត និងតួនាទីរបស់ ខៀវ សំផន នៅមន្ទីរ៨៧០ ។ ឆ្លើយតបនឹងសំណួររបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ើញ លោកសាក្សីបានបញ្ជាក់ថា ជាទូទៅកិច្ចប្រជុំនៅមន្ទីរក-១ ត្រូវបានរៀបចំ និងដឹកនាំដោយ ប៉ុល ពត ។ ប៉ុន្តែក្នុងករណី ប៉ុល ពត អវត្តមាន ឬធ្វើដំណើរទៅក្រៅប្រទេស គឺ នួន ជា ជាអ្នកទទួលបន្ទុកក្នុងការដឹកនាំកិច្ចប្រជុំទាំងនោះ ។ ចំពោះតួនាទីរបស់ជនជាប់ចោទ

ខៀវ សំផន វិញ លោក អឿន តាន បញ្ជាក់ជូនលោកចៅក្រម និល ណុន ថា ក្នុងអំឡុងពេលលោកធ្វើការនៅមន្ទីរក-១ គឺលោកមិនដែលឃើញ ខៀវ សំផន ដឹកនាំកិច្ចប្រជុំនៅមន្ទីរ៨៧០ ឡើយ ។ មន្ទីរ៨៧០ មានអង្គភាពចំណុះមួយចំនួនដូចជា មន្ទីរក-១ មន្ទីរក-៣ និងមន្ទីរក-៧ ។ សាក្សីបញ្ជាក់បន្ថែមថា មន្ទីរ៨៧០ស្ថិតនៅក្រោមការគ្រប់គ្រងរួមរបស់ ប៉ាំង ក្រោយមកមន្ទីរនេះត្រូវបានគ្រប់គ្រងដោយ កែន ហៅ លីន បន្ទាប់ពី ប៉ាំង បាត់ខ្លួន ។

## ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ

បន្ទាប់ពីបញ្ចប់សំណួររបស់តំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងរបស់អង្គជំនុំជម្រះ លោកប្រធានចៅក្រម និល ណុន បានប្រគល់វេទិកាជូនមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមដើម្បីចោទសំណួរទៅសាក្សី ដោយចាប់ផ្តើមពីមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បន្ទាប់មកមេធាវីរបស់ នួន ជា និងចុងក្រោយមេធាវីរបស់ អៀង សារី ។

### ៤.១) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី ខៀវ សំផន

គួរកត់សម្គាល់ថា ក្នុងការសួរដេញដោលសាក្សី លោក អាកទួរ វែកគែន ជាមេធាវីអន្តរជាតិការពារក្តីជនជាប់ ខៀវ សំផន បានផ្តោតសំខាន់ទៅលើភាពអាចទុកចិត្តបានរបស់សាក្សីក្នុងការផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ តាមរយៈវិធីសាស្ត្រនេះ លោកមេធាវីបានដកស្រង់ចម្លើយដែលមានការខុសគ្នាមួយ ចំនួនដែលសាក្សីបានផ្តល់នៅដំណាក់កាលស៊ើបអង្កេត និងសក្ខីកម្មដែលសាក្សីបានផ្តល់ជូនតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

សំណួរចាប់ផ្តើមដំបូងគឺពាក់ព័ន្ធនឹងវត្តមានរបស់សាក្សី និង ប៉ុល ពត នៅពេលជិតវាយបែកទីក្រុងភ្នំពេញ ។ លោកមេធាវីបានដកស្រង់ចម្លើយដែលលោក អឿន តាន ធ្លាប់បានផ្តល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា "...មុនពេលចូលភ្នំពេញមួយរយៈ ខ្ញុំមិននៅជាមួយ ប៉ុល ពត ទេដូច្នេះខ្ញុំមិនដឹងពីការ ជម្លៀសប្រជាជននៅភ្នំពេញឡើយ" ។ លោក តាន បានបំភ្លឺថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប៉ុល ពត និង លោក កំពុងរស់នៅក្នុងខេត្តកំពង់ចាម ។ ក្រោយពីរំដោះបានទីក្រុងភ្នំពេញប្រហែលកន្លះខែ ទើប ប៉ុល ពត, ប៉ាំង និងមេដឹកនាំមួយចំនួនទៀតធ្វើដំណើរទៅទីក្រុងភ្នំពេញ ។ ពេលនោះលោកមិនបានធ្វើដំណើរទៅជាមួយមេដឹកនាំទាំងនេះឡើយ ព្រោះនៅរៀបចំសម្ភារៈប្រើប្រាស់របស់អ្នកទាំងនោះយកទៅតាមក្រោយ ពោលគឺរហូតដល់ពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៥ ទើបលោកចេញទៅទីក្រុងភ្នំពេញ ។ ដូច្នេះរយៈពេលដែលលោកមិនបាននៅជាមួយ ប៉ុល ពត គឺប្រហែលមួយខែប៉ុណ្ណោះបន្ទាប់ពី ប៉ុល ពត ធ្វើដំណើរទៅទីក្រុងភ្នំពេញ ។ សាក្សីបញ្ជាក់បន្ថែមថា នៅពេល ប៉ុល ពត ធ្វើដំណើរទៅទីក្រុងភ្នំពេញ លោកមិនបានឃើញ ខៀវ សំផន រួមដំណើរជាមួយ ប៉ុល ពត ឡើយ ។

### អំពីកិច្ចប្រជុំនៅមន្ទីរក-១

សំណួរបន្ទាប់របស់លោក វែកគែន គឺពាក់ព័ន្ធនឹងកិច្ចប្រជុំនៅមន្ទីរក-១ ។ លោកមេធាវីបានរំឭកដល់សាក្សីដែលបានឆ្លើយជូនតំណាងសហព្រះរាជអាជ្ញាថា កិច្ចប្រជុំធំៗដែលធ្វើនៅមន្ទីរក-១ គឺមានរយៈពេល២-៣ថ្ងៃ ។ បន្ទាប់មកលោកមេធាវីបានដាក់បង្ហាញឯកសារដែលសាក្សីបានផ្តល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា "កិច្ចប្រជុំធំៗដែលមានគ្នាចូលរួមជាង២០នាក់ដែលមានការចូលរួមពីមេដឹកនាំធំៗ និងកម្មាភិបាលមកពីភូមិភាគ និងតំបន់គឺមានរយៈពេល ៥-៦ថ្ងៃ" ។ លោក តាន បញ្ជាក់ថា រយៈពេលនៃកិច្ចប្រជុំប្រភេទនេះគឺអាស្រ័យលើកម្មវត្ថុដែលត្រូវយកមកពិភាក្សា ។ ជាធម្មតាកិច្ចប្រជុំនេះមានរយៈពេល២-៣ថ្ងៃ ប៉ុន្តែក្នុងករណីមានប្រធានបទច្រើនដែលត្រូវពិភាក្សា គឺអាចចំណាយពេលពី៥ ទៅ៦ថ្ងៃ ។ លោកបន្ថែមថា រាល់កិច្ចប្រជុំធំៗនៅមន្ទីរក-១ គឺមានការចូលរួមពី ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង សារី និងមេដឹកនាំផ្សេងៗទៀត(សាក្សីមិនចាំឈ្មោះ) ។ បន្ទាប់ពីសាក្សីបញ្ជាក់ដូច្នេះ លោកមេធាវីស្នើឲ្យសាក្សីបញ្ជាក់ពីកាលបរិច្ឆេទដែល ខៀវ សំផន បានចូលរួមកិច្ចប្រជុំទាំងនោះ និងកម្មវត្ថុ ដែលត្រូវបានយកមកពិភាក្សានៅក្នុងអំឡុងពេលនោះ ។ ជាការឆ្លើយតប លោក តាន បញ្ជាក់ថា លោកមិនអាចចាំកាលបរិច្ឆេទទាំងនោះឡើយ ព្រោះរយៈពេលកន្លងហួសជាង៣០ទៅហើយ ។ ចំពោះកម្ម វត្ថុដែលត្រូវបានយកមកពិភាក្សាក្នុងកិច្ចប្រជុំធំៗក៏លោកមិនអាចដឹងដែរ ព្រោះជាកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ។ ប៉ុន្តែលោកធ្លាប់បានដឹងកម្មវត្ថុនៃកិច្ចប្រជុំតូចៗនៅមន្ទីរក-១

(តាមរយៈ ប៉ង់ ជាថ្នាក់លើរបស់ខ្លួន) ពាក់ព័ន្ធនឹងការដោះស្រាយជីវភាពប្រជាជន ឬការដឹកទំនប់ប្រឡាយជាដើម ។


កិច្ចប្រជុំយោធាខ្មែរក្រហមនៅស្តាតអូឡាំពិក (ប្រភពឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### អំពីកិច្ចប្រជុំនៅស្តាតអូឡាំពិក

បន្ទាប់ពីបញ្ចប់សំណួរពាក់ព័ន្ធនឹងកិច្ចប្រជុំនៅមន្ទីរក-១ លោក វ៉ែកគែន បន្តសួរសាក្សីអំពីកិច្ចប្រជុំទាក់ទងនឹងផ្នែកយោធាដែលត្រូវបានធ្វើនៅស្តាតអូឡាំពិក ។ ហាក់ដូចជាមានការភាន់ច្រឡំបន្តិចចំពោះសំណួរ និងចម្លើយទាក់ទងនឹងចំនួនដងនៃកិច្ចប្រជុំនៅស្តាតអូឡាំពិក ។ ដំបូងលោកមេធាវីសួរសាក្សីថា តើកិច្ចប្រជុំធំៗពាក់ព័ន្ធផ្នែកយោធាត្រូវបានធ្វើឡើងប៉ុន្មានដងនៅស្តាតអូឡាំពិក? លោក តាន បញ្ជាក់ថា លោកបានចូលរួមចំនួនពីរដងក្នុងឋានៈជាអ្នកការពារនៅក្នុងកិច្ចប្រជុំនេះ ។ បន្ទាប់ពីបញ្ជាក់ដូច្នេះ លោកមេធាវីបានលើកឡើងថា លោក តាន មិនបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតដូច្នេះឡើយ ពោលសាក្សីធ្លាប់បញ្ជាក់ថា កិច្ចប្រជុំយោធាត្រូវបានធ្វើពីរដងក្នុងមួយឆ្នាំ ។ ដូច្នេះកិច្ចប្រជុំនេះអាចត្រូវបានធ្វើយ៉ាងតិច៦ដងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភ្លាមនោះលោក អាប់ឌុល ថាវីក ធ្វើការកត់សម្គាល់លើចម្លើយរបស់សាក្សីថា “សាក្សីបញ្ជាក់ថាគាត់ធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំនេះពីរដង ដូច្នេះមិនអាចបញ្ជាក់ថាកិច្ចប្រជុំនេះធ្វើឡើងតែពីរដងឡើយ” ។ អង្គជំនុំជម្រះយល់ស្របតាមការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា និងសម្រេចឲ្យលោក វ៉ែកគែន រៀបចំសំណួរសួរសាក្សីសារជាថ្មី ។ អង្គជំនុំជម្រះបញ្ជាក់ថា ខ្លឹមសារចម្លើយដែលសាក្សីឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបអង្កេតខុសពីខ្លឹមសារឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ ។ បន្ទាប់ពីមានការបន្លាប់ដូច្នេះ លោកមេធាវី ចោទសួរថា តើ ប៉ុល ពត បានមកប្រជុំនៅស្តាតអូឡាំពិកពាក់ព័ន្ធនឹងកិច្ចការយោធាចំនួនប៉ុន្មានដង? សាក្សីបញ្ជាក់ថា លោកមិនដឹង ប៉ុល ពត បានចូលរួមប៉ុន្មានដងឡើយ ប៉ុន្តែធ្លាប់ឃើញ ប៉ុល ពត និង សុន សេន ចូលរួមក្នុងកិច្ចប្រជុំនោះពីរដង ។ លោកបញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលនោះលោកមិនបានឃើញវត្តមានរបស់ នួន ជា, អៀង សារី និង ខៀវ សំផន ឡើយ ។

### ៤.២) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី នួន ជា

ក្នុងការសួរដេញដោលសាក្សី លោក សុន អរុណ ជាមេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា បានសួរសំណួរមួយចំនួនប៉ុណ្ណោះទាក់ទងនឹងការងាររបស់លោក តាន ក្នុងអំឡុងពេលធ្វើបដិវត្តនិងកិច្ចប្រជុំនៅស្តាតអូឡាំពិក ។ ចំពោះសំណួរមួយចំនួនទៀតដែលលោកមេធាវីតែងតែចោទសួរសាក្សីគឺទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តនិងចរិកលក្ខណៈរបស់ជនជាប់ចោទ នួន ជា ។

សំណួរមួយចំនួនដំបូងដែលលោកមេធាវីចោទសួរសាក្សីគឺពាក់ព័ន្ធនឹងសុវត្ថិភាពរបស់សាក្សីក្នុង ការបំពេញការងារជាអ្នករត់សំបុត្រនៅក្នុងអំឡុងពេលធ្វើបដិវត្តន៍ ។ លោកមេធាវីចោទសួរថា នៅពេលសាក្សីរត់សំបុត្រពីកន្លែងមួយទៅកន្លែងមួយទៀត មានការភ័យខ្លាចចំពោះការចាប់ខ្លួនពីសំណាក់សត្រូវ របស់បដិវត្តន៍ដែរឬទេ? (លោកមេធាវីមិនបានបញ្ជាក់បុគ្គលប្រភេទណាជាសត្រូវរបស់បដិវត្តន៍ឡើយ) ។ ជាការឆ្លើយតប លោក អៀន តាន បញ្ជាក់ថា ក្នុងការបំពេញការងារជាអ្នករត់សំបុត្រ លោកមិនដែលមានការលំបាកអ្វីឡើយ ហើយក៏មិនដែលព្រួយបារម្ភ ឬភ័យខ្លាចថានឹងមានការចាប់ខ្លួនពីសំណាក់សត្រូវរបស់បដិវត្តន៍ដែរ ។ បន្ទាប់មកលោកមេធាវីបន្តសួរថា “ បើខ្មាំងរបស់បដិវត្តន៍ចាប់លោកបាន តើលោកត្រូវដោះស្រាយយ៉ាងដូចម្តេច? ” ។ ប៉ុន្តែសំណួរនេះត្រូវបានប្រធានអង្គជំនុំជម្រះ

មិនអនុញ្ញាតឲ្យសាក្សីឆ្លើយ ដោយលោកផ្តល់សំអាងហេតុថា មេធាវីសួរសំណួរបែបខុសបមាវិធី ។ ចំពោះសំណួរពាក់ព័ន្ធនឹងវត្តមានរបស់មេដឹកនាំខ្មែរក្រហមនៅក្នុង កិច្ចប្រជុំដែលត្រូវបានធ្វើនៅស្តាតអូឡាំពិក លោកបញ្ជាក់ជាថ្មីថា លោកមិនដែលឃើញវត្តមានរបស់ នួន ជា, អៀង សារី និង ខៀវ សំផន ឡើយ ។

សំណួរបន្ទាប់ លោកមេធាវី សុន អរុណ សួរបញ្ជាក់អំពីអត្តសញ្ញាណរបស់ទស្សនាវដ្តីទង់បដិវត្ត ដែលត្រូវបានបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយរបស់បក្ស ។ ជាការឆ្លើយ តប លោក អឿន តាន បញ្ជាក់ថា លោកបានឃើញទស្សនាវដ្តីនេះចាប់តាំងពីឆ្នាំ១៩៧៥មក ដែលពេលនោះ ទស្សនាវដ្តីទង់បដិវត្តមានដាក់រូបនារីទូលកណ្តាប់ស្រូវ រូបញញួរ កណ្តៀវ ។ ប៉ុន្តែដោយលោកមិនចេះអក្សរមិនអាចអានបាន ដូច្នេះលោកមិនដឹងអំពីខ្លឹមសារដែលមានចែងក្នុងទស្សនាវដ្តីទង់ បដិវត្តឡើយ ។

ចុងក្រោយលោកមេធាវី សុន អរុណ សួរសាក្សីអំពីអត្តចរិករបស់ជនជាប់ចោទ នួន ជា និង ប៉ន់ ក្នុងអំឡុងពេលដែលលោកបានធ្វើការជាមួយ ។ លោក អឿន តាន បញ្ជាក់ថា នួន ជា គឺជាមនុស្សដែលមានរិតស្លូតបូត ចេះអប់រំដល់កម្មាភិបាលខ្មែរក្រហម គឺមិនមែនជាមនុស្សកាចសាហាវឡើយ ។ ចំណែក ប៉ន់ ក៏ជាមនុស្សស្លូតបូតនិងសុភាពរាបសារជាមួយយុទ្ធជនថ្នាក់ក្រោមដែរ ។

## ៤.៣) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី អៀង សារី

ក្នុងការសួរដេញដោលសាក្សី លោក ម៉ៃឃើល ខាណាវ៉ាស ជាមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី បានព្យាយាមផ្តោតលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរចំពោះសាក្សី នៅដំណាក់កាលស៊ើបអង្កេត ។ ចំពោះសំណួរដែលលោកផ្តោតសំខាន់បំផុតនោះ គឺពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងការថតខ្សែអាត់សម្លេងនៅពេលអ្នកស៊ើបអង្កេតសួរយកចម្លើយពីសាក្សី ។

លោក អឿន តាន បញ្ជាក់ថា លោកបានផ្តល់បទសម្ភាស៍ជូនអ្នកស៊ើបអង្កេតចំនួនពីរដង គឺថ្ងៃទី៨-៩ ខែតុលា ឆ្នាំ២០០៨ ។ បន្ទាប់ពីផ្តល់បទសម្ភាស៍ចប់ អ្នកស៊ើបអង្កេតបានអានខ្លឹមសារសង្ខេបនៃបទសម្ភាស៍នោះឲ្យលោកស្តាប់ឡើងវិញមុននឹងលោកចុះហត្ថលេខាទទួលស្គាល់ ។ ចម្លើយនេះត្រូវបានអានឲ្យលោកស្តាប់ម្តងទៀតមុននឹងលោកចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ចំពោះការថតខ្សែអាត់សម្លេងនៅដំណាក់កាលស៊ើបអង្កេត លោក អឿន តាន បញ្ជាក់ថា គឺមានតែ បទសម្ភាស៍ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ ប៉ុណ្ណោះដែលមានការថតសម្លេង ។ ចំណែកបទសម្ភាស៍នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ គឺមិនមានការថតខ្សែអត់សម្លេងឡើយ ។ បញ្ហានេះហើយដែលធ្វើឲ្យលោកមេធាវី ខាណាវ៉ាស់ ជជីកសួរយ៉ាងខ្លាំង ។ លោកបានចោទសួរថា ហេតុអ្វីបានជាកិច្ចសម្ភាស៍ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ មិនមានការថតសម្លេង? តើនៅក្នុងកិច្ចសម្ភាសន៍ដែលមិនមានការថតសម្លេងនេះ អ្នកស៊ើបអង្កេតបានបង្ហាញ ឯកសារអ្វីខ្លះដល់សាក្សីជាការរំឭកដល់ការចងចាំក្នុងការឆ្លើយសំណួរដែរឬទេ? តើមានបញ្ហាអ្វីខ្លះដែលត្រូវបានចោទសួរក្នុងអំឡុងពេលនោះ? ។ ចុងក្រោយលោកមេធាវីចោទសួរថា “កិច្ចសម្ភាសន៍ថ្ងៃទី៨ ដែលមិនមានការថតសម្លេង តើអ្នកស៊ើបអង្កេតមានបង្ហាញឯកសារណាមួយដើម្បីជាការរំឭកដល់លោក ដើម្បីឲ្យលោកឆ្លើយនៅថ្ងៃទី៩ ដែលមានការថតខ្សែអាត់ដែរឬទេ?” ។ ជាលទ្ធផល លោក អឿន តាន បញ្ជាក់ថា លោកមិនចាំថាឯកសារណាឬបញ្ហាអ្វីខ្លះដែលត្រូវបានអ្នកស៊ើបអង្កេតលើកមកបង្ហាញ ឬពិភាក្សាក្នុងអំឡុងពេលការសួរយកចម្លើយដែលគ្មានការថតខ្សែអាត់សម្លេងឡើយ ។

បន្ទាប់ពីសវនាការស្តាប់សក្ខីកម្មរបស់លោក អឿន តាន ត្រូវបានបញ្ចប់ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោក យុន គីម ។

## VII) សវនាការស្តាប់សក្ខីកម្មរបស់សាក្សី យុន គីម

នៅថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានប្រកាសបន្តសវនាការសួរដេញដោលលើសាក្សីដូចដែលបានគ្រោងទុកកាលពីសប្តាហ៍មុន ។ សវនាការនេះបានប្រព្រឹត្តទៅដោយមានការចូលរួមតាមដានពីសំណាក់ប្រជាជនកម្ពុជាប្រហែល៧០០នាក់ ដែលអញ្ជើញមកពីស្រុករតនៈមណ្ឌល ខេត្ត បាត់ដំបង តាកែវ និងកណ្តាល ។ នៅក្នុងកិច្ចដំណើរការសវនាការនេះមិនមានវត្តមានរបស់មេធាវីអន្តរជាតិជនជាប់ចោទ អៀង សារី ឡើយហើយក៏មិនដឹងពីមូលហេតុពិតប្រាកដនោះទេតាមរយៈការបញ្ជាក់របស់ក្រឡា បញ្ជី ។ មុនពេលចាប់ផ្តើមសវនាការលោកប្រធាន និល ណុន បានប្រកាស

បញ្ជាក់ពីវត្តមានរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំអង្គជំនុំជម្រះលះបង់សិទ្ធិក្នុងការចូលរួម សវនាការដោយផ្ទាល់ពេញមួយថ្ងៃដោយសារបញ្ហាសុខភាព ហើយបន្ទាប់មកលោកប្រធានបានអានសេចក្តីបញ្ជាក់របស់គ្រូពេទ្យដែលទាក់ទងនឹងអាការៈជម្ងឺរបស់ជនជាប់ចោទ ។ បន្ទាប់មកលោកមេធាវី អ៊ីណូហ្វ៊ី បានស្នើសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់ខ្លួនដែលធ្វើឡើងកាលពីមុន ។ ទាក់ទងនឹងបញ្ហានេះ លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនមិនទាន់បានទទួលសំណើនោះនៅឡើយទេដោយសារភាពយឺតយ៉ាវរបស់ក្រុមមេធាវី ។ ភ្លាមនោះលោកមេធាវីបានក្រោកឈរឡើងសារជាថ្មីដើម្បីបង្ហាញពីហេតុផលណាមួយ ប៉ុន្តែករណីនេះត្រូវបានលោកប្រធានបញ្ឈប់ ដោយអះអាងថាខ្លួនបានបញ្ជាក់លើករណីនេះរួចហើយ ។

បន្ទាប់មកលោក ពេជ អង្គ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានក្រោកឈរឡើង និងបញ្ជាក់ជូនអង្គជំនុំជម្រះពីមេធាវីទទួលសិទ្ធិ ដែលនឹងធ្វើការសាកសួរសាក្សីនៅក្នុងសវនាការនេះដែលមានលោកមេធាវី វ៉ែន ពៅ និងលោកស្រីមេធាវី ស៊ីមីណូហ្វុត ។ ក្រៅពីនោះ លោកបានធ្វើការកត់សម្គាល់ចំពោះមេធាវី អ៊ីណូហ្វ៊ី ដែលបានពាក់ស្លាកមានអក្សរ«អាយ រូបបេះដូង និងដាដា» នៅលើរ៉ូបរបស់ខ្លួន ដែលលោកមេធាវីសន្និដ្ឋានថាជាស្លាកសញ្ញាផ្សាយពាណិជ្ជកម្មអ្វីមួយ ។ ភ្លាមនោះលោកប្រធានបានបង្គាប់ឲ្យមេធាវីក្រោកឈរ និងធ្វើការណែនាំមិនឲ្យមានការប្រើប្រាស់ស្លាកសញ្ញាណាមួយដែលខុសពីស្លាកសញ្ញារបស់អង្គជំនុំជម្រះឡើយ ។

## ១) ប្រវត្តិសាវតាររបស់សាក្សី យុន គីម

លោកប្រធានបានបន្តកិច្ចដំណើរការដោយកោះហៅសាក្សី យុន គីម មកចូលក្នុងបន្ទប់សវនាការ ដើម្បីធ្វើការសាកសួរ ។ លោកបានចាប់ផ្តើមសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសវតាររបស់សាក្សី ។ នៅក្នុងសភាពមាំទាំទោះបីជាមានវ័យចំណាស់ក៏ដោយ លោកសាក្សីបានបញ្ជាក់ថាខ្លួនមានឈ្មោះ យុន គីម ហៅខាំ មានអាយុ៧០ឆ្នាំ កើតនៅភូមិវឌ្ឍនៈ ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ សព្វថ្ងៃមានតួនាទីជាមេឃុំវឌ្ឍនៈ និងធ្វើស្រែ ។ លោកសាក្សីបានបន្តថា ខ្លួនមានឪពុកឈ្មោះ យុន ហាក់ ម្តាយឈ្មោះ ថាម ជ្រឹ ប្រពន្ធ


សាក្សី យុន គីម

ឈ្មោះ លន់ អេងសៀន និងមានកូន៧នាក់ ។ បន្ទាប់មកលោកប្រធានបានបញ្ចប់ការសាកសួររបស់ខ្លួនដោយផ្ទេរវេទិកាជូនសហព្រះរាជអាជ្ញាដើម្បីសាកសួរ បន្ត ។

## ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

លោក សេង ប៊ុនយាង តំណាងសហព្រះរាជអាជ្ញាជាតិបានសាកសួរសំណួរមួយចំនួនទាក់ទងនឹងការបំពេញការងាររបស់បក្សនៅខេត្តក្រចេះ ការបង្កើតសហករណ៍ ការអប់រំនយោបាយ និងការចាប់ខ្លួនកម្មាភិបាល ។ ចំណែកលោកតំណាងសហព្រះសហករណ៍រាជអាជ្ញាអន្តរជាតិ ឌែលី សាក់ បានបន្តការសាកសួរពាក់ព័ន្ធនឹងសមាជិកភាពរបស់បក្សកុម្មុយនីស្តកម្ពុជារចនាសម្ព័ន្ធរដ្ឋបាលនៅតំបន់ ៥០៥ ការប្រជុំនិងស្ថានភាពទូទៅនៅក្នុងសហករណ៍ និងបញ្ហាសាសនា ។

### ២.១) ការបង្កើតសហករណ៍

សាក្សីបានបន្តថាកាលនោះ នួន ជា បានទៅប្រជុំណែនាំពីការបង្កើតឲ្យមានក្រុមប្រវ៉ាស់ដៃ សហករណ៍កំរិតទាប និងសហករណ៍កំរិតខ្ពស់ ។ គោលបំណងនៃការបង្កើតឲ្យមានក្រុមប្រវ៉ាស់ដៃនេះគឺដើម្បីរួបរួមកម្លាំងបន្ទាប់ពីមានសង្គ្រាមកន្លងមក ហើយការបង្កើតសហករណ៍នេះបានបន្តរហូតដល់ឆ្នាំ១៩៧៩ ។ សាក្សីបានរៀបរាប់ថានៅឆ្នាំ១៩៧១រហូតដល់១៩៧៦ខ្លួនធ្វើជាមេឃុំវឌ្ឍនៈ ហើយនៅឆ្នាំ១៩៧៧គាត់បានផ្លាស់ទៅធ្វើមេឃុំសំបូរ ។ ដំបូងឡើយសហករណ៍គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ឃុំ ហើយ

នៅឆ្នាំ១៩៧៦ គ្រប់សហករណ៍ទាំងអស់ក្លាយជាសហករណ៍ចម្រុះ ដែលមានប្រជាជនជម្លៀសមកពីតំបន់រំដោះ និងប្រជាជន១៧ មេសា ប៉ុន្តែនៅពេលនោះមិនទាន់មានការបែងចែកប្រភេទប្រជាជននៅឡើយទេ ។

## ២.២) ការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហម

ទាក់ទងនឹងការចាប់ខ្លួន លោក គីម បានរៀបរាប់ថា នៅពេលខ្លួនទៅគ្រប់គ្រងនៅឃុំសំបូរនោះធ្លាប់មានបញ្ជាពីថ្នាក់លើឲ្យយក តាឈី ដែលជាអតីតគណៈស្រុកសំបូរ ហើយមិនដែលឃើញត្រលប់មកវិញឡើយ ។ ចំពោះការចាប់ខ្លួន តាឃិន ដែលកាន់ខាងសេដ្ឋកិច្ចនៅស្រុកក្រចេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងពីមូលហេតុដែរ ប៉ុន្តែនៅឆ្នាំ១៩៧៨មានការចាប់ខ្លួនមេឃុំជាច្រើននាក់នៅស្រុកសំបូរ ហើយ ក្រោយមកត្រូវបានគ្រប់គ្រងដោយពួកយោធា ។ ចំណែកលេខានិងគណៈកម្មាការស្រុកពីរនាក់ក៏ត្រូវបានចាប់ខ្លួន ហើយនៅពេលនោះមាន យួន និងឈូក បានមកគ្រប់គ្រងជំនួស ហើយ ឈូកជាលេខាស្រុក ។ សាក្សីបានបន្តថានៅជំនាន់នោះមានការផ្លាស់ប្តូរមនុស្សជាច្រើនលើកច្រើនសារដូច្នេះហេតុការណ៍នេះមិនមានអ្វីចម្លែកនោះឡើយ ។ សាក្សីបានរៀបរាប់ថាមានយុវជនជាង៤០០នាក់ត្រូវបានបញ្ជូនមកមន្ទីរប-៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកយោធាដើម្បីមកជួយធ្វើការងារនៅទីនោះ ប៉ុន្តែដោយសារការគ្រប់គ្រងនៅទីនោះមានសភាពតឹងតែងពេកខ្លួនត្រូវបានតែងតាំងឲ្យកាន់កាប់មន្ទីរប-៣វិញ ។ ចំណែកយុវជនដែលនៅទីនោះធ្វើការបានតែពីរខែក៏ត្រូវបានគណៈស្រុកបញ្ជូនទៅខេត្តកំពង់ធំ ។

## ២.៣) ការអប់រំនយោបាយ

ទាក់ទងនឹងការអប់រំនយោបាយសាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានចូលរួមរៀនសូត្រជាមួយថ្នាក់ស្រុកនិងថ្នាក់ខេត្ត ហើយឯកសារដែលបង្រៀននោះគឺឯកសារទង់បដិវត្ត ។ ចំណែកខ្លឹមសារនៃការបង្រៀន គឺទាក់ទងនឹងការណែនាំឲ្យធ្វើសហករណ៍ និងការងារផ្សេងៗទៀត ។ សាក្សីបានបន្ថែមថា ទង់បដិវត្តនោះក្នុងមួយភូមិទទួលបានតែមួយក្បាលប៉ុណ្ណោះដើម្បីឲ្យកម្មាភិបាលរៀនសូត្រ និងអនុវត្តតាមគោលនយោបាយរបស់បក្ស ។ បន្ទាប់ពីបញ្ចប់ការសាកសួររបស់ខ្លួន លោកតំណាងសហព្រះរាជអាជ្ញាជាតិបានប្រគល់វេទិកាជូនសហភាគីរបស់ខ្លួនគឺលោក ខែល លីសាក់ ។

## ២.៤) សមាជិកភាពរបស់បក្សកុម្មុយនីសកម្ពុជា

លោក ខែលី សាក់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានចាប់ផ្តើមសំណួររបស់ខ្លួនទាក់ទងនឹងការចូលជាសមាជិកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ លោក គីម បានរៀបរាប់ថាខ្លួនមាន ស្រុកកំណើតនៅស្រុកក្រូចឆ្មារខេត្តកំពង់ចាម និងកើតនៅឆ្នាំ១៩៤២ ហើយនៅឆ្នាំ១៩៥០ខ្លួនបានផ្លាស់មកនៅខេត្តក្រចេះដោយសារប្រទេសអស្ថេរភាព ។ បន្ទាប់ពីមានរដ្ឋប្រហារ ស្ថានភាពច្របូកច្របល់ដូច្នេះខ្លួនបានចូលរួមចលនាបដិវត្តហើយត្រូវបានតែងតាំងជាសមាជិកបក្សនៅឆ្នាំ១៩៧១ ដោយសារមានការណែនាំពី ចែត ជាគណៈស្រុកសំបូរ ។ សាក្សីបានរៀបរាប់ថាការងារជាប្រធានឃុំកាលនោះខ្លួនយកចិត្តទុក ដាក់លើបញ្ហាសេដ្ឋកិច្ច ការដឹកទំនប់ និងបញ្ហាសុខភាពរបស់ប្រជាជនដោយរៀបចំឲ្យមានមន្ទីរពេទ្យ ។ នៅថ្នាក់ឃុំមានផ្នែកសន្តិសុខ និងខាងយោធាមានតួនាទីពិនិត្យមើលសណ្តាប់ធ្នាប់មូលដ្ឋាន ដែលមានឈ្លបជាអ្នកទទួលខុសត្រូវ ។ ថ្នាក់លើរបស់ឃុំគឺមានថ្នាក់ស្រុកដែលមាន តាចែត ជាប្រធាន ហើយក្រោយមកមាន ផាន់ និង នី រហូតដល់ឆ្នាំ១៩៧៨គឺមាន រឿន ដែលគ្រប់គ្រងស្រុកសំបូររហូតដល់ ឆ្នាំ១៩៧៩ ។

## ២.៥) រចនាសម្ព័ន្ធរដ្ឋបាលនៅតំបន់៥០៥

សាក្សីបានរៀបរាប់បន្តថា មុនដំបូងតំបន់៥០៥ ស្ថិតនៅក្នុងភូមិភាគឦសាន្ត ក្រោយមកតំបន់នេះក្លាយជាតំបន់ស្វយ័ត ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ថ្នាក់មជ្ឈិមនៅឆ្នាំ១៩៧៨ ដែលមានយី ជាលេខាតំបន់ ហើយក្រោយមក មឿន បានមកជំនួស បន្ទាប់ពីមានការចាប់ខ្លួន យី ។ នៅតំបន់៥០៥ មានស្រុកបី គឺស្រុកសំបូរ ស្រុកស្នួល និងស្រុកក្រចេះ ហើយនៅស្រុកសំបូរមានបែងចែកជាមន្ទីរសម្រាប់ប្រជុំ មន្ទីរសេដ្ឋកិច្ច និងមន្ទីរសន្តិសុខ ។ ចំពោះការប្រជុំម្តងៗគឺតែងតែមានការលើកឡើងពីបញ្ហាគ្រប់ផ្នែកទាំងអស់ និងមានការកត់ត្រាដើម្បីបញ្ជូនទៅថ្នាក់លើ ។ រាល់ការរាយការណ៍ពីថ្នាក់ឃុំទៅស្រុក គឺត្រូវរាយការណ៍ដោយផ្ទាល់ ប៉ុន្តែពីថ្នាក់ស្រុកទៅខេត្តត្រូវធ្វើឡើងតាមរយៈនិរសារ ។

## ២.៦) កិច្ចប្រជុំជាមួយ នួន ជា

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តការសាកសួរទាក់ទងនឹងកិច្ចប្រជុំដែលធ្វើជាមួយ នួន ជា នៅឆ្នាំ១៩៧៣ ។ ឆ្លើយតប

និងសំណួរនេះសាក្សីបានបញ្ជាក់ថាកម្មវត្ថុនៃការប្រជុំនោះ នួន ជា បានណែនាំអំពីសភាពការណ៍វាយខ្មាំង ដែលសំដៅលើទាហាន លន់ នល់ ការបង្កើតសហករណ៍បីកំរិតថ្នាក់ឃុំ ដូចជាក្រុមប្រវាស់ដៃ ដែលប្រជាជនជួយគ្នាទៅវិញទៅមកធ្វើស្រែលើដីរៀងខ្លួនដោយ មិនមានការបែងចែកផល ។ ចំណែកក្រុមកំរិតទាបវិញ គឺប្រជាជន ធ្វើការរួមគ្នាចែករំលែកសម្ភារៈប្រើប្រាស់ និងគោក្របីជាដើម ហើយវាខុសពីសហករណ៍កំរិតខ្ពស់ដែលតំរូវឲ្យដាក់រទេះគោក្របី រួមគ្នា ប៉ុន្តែការទទួលបានផលតាមកម្លាំងពលកម្ម ។ ក្រោយមក តាចែត ត្រូវបានចាប់ខ្លួនបញ្ជូនទៅក្រចេះឆ្នាំ១៩៧៦ ដោយសារខុស សីលធម៌ ។

## ២.៧) ស្ថានភាពនៅក្នុងសហករណ៍

នៅឆ្នាំ១៩៧៧ នៅឃុំសំបូរមានសហករណ៍ពីរគឺសហករណ៍ សំបូរ និងស្រែខឿនដោយសារឃុំនេះធំជាងគេនៅក្នុងស្រុក សំបូរ ។ ទោះបីជាសហករណ៍ទាំងពីរចែកដាច់ពីគ្នា ប៉ុន្តែការរាយ ការណ៍នៅតែមានដដែល ហើយត្រូវធ្វើឡើងដោយផ្ទាល់ ។ ក្រោយ មកខ្លួនត្រូវបាន រឿន ជាគណៈស្រុកផ្លាស់ពីសហករណ៍ស្រែខឿន ទៅ មន្ទីរប-៣ ។ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជននៅថ្ងៃ១៧ មេសា ១៩៧៥ សាក្សីបានបញ្ជាក់ ថានៅភូមិវឌ្ឍនៈមានការជម្លៀស ប្រជាជនថ្មីតាមកាណូត ហើយក្រោយមកមានការជម្លៀសជនជាតិ ចាមប្រហែល៣០ ទៅ៤០ គ្រួសារផ្លាស់មកពីស្វាយកាំបិត ហើយមានប្រជាជនខ្មែរមួយចំនួនរហូតដល់ដើមឆ្នាំ១៩៧៨មាន ប្រជាជនមកពីឃុំមួង ស្រុកមេមត់ថែមទៀត ។ សាក្សីបាន បន្ថែម ទៀតថា ការរស់នៅទីនោះតែងតែមានការប្រជុំដើម្បីចាប់ខ្មាំងដែល ខ្ជិលច្រអូស និងអ្នកដែលមិនពេញចិត្តចំពោះបដិវត្តន៍ជាដើម ។ ក្រៅពីនោះខ្លួនបានឲ្យប្រជាជននៅក្នុងឃុំធ្វើការទិតៀនអំពីការដឹក នាំរបស់ខ្លួន ហើយប្រជាជននៅទីនោះសប្បាយចិត្តដោយសារអ្នកដឹក នាំពីមុនមិនអាចធ្វើការទិតៀនបានឡើយ ។ សាក្សីបានបន្ថែមថា មន្ទីរ អប់រំកែប្រែនៅស្រុកសំបូរមានពីរកន្លែង គឺនៅប្រស្រាលនិងគោក ក្ដួច ។

## ២.៨) ទាក់ទងនឹងសាសនា

សាក្សីបានអះអាងថា នៅខេត្តក្រចេះព្រះពុទ្ធសាសនាត្រូវ បានបញ្ចប់នៅចុងឆ្នាំ១៩៧៦ ដោយលុបបំបាត់មិនឲ្យមានលោកសង្ឃ ប៉ុន្តែវត្តអារាមមិនមានការខូចខាតច្រើនទេ ពីព្រោះពេលមាន


ស្ថានភាពសហករណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភពឯកសារៈមជ្ឈម

ប្រជាជនមកប្រជុំច្រើន គេមិនឲ្យចូលក្នុងវិហារនោះឡើយដោយឲ្យ ប្រជុំនៅបរិវេណខាងក្រៅ ហើយត្រូវបានគេយកទៅធ្វើជាកន្លែង ដុតក្បឿង ។ ចំពោះវត្តសរសរ១០០ ត្រូវបានប្រជាជន រើរុះយក ក្បឿងដើម្បីសង់មន្ទីរពេទ្យ ។ លោកបានបន្តថា នៅពេលនោះ សាសនាព្រះពុទ្ធ និងសាសនាឥស្លាមត្រូវបានលុបបំបាត់ចោល ទាំងអស់ ហើយនៅកន្លែងខ្លះមានការបង្ខំឲ្យជនជាតិចាមហូបសាច់ ជ្រូកស្មើរគ្រប់សហករណ៍ទាំងអស់ ។ បន្ទាប់ពីបញ្ចប់ការសាកសួរ របស់តំណាងសហព្រះរាជអាជ្ញា លោកមេធាវីការពារ ក្ដី អ៊ីណូហ្វ្រី



មណ្ឌលឯកសារកម្ពុជា)

បានស្នើសុំឲ្យកូនក្តីរបស់ខ្លួនចុះទៅសម្រាកនៅបន្ទប់ខាងក្រោមដោយសារបញ្ហាសុខភាព ។ ឆ្លៀតពេលនោះដែរ លោកមេធាវីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា ចំពោះពាក្យ“ដាដា” ដែលខ្លួនបានពាក់នៅលើរ៉ូបកាលពីព្រឹកនោះគឺសំដៅទៅលើចលនាទស្សនៈនិយមដែលជំទាស់នឹងអ្វីដែលគ្មានន័យ ហើយប្រឆាំងនឹងទស្សនៈដែលវង្វេងការប្រព្រឹត្តមិនល្អដោយមិនមែនមានន័យថា “មិនសួរមិនឆ្លើយនោះទេ” ។ ទាក់ទងនឹងការបកស្រាយទាំងនេះ លោកប្រធានមិនបានធ្វើការឆ្លើយតបចំពោះការបញ្ជាក់អត្ថន័យពីសំណាក់មេធាវីឡើយ ដោយលោកគ្រាន់តែអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ទៅសម្រាកនៅបន្ទប់ក្រោមតាមការស្នើ សុំតែប៉ុណ្ណោះ ។

## ២.៩) ការជ្រើសរើសនារីឱ្យរៀបការជាមួយយោធា

តំណាងសហព្រះរាជអាជ្ញាបានបន្តការសាកសួររបស់ខ្លួនទាក់ទងនឹងការរៀបការជាកងកម្លាំងយោធា ។ ទាក់ទិននឹងបញ្ហានេះសាក្សីបានបញ្ជាក់ថាការរៀបការនោះមិនមានការបង្ខំឡើយគឺទាល់តែខាងនារីស្ម័គ្រចិត្ត ហើយដោយសារការរៀបការនៅពេលនោះមានច្រើនគូរ បុរស និងនារីត្រូវតំរូវឲ្យមានពាក់លេខដើម្បី

ចំណាំ ។ សាក្សីបានរៀបរាប់ថាជាធម្មតាយោធាត្រូវស្នើទៅថ្នាក់ស្រុក ហើយខ្លួននៅថ្នាក់ឃុំជាអ្នកសាកសួរយោបល់ប្រសិនបើនារីនោះស្ម័គ្រចិត្តទើបអាចរៀបការបាន ។ នៅឆ្នាំ១៩៧៧សាក្សីបានបញ្ជាក់ថាខ្លួនត្រូវបានតែងតាំងជាគណៈស្រុកសំបូរដោយសារស្ថានភាពនៅទីនោះច្របូកច្របល់ខ្លាំង និងមានការចាប់ខ្លួន សំផន ជាប្រធានស្រុកសំបូរដែលក្រោយមកធ្វើជាប្រធានស្រុកក្រចេះ ហើយក៏ត្រូវបានចាប់ខ្លួនដែរ ។

## ២.១០) ការបែងចែកប្រជាជន

ទាក់ទងនឹងការបែងចែកប្រជាជន១៧មេសា សាក្សីបានបញ្ជាក់ថា ប្រជាជនត្រូវបានគេបែងចែកជាបីប្រភេទ ។ ទីមួយអ្នកដែលរស់នៅតំបន់នោះគេហៅថាប្រជាជនចាស់ ទីពីរប្រជាជនចាស់ដែរតែមិនពេញចិត្តនឹងបដិវត្តគេហៅថាប្រជាជនត្រៀម ហើយទីបីគឺប្រជាជន១៧មេសាដែលគេហៅថាអ្នកបញ្ញើ ។ ប៉ុន្តែនៅក្នុងសហករណ៍ខ្លួនមិនមានបែងចែកដូច្នេះទេដើម្បីកុំឲ្យអ្នកចាស់បានចិត្ត ហើយធ្វើបាបអ្នកដែលមកថ្មី ។ ពាក់ព័ន្ធនឹងប្រវត្តិរូបអ្នកមកថ្មី លោក គីម បានអះអាងថានៅក្នុងឃុំរបស់ខ្លួនមិនតំរូវឲ្យធ្វើនោះឡើយ ប៉ុន្តែអ្នកដែលត្រូវបានគេសង្ស័យថាមានជាប់ខ្សែខាងអ្នកធ្វើការរាជការពីសង្គមចាស់ទើបតំរូវឲ្យធ្វើប្រវត្តិរូបចំណែកអ្នក១៧ មេសាគឺគ្រាន់តែធ្វើជីវៀនធម្មតាតែប៉ុណ្ណោះ ។

## ២.១១) ការបោសសម្អាតខ្មាំងនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ

សាក្សីបានបន្តរៀបរាប់ថាក្នុងស្រុកសំបូរ មានមន្ទីរអប់រំពីរគឺប្រស្រាល និងគោកក្តួច ប៉ុន្តែខ្លួន ក៏មិនដឹងថានៅមន្ទីរសន្តិសុខទាំងពីរនោះមានអ្នកទោសប៉ុន្មាននាក់នោះទេ ។ នៅខេត្តក្រចេះនៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨មានការចាប់ខ្លួនកម្មាភិបាលដូចជារឿន គណៈស្រុកសំបូរបន្ទាប់ពី នី និង ឈូក ប្រធានយោធាស្រុកដោយសារពួកយោធាបានចូលទៅគ្រប់គ្រង ។ ចំពោះអ្នកដែលត្រូវបាន ចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរស-២១ នៅពេលនោះមាន គួន,យី ជាលេខាតំបន់៥០៥, នី គណៈស្រុកសំបូរ, ភឿន នៅខាងយោធានិងសន្តិសុខ និង ដាន់ ជាគណៈស្រុកសំបូរ ហើយមានកម្មាភិបាលខ្លះត្រូវបានចាប់ខ្លួនទាំងគ្រួសារ ។ ទាក់ទងនឹងការក្បត់នៅក្នុងកងកម្លាំងទាហានកម្ពុជាប្រជាធិបតេយ្យពេលច្បាំងជាមួយវៀតណាម និងកម្លាំងក្បត់ត្រូវបានកម្ទេចនៅខេត្តក្រចេះ ។ សាក្សីបានអះអាងថា ខ្លួនមិនបានដឹងពីបញ្ហានេះឡើយ ព្រោះបញ្ហានេះកើតឡើងនៅឆ្ងាយពីតំបន់របស់ខ្លួន ប៉ុន្តែសាក្សីបានបន្ថែមថា វាជារឿងធម្មតាប៉ុណ្ណោះនៅក្នុងរបបខ្មែរក្រហមនៅពេលដែលកម្មាភិបាលថ្មីចូលមកកាន់កាប់នោះ គេតែងតែនិយាយថាអ្នកមុនក្បត់ ។ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារបញ្ជីឈ្មោះអ្នកទោសមកពីតំបន់៥០៥ ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅខែធ្នូ ឆ្នាំ១៩៧៨ដើម្បីឲ្យសាក្សីបានអាន ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់តែឈ្មោះ សម្បត្តិ ម្នាក់ប៉ុណ្ណោះ ។

## ៣) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួររបស់តំណាងសហព្រះរាជអាជ្ញា លោកប្រធានបានផ្ទេរវេទិកាជូនមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក វ៉ែន ពៅ បានចាប់ផ្តើមដោយសួរទាក់ទងនឹងការចូលធ្វើបដិវត្ត ។ សាក្សីបានបញ្ជាក់ថាខ្លួនបានចូលបដិវត្ត ក្រោយពេលរំដោះខេត្តក្រចេះ ហើយរហូតដល់ខែ៤ ឆ្នាំ១៩៧៣ខ្លួនត្រូវបានតែងតាំងឲ្យធ្វើមេឃុំនៅឃុំវឌ្ឍនៈ ។ ទាក់ទិននឹងការជួបប្រជុំជាមួយ នួន ជា នៅឆ្នាំ១៩៧៣នៅពេលនោះ ប្រទេសកម្ពុជាកំពុងមានសង្គ្រាមជាមួយ លន់ នល់ នៅឡើយ ហើយការប្រជុំនោះទាក់ទងនឹងការបង្កើតសហគមន៍និងសហករណ៍ ។ នៅពេលធ្វើការបែងចែកជាសហករណ៍មេឃុំមាននាទីជាប្រធានដែលគេហៅថាគណៈសហករណ៍ ប៉ុន្តែជាការផ្សារនយោបាយរបស់បក្សគេនៅតែហៅថាគណៈឃុំដដែល ។ លោកមេធាវីបានស្នើសុំបង្ហាញឯកសារបទសម្ភាសន៍ទាក់ទងនឹងផែនការសកម្មភាព ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា ផែនការត្រូវធ្វើឡើងដោយខ្លួនឯង ហើយពេលខ្លះថ្នាក់លើជាអ្នកធ្វើ ។ សាក្សីបានបន្ថែមថា ខ្លួនបានឮថា ប៉ុល ពតជាលេខាបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផនគឺជាប្រមុខរដ្ឋ អៀង សារី គឺជារដ្ឋមន្ត្រីក្រសួងការបរទេស ។ តំបន់៥០៥គឺជាតំបន់ស្វយ័ត ហើយមេឃុំជាអ្នកទទួលខុសត្រូវរួមចំណែកអនុឃុំទទួលខាងយោធា ។ យោធានៅតំបន់៥០៥មានតួនាទីវៃខ្មាំងនៅតាមព្រំដែនចំណែកឯខាងសន្តិសុខមានតួនាទីខាងចាប់ចង ។ រាល់ការរៀបការយុទ្ធជន អាចស្នើទៅថ្នាក់ស្រុកទាល់តែមាន

ការយល់ព្រមពីខាងនារីទើបអាចរៀបការបាន ។ កន្លងមកមិនមាននារីណាម្នាក់ដែលប្រកែកមិនព្រមរៀបការនោះឡើយ ។ សាក្សីបានបញ្ជាក់ថា ការបង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូក គឺមិនមានចែងនៅក្នុងឯកសារឡើយ ហើយការបង្ខំនោះប្រហែលជាអ្នកនៅតាមផ្ទះបាយតែប៉ុណ្ណោះ ។ បន្ទាប់មកលោកស្រីមេធាវី ស៊ីម៉ូណូហុគ បានបន្តការសាកសួរទាក់ទងនឹងជីវភាពនៅតាមសហករណ៍ផ្សេងៗ ។ សាក្សីបាន បញ្ជាក់ថាការរស់នៅរបស់ប្រជាពលរដ្ឋនៅស្រុកសំបួរ គឺនៅឃុំខ្វះហូបបបរ ហើយមានលាយដំឡូងប៉ុន្តែ នៅថ្នាក់ឃុំដែលខ្លួនគ្រប់គ្រង គឺប្រជាជនហូបបាយ មិនមានឈឺថ្កាត់ដោយសារការធ្វើការងារឡើយ គឺដោយសារជំងឺគ្រុនចាញ់តែប៉ុណ្ណោះ ។ ចំពោះរបបអាហារពុំមានការបែងចែករបបអាហារតាមប្រភេទប្រជាជនចាស់អ្នកត្រៀមឬអ្នកថ្មីនោះទេ ។មុនពេលបញ្ចប់ការសាកសួរលោកស្រីមេធាវីបានបន្តសំណួរ ទាក់ទងនឹងអំណាចកំពូលរបស់ នួន ជា ហើយសាក្សីក៏បានបញ្ជាក់ថាអំណាចកំពូលនោះគឺសំដៅដល់អំណាចថ្នាក់លើរបស់បក្ស ។

## ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ

### ៤.១) ការសាកសួរដោយក្រុមមេធាវីការពារក្តី នួន ជា

មុនពេលចាប់ផ្តើមលោកមេធាវី អ៊ីនូហ៊្សី បានសាកសួរទៅអង្គជំនុំជម្រះអំពីឯកសារដើម្បីសាកសួរសាក្សីដែលខ្លួនដាក់ជូនអង្គជំនុំជម្រះធ្វើការសំរេច ។ បន្ទាប់ពីការពិភាក្សា លោកចៅក្រមនិល ណុន បានបញ្ជាក់ថាឯកសារនោះមិនមានពាក់ព័ន្ធនឹងភស្តុតាងនោះទេ ។ លោកមេធាវីអាចសួរសំណួរដែលទាក់ទងនឹងឯកសារនោះបាន ។ បន្ទាប់មកលោកស្រីចៅក្រម ខាតហ្វ៊ាយត៍ បញ្ជាក់ ជូនមេធាវីថា ខ្លួនមានសិទ្ធិសួរសំណួរដែលពាក់ព័ន្ធនឹងឯកសារនោះបាន ។ ភ្លាមនោះមេធាវីបានបញ្ជាក់ថា ខ្លួននឹងមិនសួរសំណួរទៅកាន់សាក្សីទេគឺសុំឲ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការតបនឹងសក្ខីកម្មរបស់សាក្សីទាក់ទងនឹងការជម្លៀស ។ លោកតំណាងសហព្រះរាជអាជ្ញានិងលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ូណូហុគ បានជំទាស់ចំពោះការធ្វើសេចក្តីថ្លែងការណ៍របស់ នួន ជា ដោយ



នួន ជា ធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភពឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា)

អះអាងថា ជនជាប់ចោទមិនអាចប្រើប្រាស់ពេលវេលារបស់តុលាការដើម្បីធ្វើសេចក្តីថ្លែងការណ៍តាមតែចិត្តបានទេ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកមេធាវី នៅតែទទូចឲ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការណ៍ ហើយបន្ទាប់មកលោកប្រធានក៏បានអនុញ្ញាត ។ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍តបនឹងការជម្លៀសដែលមានខ្លឹមសារដូចតទៅ ៖

> *"សូមគោរពបងប្អូនរួមជាតិ!សូមគោរពលោកប្រធាន!ខ្ញុំសូមនិយាយអំពីការជម្លៀសប្រជាជនដោយបន្ទំ ។ ខ្ញុំសូមធ្វើការឆ្លើយតបមួយចំនួនចំពោះសក្ខីកម្មរបស់លោករូបនេះអំពីការជម្លៀសប្រជាជន ។ លោកសាក្សីបាននិយាយពីហេតុផលដ៏ត្រឹមត្រូវខ្លះៗ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង គឺដើម្បីចៀសពីការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការអត់ឃ្លាន និងសង្គ្រាមដណ្តើមគ្នាទៅវិញទៅមកតែលោក សាក្សីភាគច្រើនមិនបានដឹងពីមូលហេតុច្បាស់ និងច្រើនជាងនេះទេ ហើយដែលហាក់ដូចជាបង្ហាញថា ចេតនា ឬមធ្យោបាយជម្លៀសដូចជាមិនល្អទៅវិញ ។ តទៅនេះខ្ញុំសូមធ្វើការឆ្លើយតបដូចតទៅៈ ជាដំបូងខ្ញុំសូមជម្រាបថា យើងខ្ញុំជាអ្នកចាញ់សង្គ្រាមត្រូវបានចោទប្រកាន់ពីការជម្លៀសប្រជាជនដោយបន្ទំ ក៏ប៉ុន្តែសកម្មភាពក្នុងពេលបច្ចុប្បន្ននេះមានភាពមិនសមរម្យ បើប្រៀបទៅនឹងការជម្លៀសនៅបន្ទាប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ទៅទៀត ។ ខ្ញុំសូមនិយាយដើម្បីប្រជាជនក្រីក្រដែលត្រូវបានជិះជាន់និងធ្វើទុក្ខបុកម្នេញដល់អាយុជីវិតដោយពួកអ្នកមានលុយ មានបុណ្យសក្តិដែលកំពុងប្លន់ដីធ្លីស្រែចំការ..." ។*

**កំណត់សម្គាល់៖** *ខណៈពេលដែល នួន ជា កំពុងធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន លោកប្រធានបានបញ្ឈប់ការដោយអះអាងថា ការធ្វើ សេចក្តីថ្លែងការណ៍នោះចាកឆ្ងាយពីអង្គហេតុដែលកំពុងធ្វើសវនាការលើការស្តាប់សក្ខីកម្មរបស់សាក្សីហើយបញ្ហាដែល នួន ជា លើកឡើងនោះសាក្សីបានផ្តល់សក្ខីកម្មគ្រប់គ្រាន់ហើយ ។ លោកប្រធានក៏បាន សួរបញ្ជាក់ទៅជនជាប់ចោទថា តើខ្លួនមានសំណួរផ្សេងដែលត្រូវសួរដែរទេ ។ ឆ្លើយតបនឹងបញ្ហានេះ នួន ជា បានស្នើសុំអង្គជំនុំជម្រះដើម្បីនិយាយពីការជម្លៀសប្រជាជន តែទោះជាយ៉ាងណា លោកប្រធាននៅតែមិនអនុញ្ញាតឲ្យជនជាប់ចោទធ្វើសក្ខីកម្មឡើយ ។ បម្រាមរបស់លោកប្រធានមិនត្រូវបាន នួន ជា អនុវត្តតាមឡើយដោយ នៅតែបន្តការបកស្រាយទាំងក្នុងពេលដែលឧបករណ៍បំពងសម្លេងមិនទាន់មានដំណើរការនៅឡើយ ។ ជាថ្មីម្តងទៀតលោកប្រធាននៅតែប្រកាន់ជំហរមិនអនុញ្ញាតឲ្យជនជាប់ចោទធ្វើការបកស្រាយឡើយ ។ ភ្លាមនោះលោកមេធាវី ដេស្តមេន បានក្រោកឈរឡើង និងស្នើសុំលោកប្រធានដើម្បីអនុញ្ញាតឲ្យកូនក្តីខ្លួនធ្វើសេចក្តីថ្លែងការណ៍ជាថ្មី ដោយសារមិនមានការបកប្រែជាភាសាអង់គ្លេស និងបារាំង ។ ប៉ុន្តែលោកប្រធានមិនអនុញ្ញាតនោះឡើយ ដោយមូលហេតុមិនចង់ឲ្យចំណាយពេលវេលាបន្តសវនាការលើអង្គហេតុដែលមិនពាក់ព័ន្ធនិងអង្គហេតុដែលកំពុងដំណើរការនេះឡើយ ហើយលោកក៏បានបង្គាប់ឲ្យមេធាវីធ្វើការសាកសួរសហសេវិកជាតិរបស់ខ្លួនចំពោះសេចក្តីថ្លែងការណ៍ដែលមិនមានការបកប្រែជាភាសាអង់គ្លេសនោះ ។ បន្ទាប់ពីបានឮដូចច្នេះ លោក ដេស្តមេន បានស្នើសុំដល់អង្គជំនុំជម្រះថាកូនក្តីខ្លួនសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការទេ ដោយសារខ្លួនមិនមានសិទ្ធិនិយាយនៅក្នុងសវនាការនេះ ។ លោកប្រធានបានសាកសួរ នួន ជា ថា តើខ្លួនពិតជាមានបំណងចូលរួមដំណើរការនៅបន្ទប់ក្រោមមែនដែរឬទេ? នួន ជា ក៏បានបញ្ជាក់ថា "ជម្រាបលោកប្រធាន បើមិនឲ្យខ្ញុំនិយាយទៀតទេខ្ញុំសុំទៅនៅខាងក្រោម" ។*

*តាមរយៈការបញ្ជាក់ពីគោលជំហររបស់ខ្លួនដូចនេះ លោកប្រធានបានអនុញ្ញាតឲ្យជនជាប់ចោទចុះទៅបន្ទប់ខាងក្រោមតាមការស្នើសុំ ហើយលោកប្រធានបានផ្ទេរវេទិកាបន្តជូនមេធាវីជាតិរបស់ នួន ជា ដើម្បីធ្វើការ សាកសួរ ។*

*លោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា បានចាប់ផ្តើមសាកសួរទាក់ទងនឹងការជ្រើសរើសលោកសង្ឃ ។*

ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ មានការបញ្ជាក់ពីអាជ្ញាធរថា បដិវត្តគេមិនធ្វើពីរដងនោះទេ គឺត្រូវធ្វើបដិវត្តន៍ប្រជាជន និងបដិវត្តន៍វប្បធម៌ក្នុងពេលជាមួយគ្នា ។ ពាក់ព័ន្ធនឹងអត្ថន័យ នៅក្នុងទង់បដិវត្តន៍ លោកមិនចាំថានៅក្នុងទស្សនាវដ្តីនោះមានចែងពីការហាមឃាត់មិនឲ្យមានវត្តអារាមឬអត់នោះទេ ប៉ុន្តែវាជានយោបាយរបស់មជ្ឈិមបក្ស ។ លោកមេធាវីបានសួរបន្តទាក់ទងនឹងការប្រជុំជាមួយ នួន ជា ទាក់ទងនឹងខ្មាំង ។ សាក្សីបានបញ្ជាក់ថាពេលនោះ នួន ជា បានទៅប្រជុំនៅឃុំដា ហើយនិយាយពីខ្មាំងដែលមានអាមេរិកកាំង និងវៀតណាម ហើយក្រៅពីនោះមាននិយាយពីការធ្វើសហករណ៍ ។ សាក្សីបានបន្តថាខ្លួនបានជួបតែ នួន ជា ម្នាក់គត់មិនមានមេដឹកនាំផ្សេងទៀតនោះទេ ហើយជួបនៅពេលនោះគឺនៅក្នុងបន្ទប់សាលសិក្សាសាលាដែលមានអ្នកចូលរួមមកពីស្រុកស្ទួល សំបូរ និងស្រុកក្រចេះ ។ លោកមេធាវីបានបន្តសួរទាក់ទងនឹងអត្តចរិករបស់ នួន ជា នៅពេលប្រជុំ ។ លោកតំណាងសហព្រះរាជអាជ្ញា ឌែល លីសាក់ បានជំទាស់នឹងសំណួររបស់មេធាវីដែលសួរឲ្យសាក្សីបញ្ជាក់ពីចរិកលក្ខណៈរបស់ នួន ជា ដែលវាជាការស្មានប៉ុណ្ណោះ ។ ភ្លាមនោះលោកមេធាវីបានបញ្ជាក់ថាដោយសារសាក្សីជួបផ្ទាល់ជាមួយ នួន ជា ដូច្នេះចម្លើយរបស់សាក្សីមិនមែនជាការស្មាននោះឡើយ ។ លោកសាក្សីបានបញ្ជាក់ថា នៅពេលនោះ នួន ជា មានចរិកល្អសមជាអ្នកដឹកនាំដែលល្អ ។ មុនពេលខ្លួនចូលបដិវត្តខ្លួនមិនដែលឃើញមានការទម្លាប់គ្រាប់បែកទេគឺធ្លាប់ឃើញនៅពេលធ្វើរដ្ឋប្រហារ ហើយនៅឆ្នាំ១៩៧២ខ្លួនបានឃើញមានការបំផ្លាញស្ពានជាដើមស្ទើរតែដាច់អស់ហើយ ។ ពេលយោធាចូលស្រុកសំបូរនៅឆ្នាំ១៩៧៨ ស្ថានភាពមានការច្របូកច្របល់ ដោយសារមានការចាប់កម្មាភិបាលថ្នាក់ឃុំ និងស្រុក ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីបញ្ជាក់ថាខ្លួនរស់នៅឃុំវឌ្ឍនៈ ហើយបានឮតាមវិទ្យុថាមានការរំដោះទីក្រុង ។ ពេលនោះប្រជាជនមានការសប្បាយរីករាយណាស់នៅពេលឮថាប្រទេសជាតិត្រូវបានរំដោះ ។ លោកមេធាវីបានបន្តសួរទាក់ទងនឹងការប្រជុំ និងប្រតិកម្មរបស់ប្រជាជនក្នុងការបង្កើតសហករណ៍ និងសហគមន៍ ។ សាក្សីបានញ្ជាក់ថា នួន ជា មិនបានទៅដល់ស្រុកសំបូរទេ គឺទៅប្រជុំនៅដ-៣ ឃុំថ្មដា ហើយពេលត្រលប់មកវិញមាន តាបែត ជាអ្នករៀបចំសហគមន៍ ។ សាក្សីបានបន្តថា តាបែត ដែលថាគាត់ជាមនុស្សមានចរិតមិនល្អ ធ្វើអ្វីតាមចិត្តរបស់ខ្លួនតែប៉ុណ្ណោះ ។ មេធាវីបានបន្តសំណួរដោយឲ្យសាក្សីបញ្ជាក់ពីភាពខុសគ្នារវាងសហករណ៍និងសហគម៍ ។ សាក្សីបានបញ្ជាក់ថា សហករណ៍ប្រជាជនមិនសូវដឹងទេតែបើសហគមន៍គឺរស់នៅរួមហូបចុករួមគ្នា ។ បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវីការពារក្តី នួន ជា លោកប្រធានបានផ្ទេរវេទិកាជូនមេធាវី អៀង សារី ដើម្បី សាកសួរ បន្តប៉ុន្តែមេធាវីបានបញ្ជាក់ថា ខ្លួនមិនមានសំណួរទៅសាក្សីឡើយ ។

### ៤.២) ការសួរដេញដោលដោយក្រុមមេធាវីខៀវ សំផន

លោកមេធាវី វែកគែន បានចាប់ផ្តើមសួរទាក់ទងនឹងការចូលបដិវត្តរបស់សាក្សី ។ សាក្សីបានបញ្ជាក់ថាក្រោយពេលរដ្ឋប្រហារឆ្នាំ១៩៧០ មានចលនា“ឃុតខត្តមូវង្សវឌ្ឍនា”មួយដែលអះអាងថាមកជួយជាតិប៉ុន្តែខ្លួនមិនជឿទុកចិត្តនោះឡើយ ហើយក្រោយមកមានចលនាខ្មែរក្រហមដែលចុះមកបង្រៀន ហើយពេលនោះ តាបែត បានយកសៀវភៅមកឲ្យខ្លួនរៀន ហើយក្រោយមកខ្លួនត្រូវបានតែងតាំងជាគណៈឃុំវឌ្ឍនៈ ។ សាក្សីបានបន្ថែមថាខ្លួនចូលបដិវត្តនៅឆ្នាំ១៩៧១ដោយចិត្តខ្លួនឯង ហើយពេលនោះខ្លួនមានចិត្តចង់ជួយជាតិឲ្យប្រជាជនមានជីវភាពសមរម្យ ។ ទាក់ទងនឹងជម្លោះរវាងយោធា និងអជ្ញាធរនៅឆ្នាំ១៩៧៨លោកសាក្សីបាន បញ្ជាក់ថា ខ្លួនមិនសូវដឹងច្បាស់ទេ ប៉ុន្តែកាលនោះមាន ឈ្មោះ សុវណ្ណ បានយកសំបុត្រពី សាន មកឲ្យខ្លួនថាខាងស្រុកឲ្យយកគោ៥០ក្បាល ហើយក្រោយមកខាងយោធាបានសួរអំពីមូលហេតុ ហើយខ្លួនបានបញ្ជាក់ថាខាងស្រុកឲ្យមកយក ។ តាមរយៈនេះ ខ្លួនអាចយល់បានថាខាងយោធា និងអាជ្ញាធរមិនមានទំនាក់ទំនងល្អជាមួយគ្នាឡើយ ។ បន្ទាប់ពីបញ្ចប់ ការសាកសួរសាក្សី យុនគីម លោក ប្រធានអង្គជំនុំជម្រះបានប្រកាសបន្តសវនាការសាកសួរសាក្សី ម្នាក់ទៀតដែលមានលេខសំគាល់ TCW-៣២១ ដូចដែលបានគ្រោងទុក ។

## VIII) សវនាការសាកសួរដេញដោលសាក្សី ខៀវ នៅ

នៅរសៀលថ្ងៃទី២០ដល់២១ ខែមិថុនា ឆ្នាំ២០១២ បន្ទាប់ពីអង្គជំនុំជម្រះបានបញ្ចប់កិច្ចដំណើរការនីតិវិធីសាកសួរសាក្សី យុន គីម លោកប្រធានអង្គជំនុំជម្រះបានប្រកាសបន្ត

សវនាការសាកសួរសាក្សី បន្ទាប់ដែលមានលេខសំគាល់ TCW-៣២១ ដូចដែលបានគ្រោងទុក ។សូមបញ្ជាក់ថា នៅក្នុងកិច្ចដំណើរការនេះមានការចូលរួមពីគ្រប់ភាគីទាំងអស់លើកលែងតែជនជាប់ចោទអៀងសារី ដោយសារបញ្ហាសុខភាព និងមេធាវីអន្តរជាតិការពារក្តី ម៉ៃឃើល ខាណាវ៉ាស មិនមានវត្តមាន ។ នៅក្នុងកិច្ចដំណើរការសាកសួរលើសាក្សីរូបនេះ គឺផ្តោតទៅលើការជម្លៀសលោកសង្ឃ ការបង្កើតសហករណ៍និងរចនាសម្ព័ន្ធរដ្ឋបាល នៅក្នុងភូមិភាគនិរតី និងការងាររបស់សាក្សីនៅទីក្រុងភ្នំពេញ ។ លោកប្រធានបានចាប់ផ្តើមដោយធ្វើការសាកសួរព័ត៌មានមួយចំនួនទាក់ទងនឹងប្រវត្តិសាវតារបស់សាក្សី ។ សាក្សីបានបញ្ជាក់ថាខ្លួន ឈ្មោះ ខៀវ នៅ កើតឆ្នាំចរ អាយុ៧៩ឆ្នាំ ប្រពន្ធឈ្មោះ ងឹម អឿន និងមានកូន៦នាក់ ។ បន្ទាប់មកលោកប្រធានបានផ្តល់សេចក្តីណែនាំមួយចំនួនដល់សាក្សីទាក់ទងនឹងសិទ្ធិមិនឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ហើយនិងករណីកិច្ចដែលសាក្សីត្រូវតែឆ្លើយនូវអ្វីដែលខ្លួនដឹង ។ បន្ទាប់ពីបញ្ចប់ការណែនាំទាំងនេះរួចមកលោកប្រធានបានផ្ទេរវេទិកាការជូនភាគីសហព្រះរាជអាជ្ញាដើម្បីធ្វើការសាកសួរដេញដោលបន្ត ។

### ១) កាសាកសួរដោយសហព្រះរាជអាជ្ញា

លោកតំណាងសហព្រះរាជអាជ្ញា វេង ហ៊ត់ បានចាប់ផ្តើមការសាកសួរដោយការអាននូវបទសម្ភាសន៍ដែលឡើងដោយសាក្សី និងសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងទំនាក់ទំនងរបស់សាក្សីជាមួយ តាម៉ុក ពេលនៅបួសជាសង្ឃ ។ សាក្សីបានបញ្ជាក់ថា តាម៉ុក បួសនៅវត្តត្រពាំងធំប្រហែលដប់ឆ្នាំ ហើយ ពេលនោះខ្លួននៅក្មេងនៅឡើយដែលក្រោយមក តាម៉ុក បានលាកចាកសិក្ខាបទ ហើយរៀបការ ។ នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបាន តម្រូវឲ្យព្រះសង្ឃដែលនិមន្តមកពីខេត្តតាកែវ និងភ្នំពេញទៅប្រជុំគ្នានៅវត្តអង្គរការដើម្បីលាចាកសិក្ខាបទ ហើយក្រោយមកការប្រតិបត្តិសាសនាត្រូវបានលុបបំបាត់ ។ សាក្សីបានបញ្ជាក់ថាខ្លួនមិនបានឃើញការជម្លៀសប្រជាជនចេញពីភ្នំពេញមកតាកែវទេ ដោយគ្រាន់តែដឹងថាមានមនុស្សមកពីភ្នំពេញ និងតាកែវដោយសារខ្លួនបានឮពួកឈ្លបនិយាយគ្នា និងមានកម្មាភិបាលខ្មែរក្រហមដើរតាមប្រជាជនដើម្បីរៀបចំកន្លែង ប៉ុន្តែខ្លួនមិនបានដឹងពីការបង្កើតសហករណ៍ឡើយ ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានផ្ទេរ



សាក្សី ខៀវ នៅ

វេទិកាការសាកសួរនេះទៅកាន់សហសេវិករបស់ខ្លួនគឺលោក ថារីក ដោយចាប់ផ្តើមសួរទាក់ទងនឹងព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ ។សាក្សីបានបញ្ជាក់ថាខ្លួនមានស្រុកកំណើតនៅឃុំត្រពាំងធំ ហើយក្រោយមកឃុំនេះត្រូវបានគេបែងចែកជាពីរគឺឃុំត្រពាំងធំខាងជើង និងត្រពាំងធំខាងត្បូង ។ បច្ចុប្បន្នខ្លួនមានទីលំនៅនៅឃុំត្រពាំងធំខាងត្បូងជិតវត្តត្រពាំងធំ ហើយ តាម៉ុក ក៏មានស្រុកកំណើតនៅឃុំត្រពាំងធំខាងត្បូងដែរ ។ ឆ្លើយតបនឹងសំណួរជាបន្តបន្ទាប់របស់សហព្រះរាជអាជ្ញាសាក្សីបានបញ្ជាក់ថា អង្គការបានប្រាប់ខ្លួនឲ្យចាកចេញពីវត្តត្រពាំងធំ ហើយទៅជួបជុំគ្នានៅវត្តអង្គរការ ។ ទាក់ទងនឹងការផ្លាស់ទីកន្លែងនេះសាក្សីបានបញ្ជាក់ថាខ្លួនមិនដឹងពីមូលហេតុឡើយ ដោយសារនៅក្នុងសម័យសង្គ្រាមខ្លួនបានឮចាស់ៗប្រាប់ថាត្រូវឲ្យដាំដើមគរដើម្បីរស់ ដូច្នេះខ្លួនមិនហ៊ានសួរនាំពីបញ្ហានោះឡើយ ។ នៅថ្ងៃទី១៧ មេសាមានការជម្លៀស ព្រះសង្ឃដែលមកពីខេត្តតាកែវ និងភ្នំពេញដោយមិនដឹងមូលហេតុហើយ នៅពេលនោះមិនមានព្រះសង្ឃណាមួយដែលបដិសេធមិនព្រមសឹកនោះឡើយ ។ តាមរយៈការសន្និដ្ឋានរបស់ខ្លួន សាក្សីបានបញ្ជាក់ថា ការជម្លៀសព្រះសង្ឃនេះគឺមានការបញ្ជាពីពួកឈ្លប ពីព្រោះខ្លួនមិនដែលឃើញមានមេដឹកនាំខ្មែរក្រហមចុះទៅដល់តំបន់របស់ខ្លួនឡើយ ។ ចំពោះលោកសង្ឃដែលមិនទាន់បានសឹកត្រូវបានខ្មែរក្រហមនាំមកស្នាក់នៅវត្តផ្លឹកជ្រុំ ហើយនៅទីនោះប្រជាជនអាច

យកចង្ហាន់ទៅប្រគេនលោកសង្ឃបានរហូតដល់ជាងមួយឆ្នាំទើបលោកសង្ឃនៅទីនោះត្រូវបានផ្សឹកទាំងអស់ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តការសាកសួរទាក់ទងនឹងការប្រតិបត្តិព្រះពុទ្ធសាសនាសាក្សីបានបញ្ជាក់ថាខ្លួននៅតែប្រតិបត្តិសាសនារហូតដោយគោរពនៅក្នុងចិត្ត ដូច្នេះមិនមានអ្នកណាម្នាក់ដឹងថាខ្លួននៅតែគោរពសាសនានោះឡើយ ។ សាក្សីបានបញ្ជាក់ថាមុនពេលលាចាកសិក្ខាបទខ្លួនបានឃើញប្រជាជនត្រូវបានជម្លៀសចេញពីភ្នំពេញគឺពេលទាហានវាយដល់ណាប្រជាជននៅទីនោះត្រូវតែចេញមកដែរ ។ ប្រជាជនដែលចេញមកពីភូមិត្រូវទៅរស់នៅតាមសហករណ៍ ហើយចំណែកអ្នកដែលមកពីភូមិភាគត្រូវរស់នៅដោយឡែក ។អ្នករស់នៅក្នុងសហករណ៍ត្រូវធ្វើស្រែរួមគ្នាដោយមិនមានប្រជាជនណារស់នៅក្រៅសហករណ៍នោះឡើយ ពីព្រោះនៅទីនោះមានមេកងនិងមេក្រុមជាអ្នកគ្រប់គ្រង ។ ប្រធានឃុំទាំងអស់ត្រូវបានតែងតាំងដោយអង្គការ ដែលគេហៅថាអង្គការតែងតាំងអង្គការចាត់តាំង ។ នៅពេលនោះមានការអប់រំរៀនសូត្រប្រជុំទៀនដែលត្រូវបានធ្វើឡើងជាញឹកញាប់ ហើយមាននិយាយពីបទពិសោធការងារជាដើម ។ ពេលខ្លះមានការប្រជុំរៀនសូត្រនិងចែកឯកសារថែមទៀតផង ។ ចំពោះទង់បដិវត្តសាក្សីបានបញ្ជាក់ថាខ្លួនធ្លាប់ឮតែចម្រៀងប៉ុណ្ណោះហើយមិនដែលឃើញឯកសារនោះឡើយ ។ ការធ្វើប្រវត្តិរូបគឺសម្រាប់តែអ្នកថ្មីៗតែប៉ុណ្ណោះ ហើយរបាយការណ៍ទាំងនោះត្រូវបញ្ជូនទៅអង្គការថ្នាក់លើ ប៉ុន្តែខ្លួនមិនដឹងថាអង្គការជាអ្នកណានោះទេ ។ សាក្សីបានបន្ថែមថា ព្រាប គិត និង ចាយ គឺជាគណៈស្រុកត្រាំកក់កាលជំនាន់នោះ ។ ពេលខ្លួនទៅនៅមន្ទីរពេទ្យខ្លួនមិនទាន់ត្រូវបានចាត់តាំងការងារច្បាស់លាស់នៅឡើយទេ ហើយក្រោយមកគណៈកម្មការខេត្តឈ្មោះ សោម បានមកប្រាប់ខ្លួនឲ្យទៅធ្វើការនៅបន្ទាយទាហានពីសម័យ លន់ នល់ ជាមួយ តាម៉ុក ដោយធ្វើជាអ្នកកាន់លុយ និងជួយធ្វើស្មៀតចប ។ ប្រហែលឆ្នាំ១៩៧៦ ខ្លួនត្រូវបានបញ្ជូនឲ្យទៅនៅខាងពាណិជ្ជកម្មដឹកជញ្ជូននៅភ្នំពេញដើម្បីគ្រប់គ្រងអ្នកបើកឡានប្រហែលដប់នាក់ដើម្បីដឹកសំភារៈពីឃ្លាំងរដ្ឋទៅភូមិភាគដែលមានដូចជា ចាន ឆ្នាំង ទៀន គ្រឿងដែក ស៊ីម៉ង់ ដែលប្រជាជន ត្រូវការ ។ រាល់ការដឹកជញ្ជូនទាល់តែមានលិខិតអនុញ្ញាតចេញពីថ្នាក់លើខាងផ្នែកសេដ្ឋកិច្ចគឺ វ៉ន វេត ហើយមានមន្ទីរក-២២ ជាអ្នកធ្វើការផ្ទាល់ ។ ប្រធានឃ្លាំងរដ្ឋ មានឈ្មោះ រឿង ហើយខាងខស្សរាហកម្មមាន ចេង អន ។ ចំណែកឥវ៉ាន់ដែលដឹកពីភូមិភាគមកឃ្លាំងរដ្ឋទៅភ្នំពេញវិញមានដូចជា សំឡី, គរ, ដូង និងផលិតផលផ្សេងទៀតដែលប្រជាជនធ្វើបាន ។ សាក្សីបានបន្ថែមថា ចំពោះការបាត់ខ្លួនរបស់ វ៉ន វេត, ហ៊ូ នឹម និង ហ៊ូ យុន នោះខ្លួនគ្រាន់តែបានឮតាមគេតែប៉ុណ្ណោះដោយមិនដឹងពីមូលហេតុនោះឡើយ ។ ចំណែកអ្នកបាត់ខ្លួនផ្សេងទៀតត្រូវបានចោទថាក្បត់ ។ ចំពោះកិច្ចប្រជុំពីវិន័យ សាក្សីបានបញ្ជាក់ថា ខ្លួនបានចូលរួមនៅភូមិភាគដែលមានប្រធានភូមិភាគគឺ សំ ប៊ិត អនុប្រធានរបស់ តាម៉ុក ជាអ្នកបង្រៀន ហើយកិច្ចប្រជុំនោះនិយាយពីមាគ៌ាប្រជាជន មាគ៌ាច្បាប់ និងមាគ៌ាបដិវត្ត ។ សាក្សីបានបញ្ជាក់ថា ពេលដែលខ្លួនបំពេញតួនាទីនៅភ្នំពេញខ្លួនធ្លាប់បានឃើញ តាម៉ុក និង ប៉ុល ពត ។ លើសពីនេះខ្លួនបានជួប ខៀវ សំផន នៅក្រសួងពាណិជ្ជកម្មនៅពេលដែល ខៀវ សំផន ទៅជំនួស វ៉ន វេត មួយរយៈ ។ ចំពោះអ្នកដឹកនាំនៅភូមិភាគនិរតីក្រៅពី តាម៉ុក គឺមានថ្នាក់ខេត្ត និងខាងកងពល បានមកជួបជាមួយ ប៉ុល ពតដែរ ។ តាមរយៈការរំឮករបស់សហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ថា ជូ ជេត គឺជាអ្នកធ្លាប់បួសរៀនជាមួយខ្លួន ហើយក្រោយមក ជូ ជេត និងប្រពន្ធត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ។

## ២) ការសាកសួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោក ពេជ អង្គ បានចាប់ផ្តើមដោយសាកសួរទាក់ទងនឹងជំនាន់ឥស្សរៈ សាក្សីបានបញ្ជាក់ថា ពាក្យឥស្សរៈនោះខ្លួនបានឮតាំងពីជំនាន់បារាំងរហូតដល់១៩៦៧ ទើបមានឥស្សរៈខ្មែរក្រហម ។ ចំណែក តាម៉ុក ក៏បានចូលរួមក្នុងចលនាឥស្សរៈដែលកាលនោះមារបស់ តាម៉ុក ធ្វើជាប្រធានឃុំហើយនៅពេល នោះ តាម៉ុក មានតួនាទីជាស្មៀន ។ មេធាវីបានបន្តសួរទាក់ទងនឹងការផ្សឹកព្រះសង្ឃ សាក្សីបានបញ្ជាក់ថា ព្រះសង្ឃដឹងជាមុនថានឹងមានការផ្សឹកដោយសារនៅក្នុងលទ្ធិកុម្មុយនីស្តមិនមានការគោរពសាសនាឡើយ ។ទោះបីជាយ៉ាងណាក៏ដោយការលាចាកសិក្ខាបទនេះគឺមានពិធីត្រឹមត្រូវដែលមានការចូលរួមពីប្រជាជន ។ ទាក់ទងនឹងការងារជាអ្នកកាន់លុយ សាក្សីបានបញ្ជាក់ថាកាលនោះខ្លួនមិនបានធ្វើការងារនេះទេដោយសារថ្នាក់លើបានហាមឃាត់មិនឲ្យចាយលុយវិញ ។

ចំពោះការដឹកជញ្ជូនសម្ភារៈត្រូវតែមានសំបុត្រស្នាមដែលចេញដោយ តាម៉ុក ឬខាងភូមិភាគហើយសម្ភារៈទាំងនោះត្រូវបានដឹកជញ្ជូនទៅដល់ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវជាដើម ។ សាក្សីបានរៀបរាប់ថា ខ្លួនបានជួប នួន ជា ពេល ទៅយកឧបករណ៍ភ្លើងទៅដាក់នៅប៉ុស្តិ៍វិទ្យុ ។ ចំពោះផ្នែកពាណិជ្ជកម្មនិរតីនោះមានជាប់ពាក់ព័ន្ធជាមួយខាងភូមិភាគ ហើយប្រធានឃ្លាំងរដ្ឋនៅពេលនោះមានឈ្មោះ រឿង ។ បន្ទាប់មកលោកមេធាវីអន្តរជាតិ បាណាបេ បានសាកសួរបន្តទាក់ទង នឹងការជំនួសតំណែង វ៉ន វេត ដោយ ខៀវ សំផន ។ សាក្សី បានរៀបរាប់ថានេះជាការសន្និដ្ឋានរបស់ខ្លួនដោយសារតែវាមិនមានឯកសារណាដែលនិយាយឲ្យច្បាស់លាស់នោះឡើយ ។

## ៣)ការសាកសួរដោយចៅក្រម ឡាវ៉េញ

ក្រោយពីបានបញ្ចប់ការសាកសួរដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកចៅក្រម ឡាវ៉េញ បានធ្វើការសាកសួរទាក់ទងនឹងស្រុកកំណើតរបស់ តាម៉ុក ។ សាក្សីបានបញ្ជាក់ថា តាម៉ុក មានស្រុកកំណើតនៅក្នុងភូមិជាមួយខ្លួន ។ តាម៉ុក បាននិយាយថាខ្មាំងគឺជាអ្នកដែលប្រឆាំងនឹងបដិវត្ត ហើយអ្នកដែលប្រឆាំងត្រូវប្រយុទ្ធគ្នា ហើយខ្លឹមសារពាក្យពេចន៍របស់ តាម៉ុក បានមានឥទ្ធិពលមកលើមនុស្សច្រើនទើបអាចកាន់អំណាចបាន ។ សាក្សីបានរៀបរាប់ថាខ្លួនបានជួប នួន ជា បានម្តងនៅពេលដែលខ្លួនទៅរកឧបករណ៍ភ្លើងទៅដាក់នៅប៉ុស្តិ៍វិទ្យុ ។ រាល់ការដឹកឥវ៉ាន់ចេញពីឃ្លាំងគឺមានលិខិតអនុញ្ញាតពីមន្ទីរក-២២ដែលមាន រឿង ជាអ្នកប្រធានឃ្លាំង ។ ការដឹកជញ្ជូនទៅកំពង់សោម គឺដឹកតាមរថភ្លើង ហើយតួនាទីរបស់ខ្លួនគឺដឹកជញ្ជូនពីភូមិភាគនិរតីទៅភ្នំពេញ និងភ្នំពេញទៅភូមិភាគនីរតីវិញតែប៉ុណ្ណោះ ។

## ៤)ការសាកសួរដោយក្រុមមេធាវីការពារក្តី នួន ជា

ក្រោយពេលបញ្ចប់ការសាកសួរដោយលោកចៅក្រម ឡាវ៉េញ លោកប្រធានអង្គជំនុំជម្រះបានផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តី នួន ជា ដើម្បីធ្វើការសាកសួរសាក្សីបន្ត ។ លោកមេធាវី ផេស្តមេន ធ្វើការចាប់ផ្តើមដោយលើកឡើងពីសំណើរបស់ខ្លួនដែលដាក់ជូនអង្គជំនុំជម្រះទាក់ដែលទាក់ទងនឹងឯកសារថ្មីចំនួនពីរហើយមកទល់ពេលនេះខ្លួនមិនទាន់បានទទួលដំណឹងណាមួយពីអង្គជំនុំជម្រះឡើយ ។ បន្ទាប់ពីមានការពិភាក្សារបស់ក្រុមប្រឹក្សាជំនុំជម្រះរួចមកលោកស្រីចៅក្រម ខាតព្រ៉ាយត៍ បានបញ្ជាក់ថាអង្គជំនុំជម្រះបានទទួលឯកសាររបស់មេធាវីដែលដាក់មកនោះរួចហើយ ប៉ុន្តែនៅពេលមេធាវីធ្វើការយោងទៅលើឯកសារណាមួយនោះត្រូវបញ្ជាក់ថាតើឯកសារនោះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬស្ថិតនៅក្នុងបញ្ជីឯកសាររស់ភាគីណាមួយដើម្បីឲ្យអង្គជំនុំជម្រះធ្វើការសម្រេច ហើយភ្លាមនោះ លោកមេធាវីអះអាងថាឯកសារមួយដែលខ្លួនបានដាក់នោះ គឺមាននៅក្នុងបញ្ជីរបស់សហព្រះអាជ្ញា ប៉ុន្តែឯកសារមួយទៀតមិនមាននៅក្នុងបញ្ជីឡើយ ហើយខ្លួនមិនមានការតព្វកិច្ចក្នុងការបង្ហាញព័ត៌មានទាំងនោះទេ ។ លោកស្រីចៅក្រមបានបញ្ជាក់ជាថ្មីម្តងទៀតថា លោកមេធាវីអាចសាកសួរដោយធ្វើការយោងតែលើឯកសារដែលមាននៅក្នុងបញ្ជី ។ បន្ទាប់ពីការបញ្ជាក់របស់លោកស្រីចៅក្រមលោកមេធាវីបានអះអាងថា សំណួរដែលខ្លួននឹងសួរសាក្សីគឺផ្អែកទៅលើឯកសារទាំងពីរដោយមិនអាចខ្វះមួយណាបាន ដូច្នេះខ្លួននឹងមិនមានសំណួរទៅសាក្សីនោះឡើយ ។ ចំណែកមេធាវីការពារក្តីទាំងពីរក្រុមផ្សេងទៀត ក៏បានបញ្ជាក់ពីជំហមិនធ្វើការសាកសួរទៅកាន់សាក្សីដែរ ។ មុនពេលបញ្ចប់កិច្ចដំណើរការ នីតិវិធីលោកប្រធានអង្គជំនុំជម្រះបានប្រកាសនូវសេចក្តីព្រមានដល់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ ចោទ នួន ជា នៅក្នុងដំណើរការសវនាការក្នុងសំណុំរឿង០០២ ដោយអង្គជំនុំជម្រះធ្វើការកត់សម្គាល់ទៅលើទង្វើរបស់ក្រុមមេធាវីការពារក្តីចំនួនបីចំណុចដូចជា ៈ

- ការរំលោភដោយចេតនាលើសេចក្តីបង្គាប់នានារបស់អង្គជំនុំជម្រះ
- ការបញ្ចេញឯកសារសមាត់ ឬសមាត់បំផុតទៅសារព័ត៌មានដោយគ្មានការអនុញ្ញាតនិង
- ការធ្វើសេចក្តីថ្លែងការណ៍នានាក្នុងតុលាការមិនគោរពដល់តុលាការឬមិនស្របតាមនិយាម និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ដែលមានការទទួលស្គាល់ឡើយ ។

អំពើ និងគំរូនេះ នឹងត្រូវអង្គជំនុំជម្រះបញ្ជូនទៅកាន់គណៈមេធាវីតាមវិធាន៣៨នៃវិធានផ្ទៃក្នុង ។ ក្រោពីនោះ លោកប្រធានបានប្រកាសអំពីការផ្អាកកិច្ចដំណើរការនីតិវិធីដែលនឹងបន្តធ្វើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២លើការសាកសួរអ្នកជំនាញគឺ លោក

ដេវីដ ឆេនដ្ល័រ ។

**បញ្ហាផ្សេងៗ**

ក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្មរបស់សាក្សី នី កន ចំនួនបីថ្ងៃពេញ ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដោយសម្រេចចូលរួមសវនាការពីចម្ងាយតាមរយៈ ប្រព័ន្ធសោតទស្សន៍ដែលត្រូវបានរៀបចំទុកនៅបន្ទប់រង់ចាំនៅក្រោមបន្ទប់សាលសវនាការ ។ មូលហេតុនៃការលះបង់សិទ្ធិនេះគឺដោយសារជនជាប់ចោទ អៀង សារី មានបញ្ហាសុខភាពដោយមិនអាចអង្គុយ នៅក្នុងបន្ទប់សាលសវនាការបាន ។ ដូច្នេះ ជនជាប់ចោទ អៀង សារី ត្រូវបានតំណាងដោយមេធាវី ទាំងពីររូបរបស់ខ្លួននៅក្នុងកិច្ចដំណើរការសួរសាក្សីក្នុងរយៈពេលបីថ្ងៃពេញនេះ ។ ចំណែកជនជាប់ចោទ នួន ជា តែងតែស្នើសុំចូលរួមសវនាការពីចម្ងាយ នៅបន្ទប់រង់ចាំនៅពេលរសៀលបន្ទាប់ពីខ្លួនបានចូលរួមសវនាការដោយផ្ទាល់នៅពេលព្រឹកដោយផ្តល់ហេតុថា មានបញ្ហាសុខភាពមិនអាចអង្គុយក្នុងបន្ទប់សវនាការបាន ។ មានតែជនជាប់ចោទ ខៀវ សំផន តែម្នាក់គត់ដែលអាចចូលរួមសវនាការដោយផ្ទាល់ក្នុងរយៈពេលមួយថ្ងៃពេញជារៀងរាល់ថ្ងៃ ។

ក្នុងអំឡុងពេលសួរដេញដោលសាក្សី អឿន តាន គឺមានបញ្ហាមួយចំនួនគួរឲ្យកត់សម្គាល់ដូចជាៈ

មុនពេលកោះហៅសាក្សី អឿន តាន ចូលក្នុងសាលសវនាការ លោកមេធាវី ម៉ៃឃើល ខាណាវ៉ាស់ ស្នើសុំការណែនាំពីអង្គជំនុំជម្រះ ឲ្យ បានច្បាស់អំពីការប្រើប្រាស់ចម្លើយរបស់សាក្សីក្នុងការសួរផ្ទាញ់ ។ សំណើនេះផ្តើឡើងបន្ទាប់ពីអង្គជំនុំជម្រះសម្រេចទទួលយកការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ចំពោះសំណួររបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ។ សំណើនេះមិនត្រូវបានអង្គជំនុំជម្រះសម្រេចក្នុងអំឡុងពេលសវនាការនេះឡើយ ដោយអង្គជំនុំជម្រះបង្គាប់ឲ្យលោកមេធាវី ខាណាវ៉ាស បញ្ជាក់ជាលាយលក្ខអក្សរឲ្យបានច្បាស់អំពីគោលបំណងរបស់ខ្លួនក្នុងការស្នើសុំដើម្បីឲ្យអង្គជំនុំជម្រះសម្រេចនៅពេលក្រោយ ។ គួររំឭកថា នៅពេលសវនាការស្តាប់សក្ខីកម្មរបស់សាក្សី ខឹម ងន ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានយកចម្លើយដែលលោក ខឹម ងន ផ្តល់ជូនតំណាងសហព្រះរាជអាជ្ញារួចហើយមកចោទសួរសាក្សីដដែលនេះម្តងទៀតក្នុងគោលបំណងសួរផ្ទាញ់ ។ ប៉ុន្តែមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាត ដោយលោកផ្តល់សំអាងហេតុថាជាសំណួរច្រំដែល ។

បញ្ហាមួយទៀតគួរឲ្យកត់សម្គាល់ គឺពាក់ព័ន្ធនឹងការចោទសំណួរសាក្សីដោយតំណាងសហព្រះរាជអាជ្ញាជាតិ ។ លោកបានចោទសំណួរមួយចំនួនទៅលោក អឿន តាន តែសំណួរទាំងនោះមិនបានទទួលចម្លើយឡើយ ដោយសាក្សីបញ្ជាក់ថា គឺជាសំណួរដែលហួសពីសមត្ថភាពដែលលោកអាចឆ្លើយបាន ។ ភ្លាមនោះ លោកមេធាវី ម៉ៃឃើល ខាណាវ៉ាស់ លើកឡើងថា តំណាងសហព្រះរាជអាជ្ញាបានសួរសំណួរ ជាច្រើនដែលខ្ពស់ជាងតំណែងដែលសាក្សីអាចដឹង ។ ដូច្នេះគប្បីសួរសំណួរណាដែលស្របនឹងដំណែងរបស់សាក្សីអាចដឹងបាន ពោលគឺមិនអាចសួរលើអង្គហេតុទាំងមូលនៃសំណុំរឿងដើម្បីឲ្យសាក្សីបញ្ជាក់បានឡើយ ។ បន្ទាប់ពីការលើកឡើងរបស់លោកមេធាវី ខាណាវ៉ាស់ ប្រធានអង្គជំនុំជម្រះ


ចៅក្រម និល ណុន

បញ្ជាក់បន្ថែមថា "...សំណួរដែលពាក់ព័ន្ធ គឺមាននៅក្នុងកំណត់ហេតុជាមូលដ្ឋាននៃអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានរៀបចំរួចហើយ ។ សំណួរជាមូលដ្ឋាន ថាសាក្សីណាដឹងរឿងអ្វី ជាមូលដ្ឋានជាសំខាន់នោះ ។ សាក្សីណាដឹងអង្គហេតុទូលំទូលាយតាំងពីដើមរហូតដល់ចប់? រហូតអង្គជំនុំជម្រះសម្រេច

ឲ្យតាំងសំណួរដេញដោលលើសាក្សីនោះក្នុងវិសាលភាពនៃសំណុំរឿង០០២ទាំងមូល ។ ដូចជាសាក្សីផ្តល់សក្ខីកម្មកាលពីម្សិលមិញហើយសាក្សីផ្សេងៗទៀតគឺមានមូលដ្ឋានកត់សម្គាល់ដោយអ្នកស៊ើបអង្កេតរួចហើយ ថាគាត់ស្គាល់ គាត់ដឹងជាក់ច្បាស់ពាក់ព័ន្ធទៅនឹងអង្គហេតុ ឬព្រឹត្តហេតុណាមួយនៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងការធ្វើសក្ខីកម្មរបស់គាត់ ។ សូមតម្រង់ទិសឲ្យចំបញ្ហា មិនសួរដើម្បីឲ្យបានតែសួរនោះទេ គឺសួរដើម្បីបានចម្លើយដែលឆ្លុះបញ្ចាំងការពិតទៅនឹងអង្គហេតុដែលចោទប្រកាន់ទៅនឹងបទល្មើសដែលចោទប្រកាន់ជាភស្តុតាងដែលឆ្លុះបញ្ចាំងថាមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ដែលជាមូលដ្ឋានក្នុងការពិចារណាសម្រេចចុងក្រោយនៃសាលក្រមរបស់អង្គជំនុំជម្រះ ។ សូមកំណត់គោលដៅក្នុងការតាំងសំណួរឲ្យបានច្បាស់លាស់ កម្មវត្ថុនៃការសួរចំពោះសាក្សីមួយឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស ។...លោកតាំងសំណួរបន្តទៀតចៀសវាងសំណួរនាំមុខ សំណួរច្រំដែល សំណួរឧបមាវិធី សំណួរក្រៅអង្គហេតុជាដើម ។ សំណួរគួរតែខ្លីៗ ដើម្បីឲ្យសាក្សីដែលគាត់អាចឆ្លើយបាន មិនមែនសំណួរសួរសំខាន់សួរហួតសាក្សីស្តាប់មិន យល់សំណួរថាសំណួរនោះវាអស្ចារ្យនោះទេ» ។

បញ្ហាចុងក្រោយ គឺពាក់ព័ន្ធនឹងការបង្ហាញឯកសារដើម្បីរំឭកដល់ការចងចាំរបស់សាក្សី ។ ជាទូទៅក្នុងការសួរដេញដោលសាក្សី អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីយកចម្លើយដែលសាក្សីបានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតមកសួរបញ្ជាក់នៅ ចំពោះមុខខ្លួន(អង្គជំនុំ ជម្រះ) ដើម្បីរំឭកការ ចងចាំរបស់សាក្សី ។ ទោះបីមានការអនុវត្តជាទូទៅដូច្នេះក៏ដោយ ប៉ុន្តែនៅតែមានភាព មិនច្បាស់លាស់សម្រាប់ ភាគីមួយចំនួននៅក្នុង រឿងក្តី ។ ជាក់ស្តែងក្នុងការសួរដេញដោលសាក្សី អឿន តាន តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារដែលសាក្សីរូបនេះបានផ្តល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេត ដើម្បីសួរបញ្ជាក់សារជាថ្មីនៅចំពោះមុខអង្គជំនុំជម្រះ ។ ប៉ុន្តែត្រូវបាន លោក អាកនូ វ៉ែកគែន ជាមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ធ្វើការជំទាស់ ហើយលោកបានស្នើឲ្យតំណាងសហព្រះរាជអាជ្ញាពន្យល់អំពីមូលហេតុក្នុងការដាក់បង្ហាញឯកសារនេះ ដោយលោកលើកឡើងថា «...សហព្រះរាជអាជ្ញាបានប្រើសក្ខីកម្មដែលថាសាក្សីមិនចាំអំពីសេចក្តីលម្អិតដែលគាត់បានផ្តល់ជូន ។ ឥឡូវនេះព្រះរាជអាជ្ញាគាត់បានផ្តល់ជូននូវចំណុចច្បាស់ៗ ចំណុចជាក់លាក់ដែលសាក្សីគាត់មិនចាំនោះទេ ។ ដូច្នេះខ្ញុំគិតថា ការជំនុំជម្រះនេះមិនអាចធ្វើទៅដូច្នេះបាននោះទេ យើងមិនអាចគ្រាន់តែអានកំណត់ហេតុពីមុនរបស់សាក្សី ហើយយកមកឲ្យគាត់ឆ្លើយនោះទេ ។ យើងគ្រាន់តែអានឡើងវិញ ហើយសួរថា តើអីចឹងមានទេ ឬមិនមែនអីចឹងនោះ គឺអាចធ្វើបានដោយមិនចាំបាច់មានសាក្សីនោះទេ ។ ខ្ញុំមិនយល់អំពីវិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាឡើយ ដូច្នេះខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាពន្យល់អំពីវិធីសាស្ត្រនេះ» ។ ជាការឆ្លើយតប លោក តារីក បញ្ជាក់ថា « ខ្ញុំគ្រាន់តែសួរបញ្ជាក់អំពីចម្លើយរបស់គាត់ ដោយហេតុថាគាត់បានឆ្លើយ៤ឆ្នាំកន្លងទៅហើយនោះ គឺថាវាអាចមានភាពខុសគ្នាក្នុងកំរិតនៃការចងចាំរបស់គាត់ ។ ដូច្នេះហើយបានជាខ្ញុំចង់ឲ្យសាក្សីមើលចម្លើយរបស់គាត់ ហើយឲ្យគាត់បញ្ជាក់ថា តើត្រឹមត្រូវដោយស្មោះត្រង់ដែរឬអត់...» ។បន្ទាប់ពីការបំភ្លឺរបស់តំណាងសហព្រះ រាជអាជ្ញា អង្គជំនុំជម្រះបានសម្រេចបដិសេធការលើកឡើងរបស់លោកមេធាវីការពារក្តី ដោយលោកបញ្ជាក់ថា ភាគីអាចធ្វើដូច្នេះ បាន ។


សិស្សកំពុងយកឯកព័តមានតុលាការខ្លះៗ មុនចូលបន្ទប់សវនាការ

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ស-២១ ៖ មន្ទីរសន្តិបាលស-២១ គឺជាមន្ទីរសន្តិសុខសម្ងាត់របស់នគរបាលដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។

អគ្គសេនាធិការ ៖ ទីបញ្ជាការជាន់ខ្ពស់នៃកងទ័ពបដិវត្តកម្ពុជាដែលដឹកនាំដោយ សុន សេន ស្ថិតនៅទីក្រុងភ្នំពេញ ។

ក-១ ៖ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត ។

ក-២ ៖ លេខកូដសម្គាល់សម្រាប់ក្រសួងសង្គមកិច្ច ។

ក-៣ ៖ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ នួន ជា និង ខៀវ សំផន ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ *dccam@online.com.kh*

គេហទំព័រ ៖ *www.dccam.org* ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



***ឆាយ ឈុនលី***

**ឈុនលី** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***ខី សុជាតា***

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***លឹម ជ័យទ័ត្ត***

**ជ័យទ័ត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



***ចាន ប្រាថ្នា***

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។




(ប្រភពឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែកក្កដា ឆ្នាំ២០១២